៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤២ ខែ កក្កដា

ព.ស. ២៥១៤ គ.ស. ១៩៧០

-ភ្នំពេញ-

៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក-អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះមុនីកោសល សួរ-ហាយ

លោក ឈឹម-ឈាត លោក ឌិត-តាម

អ្នកស្រី ពេជ-សល់

# បញ្ជីរឿង

**អត្ថបទ** | **ទំព័រ**

## ផ្នែកសាសនា


១— កើតទៀតឬទេ ? (ត) ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង . . ៦៩៧

២— យសោភិវឌ្ឍនកថា ព្រះសាសនមុនី ក៏ម-ទូរ រៀបរៀង . . . ៧២៧


## ផ្នែកអក្សរសាស្ត្រ


៣— វិចារណកថា : បញ្ហាអប់រំនៅក្រៅសាលា លោក លី-ធាមតេង រៀបរៀង ៧៤៤

៤— រឿងសាមកុក លោក ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ៧៥២

៥— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ៧៦២

៦ រឿងវរវង្សសូរវង្ស ចម្លងចេញពីសាស្ត្រាស្លឹករឹត លោក លី-ធាមតេង ពិនិត្យផ្ទៀងផ្ទាត់. . . . . . . . . ៧៧[illegible]


## ផ្នែកកំណត់-ប្រវត្តិការណ៍


៧- ករណីការភតត្បាកចូលប្រាសាទអង្គរនៃពួកកុម្មុយនិស្ត :

- សាររបស់រដ្ឋាភិបាលប្រទេសកម្ពុជា ជូនចំពោះមតិពិភពលោក
- សេចក្ដីអំពាវនាវរបស់ ឯ. ឧ. អ៊ូ-ថាន់ ដើម្បីរក្សាប្រាសាទអង្គរវត្ត
- សេចក្ដីអំពាវនាវ អ្នកនិពន្ធខ្មែរ


---


តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យជុំសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ច. ព

# កើតទៀតឬទេ ?

ព្រះមហាវីរិយបណ្ឌិតោ ប៊ាន់-ខាត់ រៀបរៀង

[តពីលេខមុន ]

## បទទីប្រាំបី

### សីលជាធម៌ទ្រទ្រង់សត្វឬទេ ?

មនុស្សម្នាក់ធ្វើ "កម្ម" ក្នុងជាតិនេះ ហើយមនុស្សម្នាក់ទៀតទទួលផល "កម្ម" នោះ នៅក្នុងកំណើតគឺជាតិមួយទៀតដូច្នេះឬអ្វី ?

និយាយថា "អ្នកដាំមានសភាពដូចគ្នាសុទ្ធនឹងអ្នកបេះ" នេះ ជាយោបល់មួយបែប, និយាយថា "អ្នកដាំផ្សេងគ្នាស្រឡះពីអ្នកបេះ" នេះជាយោបល់មួយបែបទៀត ។ ព្រះសម្ពុទ្ធទ្រង់បដិសេធយោបល់ទាំង

ពីរបែបនេះចោលចន់ ហើយទ្រង់ត្រាប់ទេសនាជាកណ្ដាល ដែលហៅថា មជ្ឈិមាបដិបទា ជាធម៌មានហេតុផលពិសេស ។

ចំណុចសារវន្តនេះ ព្រះពុទ្ធឃោសាចារ្យ ធ្វើអត្ថាធិប្បាយទុកយ៉ាងពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គ លោកសួរទុកថា "អ្នកនោះ ក៏ពុំមែន អ្នកដទៃទៀត ក៏ពុំមែនដែរ" = ន ច សោ, ន ច អញ្ញោ ។ ដើម្បីពន្យល់យើងយកអ្វីជាឧទាហរណ៍? យើងយកមេអំបៅជាឧទាហរណ៍ទៅចុះ ។ មេអំបៅ ដើមឡើយជាស៊ុត តមកស៊ុតនេះទៅជាដង្កូវ តមកទៀតដង្កូវនេះបម្រើនក្នុងសំបុកវា ហើយទីបំផុត បានទៅជា "មេអំ-បៅ" ។ កម្មវិធីនេះ ជាកម្មវិធីធម្មតា កើតមានឡើងតាមដំណើរប្រក្រតីនៃជីវិតរបស់វា ។ សេចក្ដីពិត មេអំបៅនេះដូចគ្នាជាឯកលក្ខណ៍ដែរឬទេ? ទេ! ពុំដូចគ្នាជាឯកលក្ខណ៍ទេ តែក៏មិនផ្សេងគ្នាស្រឡះពីដង្កូវដែរ ។ សេចក្ដីនេះបញ្ជាក់ច្បាស់ថា "នេះគឺជាការហូរទៅនៃជីវិត" ដែលលោកប្រើពាក្យហៅថាសន្តតិ "តំណ" ។

ព្រះនាគសេនត្ថេរ បានដោះស្រាយប្រស្នានេះ ដោយលើកយកភ្លើងប្រទីបមកធ្វើជាឧទាហរណ៍ គឺប្រទីបដែលឆេះពេញមួយយប់ ។ ក្នុងករណីយ៍នេះ អណ្ដាតភ្លើងដើម ពុំមែនមានឯកលក្ខណ៍ដូចអណ្ដាតភ្លើងក្រោយទេ តែដោយអាស្រ័យភ្លើងប្រទីបនេះឯង ទើបពន្លឺភ្លើងឆេះក៏រហូតតទៅពេញមួយយប់ ។ សេចក្ដីនេះ មានឧបមេយ្យដូចសន្តតិ

នៃជីវិតដូច្នេះឯង គឺ សន្តតិ មួយអាស្រ័យដោយ សន្តតិ មួយទៀត ដែលមានមកខាងដើមនោះ ហើយបានជាមនុស្សសត្វ ចេះមានជីវិតរស់ នៅតរៀងរហូតទៅ ។

ពុទ្ធសាសនាបដិសេធអាត្មន៍=ព្រលឹង ដែលស្តីថាចេះអន្ទោលទៅ មក "សង្សារ" នេះហើយ បើដូច្នេះ តើមានអ្វីទៅក៏ ជាស្ព ឬបាទ ទ្រនាំបន្តជីវិតឲ្យទៅកើតទៀត ?

ឆ្លើយថា មាន សន្តតិ គឺតំណជីវិតដែលតគ្នាដឹកនេះ ជាការបន្ត ឲ្យមានជាតិគឺកំណើតនេះតទៅ ដោយតាមពលនៃកម្ម មិនបាច់មាន អាត្មន៍=ព្រលឹង ជាស្ព ឬជាបាទទ្រឲ្យបន្តទៅទៀតទេ ។ សេចក្តីនេះ បើគ្រាន់តែយើងលើកទុកពាក្យ អាត្មន៍=ព្រលឹង កុំនិយាយ ហើយលើក យកពាក្យ សន្តតិ=តំណជីវិតនេះ មកប្រើជំនួសវិញតែប៉ុណ្ណោះ យើង យល់បានភ្លាមទៅហើយ ឧទាហរណ៍ ដូចជាទារក បានទៅជាបុរស ចាំបាច់មានអ្វីជាស្ព ឬបាទទ្រ ? ពិតមែនតែឯកលក្ខណ៍មិនដូចគាសុទ្ធ សាធ តែក៏មិនផ្សេងគ្នាដាច់ស្រឡះដែរ ព្រោះថា កោសិកា ដែល បង្កើតជារូបកាយបុរសភាពនេះ ប្រែប្រួលទៅផ្សេងហើយ តែគឺអ្នកដដែល មិនគឺអ្នកដទៃទេ ។ ការប្រែប្រួលនៃ កោសិកា នេះ ពុំមែនចំពោះតែ រូបធម៌ទេ សូម្បីតែនាមធម៌ក៏ប្រែប្រួលដែរ តែការប្រែប្រួលរូបធម៌ មើល ឃើញជាក់ស្តែង ហើយរូបធម៌នេះឯងជាតួបុរស ដែលជាអ្នកទទួលខុសត្រូវ

ចំពោះកិច្ចការទាំងអស់ ដែលខ្លួនបានធ្វើ ក្នុងកាលខ្លួនទៅជាកុមារភាព នោះ ៗ

ពិតមែនហើយ មនុស្សសត្វ តែងតែបន្តការកើតរបស់ខ្លួន មានជីវិតរស់នៅ ដូចដែលធ្លាប់មានមកហើយ តែចំណុចសារវន្តក្រៃលែងគឺ សន្តតិ=តំណជីវិតតៗគ្នានេះ ពុំមែនជា អាត្មន៍=ព្រលឹង នោះទេ ឧបមា ដូចក្នុងអតីតជាតិ គេជាអ្នក "ក" ហើយមកក្នុងបច្ចុប្បន្នជាតិនេះ គេមកកើតជាអ្នក "ខ" តទៅក្នុងអនាគតជាតិទៀត គេនឹងបានទៅកើតជាអ្នក "ម" មួយទៀត ៗ ដូច្នេះ អ្នក "ខ" គឺជា សន្តតិត មកពីអ្នក "ក" ហើយអ្នក "ម" នឹងទៅជា សន្តតិ ដែលតមកពីអ្នក "ខ" ហើយតែងតែប្រព្រឹត្តតគ្នារហូតទៅ ៗ កាលបើអ្នក "ក" ឈ្មោះថាស្លាប់នោះ គឺរូបកាយជាយានរបស់គេ ដែលជាធាតុភាពខាងក្រៅ នៃថាមពលកម្មបែកធ្លាយសូន្យទៅ ហើយកាលណាបើអ្នក "ខ" ឈ្មោះថាកើតទៀតនុ៎ះ គឺរូបកាយជាយានថ្មីរបស់គេ ដែលជាធាតុភាពខាងក្រៅនៃថាមពលកម្មកើតឡើង ៗ ក្នុងដំណើរនេះ មានតែធម៌មួយទេដែលពៀសវាងពុំរួច គឺការប្រែប្រួលនៃរាងកាយ ដែលតែងតែប្រព្រឹត្តទៅ តាមធម្មតារបស់ធាតុ ដែលយើងហៅថា "ស្លាប់=មរណៈ" តែបន្តគឺការរស់នៅ ជាធម៌មើលមិនឃើញ មិនចេះបាត់បង់ទៅណាទេ ចេះតែបន្តការហូររបស់ខ្លួន ទៅជានិច្ចមិនដាច់ក្នុងខ្លួនឯង ដោយអំណាច

ជាមពលរបស់កម្ម មិនរបេះនៅគាំង មិនរបេះដាច់គ្នាទាញកកណ្តាលផ្លូវ ពោះជាមានសក់សត្រូវធំ គឺការស្លាប់មកកាត់កំដោយ ក៏បន្តជីវិតនេះ របេះ តែប្រព្រឹត្តទៅជាធម្មតា ហើយគេងយកធម្មារម្មណ៍ (កុសលអកុសល) ជាប់ទៅជាមួយខ្លួន ជាការម្មណ៍ដែលខ្លួនធ្លាប់បានទទួលមកអំពី អាយ-តនៈ (ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ) ។ យើងរស់នៅ បាន សន្សំកុសលអកុសលប៉ុន្មាន ស្លាប់ទៅកើតទៀត យកទៅតាំងអស់ តែជីវិតអតីត មិនមែនជាជីវិតបច្ចុប្បន្ន ឬអនាគតទេ ជីវិតអនាគត មិន មែនជាជីវិតបច្ចុប្បន្ន ឬអតីតទេ ជីវិតបច្ចុប្បន្ន មិនមែនជីវិតអតីត ឬអនា-គតទេ ។

ដូច្នេះ អ្នក "ខ" ត្រូវទទួល ឬរងអំពើកម្ម ឬក៏ទទួលខុសត្រូវ ចំពោះអំពើកម្មរបស់អ្នក "ក" ដែលខ្លួនឯងជាអ្នកមុនបានធ្វើនោះឬអ្វី ? អ្នក "ខ" ត្រូវទទួលតាំងអស់ តែពុំមែនជាត្ថុយគឺ វិញ្ញាណ=មនះ =ចិត្ត ជាអ្នកទទួល ឬរងអំពើកម្ម ឬក៏ទទួលខុសត្រូវចំពោះអំពើកម្ម ដូចទ្រឹស្តីអាត្មន=ព្រលឹង ជារបស់ពាហិរសាសនានោះទេ ។ ក្នុង ដំណើរនេះ ធម៌ដែលយើងមើលឃើញនោះ គឺភាពផ្សេងគ្នារវាងអ្នកទី មួយនិងអ្នកទីពីរ និងភាពកភាពទៅជាបុរសភាព មាន "វិញ្ញាណ= មនៈ=ចិត្ត" តៗ គ្នាដើរទៅតែប៉ុណ្ណោះ ។ ដទៃពីនេះ ក្នុងករណីយ៍ ដែលអ្នក "ខ" នឹកមិនឃើញកម្មរបស់ខ្លួនពីអតីត កាលដែលខ្លួននៅ

ជាអ្នក "ក" បានធ្វើហើយនោះ ។ ការនឹកមិនឃើញកម្លាំងនេះ ដោយហេតុតែមាន "ការស្លាប់=មរណៈ" ចូលមកកាត់ផ្ដាច់នៅចន្លោះពាក់កណ្ដាល ទើបបានជាអ្នក "ខ" នឹកជាតិខ្លួនពីអតីតមិនឃើញ ។

ចុះឯលក្ខណ៍ ឬហៅថា "ខ្លួន" ជាធម៌សារវន្តដាច់ខាតក្នុងការទទួលខុសត្រូវផ្នែកសីលធម៌ឬអ្វី? បើឆ្លើយឲ្យអស់ជើង ចម្លើយចំពោះសំនួរនេះ នឹងទុកជាធម៌សារវន្តដាច់ខាតក៏ទេដែរ ឧបមាថាមនុស្សម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ ហើយបំភ្លេចឧប្បត្តិហេតុនេះចោលអស់ទៅ តើអ្នកប្រព្រឹត្តបទឧក្រិដ្ឋនេះ នឹងត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋ ដែលខ្លួនធ្វើនេះដែរឬទេ ? បើយកច្បាប់តុលាការជាច្បាប់រដ្ឋមកប្រើ ពិតណាស់ការទាំងនេះ នឹងទៅជាអសារបង់ពុំខាន ព្រោះថា ឯកសារទាំងនេះគេបំបាត់ចោលអស់ទៅហើយ ។

ប៉ុន្តែ អ្វីទៅហ្ន៎ ជាវិធីដាក់ទណ្ឌកម្ម ចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនោះ? បើអ្នកប្រព្រឹត្តអំពើនេះ ធ្វើជាពុំដឹងបទឧក្រិដ្ឋរបស់ខ្លួននោះទៅហើយ ។ តើវិធីនេះឬ ជាវិធីយុត្តិធម៌នៅក្នុងលោកនេះ? បើច្បាប់យុត្តិធម៌ ព្រះអាទិទេពទៅក៏ សមនឹងអសារបង់បាន ព្រោះព្រះអាទិទេពជាអាជ្ញាកណ្ដាល ទទួលខុសត្រូវ ជាអ្នកប្រទានរង្វាន់ ឬដាក់ទណ្ឌកម្មចំពោះមនុស្សសត្វទៅ ។ តែបើតាមពុទ្ធសាសនា ពិភពលោកយើងនេះ មិនសមគួរនឹងកើតមានច្បាប់អយុត្តិធម៌បែបនេះទេ ។ សេចក្ដី

ពិត ក្រៅពីអាទិទេព ជាមហេស្វរមានអំណាចមហិមា នៅមានច្បាប់យុត្តិធម៌ ជាច្បាប់ធម្មជាតិ ពោលគឺច្បាប់កម្ម ជាច្បាប់ហេតុផលប្រព្រឹត្តទៅដោយឯកឯង មិនបាច់មានអ្នកជាអាជ្ញាកណ្ដាលមកជំនួសឡើយ ។

សេចក្ដីនេះ គួរសាធុជនទាំងឡាយយល់តាមហេតុផល ឧបមាថា មនុស្សម្នាក់ងងុយដេកខ្លាំង ហើយដេកកំពុងលក់ ស្រាប់តែមានការត្រូវក្រោកទាំងមមីងមមាំង ដើរចេញតាមបៀងផ្ទះ មនុស្សនេះដោយងងុយខ្លាំងពេក អាចភាំងស្មារតី ដើរធ្លាក់ពីបៀងផ្ទះបាក់ដៃបាក់ជើងពុំខាន តែគ្រោះថ្នាក់មនុស្សនេះ មិនជាធ្ងន់ណាស់ពេកទេ មិនដូចគ្រោះថ្នាក់អ្នកដេកលក់បណ្ដើរ ដើរបណ្ដើរនោះឡើយ ។ អ្នកដើរទាំងដេកលក់ ឬអ្នកបើកបររថយន្តទាំងដេកលក់ មានអន្តរាយធ្ងន់ណាស់ធ្ងន់ក្រៃលែង ព្រោះអ្នកទាំងពីរប្រភេទនេះ មិនដឹងខ្លួនថាខ្លួនដើរ ឬបររថយន្តទេ មុខជាធ្លាក់ពីបៀងផ្ទះ ឬបររថយន្តខុសផ្លូវ មានក្ដីអន្តរាយដល់ជីវិតពិតប្រាកដ ឬអាចទៅប៉ះអ្នកដទៃទៀត មានក្ដីអន្តរាយដល់ទៅស្លាប់ក៏សឹងមានដែរ ។ ដូច្នេះ ពុទ្ធសាសនិកជនមិនប្រមាទប្រុងប្រយ័ត្នខ្លួនជានិច្ច មិនព្រមដើរតាមបៀងផ្ទះ ឬបររថយន្តក្បែរជ្រោះជ្រៅទាំងដេកលក់នោះទេ ពេលដេកក្ដី ពេលភ្ញាក់ក្ដី មានសតិសម្បជញ្ញៈដាស់ខ្លួនជានិច្ច ជាការចៀសវាងគ្រោះថ្នាក់ ឈឺចាប់ផ្ទាល់ខ្លួន ឬប៉ះពាល់អ្នកដទៃដោយមិនដឹងខ្លួនទុកមុន ។

ក្នុងដំណើរជីវិតនេះ មនុស្សម្នាក់ៗមើលមិនឃើញកម្មរបស់ខ្លួនពីអតីតទេ ថាតើកម្មរបស់ខ្លួននេះនឹងត្រូវឲ្យផលពេលណា? ឬអ្នកណានឹងដឹងខ្លួនថា ខ្លួននឹងត្រូវទទួលរងគ្រោះថ្នាក់ ដោយសារអាជ្ញាច្បាប់យុត្តិធម៌របស់ខ្លួននោះ? ការចេះដឹង ឬការយល់ថា មានកម្មឲ្យផលអាក្រក់ ឬល្អ តាមយថាកម្មរបស់ខ្លួន ដែលខ្លួនចៀសពុំរួចនោះ នៅក្នុងវាលវដ្ដសង្សារដ៏ធំធេងនេះ មានហិតប្រយោជន៍ច្រើនណាស់ ហើយខំអប់រំបន្ទុំអាត្មាគ្រប់ពេលវេលា ទោះបានតិចក្ដី ទោះបានច្រើនក្ដី ៗ ការទូន្មានកាយវាចាចិត្តគ្រប់ពេលវេលា នេះជាលក្ខណ៍ពិសេសនៃពុទ្ធសាសនិកជនទូទៅ ក្នុងពិភពលោក ៗ

# បទទីប្រាំបួន

## កម្មនាំទៅទាប (ទុ គតិ) និងនាំទៅខ្ពស់ (សុគតិ)

និយាយថា កម្មមានអានុភាពនាំទៅកាន់ទីទាបគឺ ទុក្កតិ ឬនិយាយមួយបែបទៀតថា មនុស្សអាចវិលទៅកើតជាសត្វតិរច្ឆានបានដែរឬទេ ?

ឆ្លើយថា កម្មមានអានុភាពខ្លាំងមហិមាណាស់ អាចធ្វើឲ្យមានការពិសេសពិសាល ឥតមានអ្នកធ្វើត្រាប់តាមបានទេ ។ កុសលកម្ម នាំទៅកាន់ សុគតិ អកុសលកម្ម នាំទៅកាន់ ទុក្កតិ ។ មហាភូតរូប (Material form) គឺ ដី ទឹក ភ្លើង ខ្យល់ ដូចជារូបសត្វតិរច្ឆាន មនុស្ស ទេព្តា ដែលមានជីវិតរស់នៅតៗគ្នា (ជីវិតសន្តតិ) បានបង្ហាញឲ្យយើងឃើញជាក់ច្បាស់ ដូចយើងពោលមកហើយ សេចក្តីពិត ដោយអំណាចកម្ម គ្រាន់តែជាធាតុភាពកើតប្រាកដឡើង មើលឃើញបានតែមួយរំពេច ដូចថៃបណ្តើរកូនប៉ុណ្ណោះទេ ។ យានគឺរូបកាយបច្ចុប្បន្ននេះ ពុំមែនជាការវិវឌ្ឍន៍ទៅដដែល ចេញពីយានគឺរូបកាយពីអតីតទេ ប៉ុន្តែជាយានគឺរូបកាយ ដែលកើតមានតៗគ្នាមកពីអតីតកាលពិតប្រាកដ ដូចចរន្តអគ្គិសនី ដែលជាធាតុភាពខ្លួនឯងតៗគ្នា ហើយបានកើតទៅជារូប ក្តៅ ពន្លឺ ឬចលនា ។ ចរន្តអគ្គិសនីមួយៗ វិវឌ្ឍន៍តៗគ្នាពីចរន្ត

អត្តិសទ័មួយ ដោយមិនចាំបាច់មានសភាពដូចគ្នាដដែលយ៉ាងណា ថាមពលកម្មក៏កើតប្រាកដខ្លួនឯង បានកើតទៅជារូប សត្វតិរច្ឆាន មនុស្ស ទេព្តា តែរូបមួយៗ មិនមានអ្វីជាប់គ្នាពីរូបមួយទៅរូបមួយទៀតទេ យ៉ាងនោះដែរ ។ កម្ម[១] មានពលានុភាពនេះ គឺ សង្ខារ ចែករំលែកដែលកមហាភូតរូប "ដី ទឹក ភ្លើង ខ្យល់" ឲ្យកើតទៅជារូប មានប្រភេទផ្សេងៗគ្នាយ៉ាងពិសេសពិសាល មិនមានអ្វីអាចធ្វើត្រាប់តាមបាន ដែលលោកហៅថា "គ្រាដូនៃការវិវឌ្ឍន៍ទៅនៃសត្វទាំងឡាយ" ។

សេចក្តីទៅ ជាសេចក្តីពន្យល់ យើងកុំនិយាយថា "មនុស្ស ទេព្តា វិលត្រឡប់ទៅកើតជាកំណើតសត្វតិរច្ឆាន ហើយសត្វតិរច្ឆាន បានឡើងមកកើតជាកំណើតមនុស្សឬទេព្តាវិញ" ដូច្នេះ វាពិបាកស្តាប់ណាស់ ។ ឥឡូវនេះ យើងនិយាយយ៉ាងនេះ យើងនិយាយថា "ថាមពលកម្មមកប្រាកដភាព ជាកាយមនុស្ស ជាកាយទេព្តា ឬជាកាយសត្វតិរច្ឆាន" យ៉ាងនេះវិញ ងាយស្តាប់ ងាយយល់ ហើយមានហេតុផលប្រសើរជាង តាមផ្លូវបរមត្ថផង តាមផ្លូវវិទ្យាសាស្ត្រផង ។

ឥឡូវ យើងនិយាយដោយសន្មតទៅចុះថា ក្នុងដំណើរជីវិតដែលយើងកំពុងតែត្រាច់រង្គាត់ក្នុងវាលវដ្តសង្សារនេះ យើងបានប្រមូលយក

---

១-លទ្ធិតៅ របស់លោកឡៅត្សឺ មានសេចក្តីអធិប្បាយដូចកម្ម ដែលជាសង្ខារនេះដែរ។ តៅប្រសើរណាស់ ចេះធ្វើអ្វីៗឲ្យពិសេសប្លែក ឥតអ្នកណាធ្វើត្រាប់តាមបាន ។

ការបេះដឹង និងចំពោះវិជ្ជាច្រើនប្រការណាស់ ការយល់ត្រូវ "សម្មា-ទិដ្ឋិ" តម្រិះត្រូវ "សម្មាសង្កប្បៈ" វិចារណញ្ញាណល្អ ប្រាជ្ញាចៀវឈ្លាសវៃដោះអាថ៌ប្រស្នា ។ល។ បានទូន្មានកាយវាចាចិត្តរបស់ខ្លួនអប់រំបង្ហាត់ខ្លួនឯង ហើយបានសម្រេចគុណសម្បត្តិ និងចរិយាសម្បត្តិ ជាបុគ្គលប្រសើរមានរូបល្អ សម្ផស្សល្អ ចិត្តល្អ ។ល។ បានសិក្សាប្រវត្តិមហាបុរសក្នុងលោក មានប្រវត្តិអង្គព្រះសម្មាសម្ពុទ្ធជាដើម ហើយអប់រំបង្ហាត់ខ្លួន ឲ្យដើរទៅតាមមាគ៌ានៃមហាបុរសទាំងនេះ កើតបានជាអនុស្ស-យធម៌នៅក្នុងសន្តានចិត្ត ជាប់ជាមួយខ្លួនយើង ដូចជាគេសរសេរអក្សរនៅលើស្បែកសត្វ ។ ធម៌ទាំងនេះ មិនបេះបាត់បង់ទៅណាទេ យើងទៅណាទៅតាមយើង សូម្បីយើងស្លាប់ ក៏ទៅតាមយើងដែរ តាំងពីចនិយាយថ្មីក្នុងកាលដែលយើងនៅរស់នេះ ឬយើងយល់ថា អនុស្សយ-ធម៌ទាំងនេះ បើយើងដើរចេញពីផ្ទះទៅ វាមិនទៅតាមយើងទេ វាដេកនៅក្នុងផ្ទះយើង ដូចទ្រព្យសម្បត្តិឯទៀតមានមាសប្រាក់ជាដើមទៅឬ? សេចក្តីពិត ទ្រព្យដ៏ប្រសើរទាំងនេះ ជាសារទ្រព្យ ជា "របស់យើង" ទៅតាមយើងពិតប្រាកដ បានជាអង្គព្រះសម្ពុទ្ធឲ្យឈ្មោះធម៌ទាំងនេះថា អនុគាមិកធនៈ "ទ្រព្យប្រាកដស្មើដូចខ្លួនយើង" ហើយពុំមែនមានឫទ្ធិអានុភាពប៉ុណ្ណឹងទេ មានអានុភាពអាចជូនយើងឲ្យទៅកើតក្នុងភពតូច-ធំបានខ្ពង់ខ្ពស់ប្រសើរលើសទៅទៀត បានជាអង្គព្រះសម្ពុទ្ធឲ្យឈ្មោះធម៌

ទាំងនេះថា អនុគាមិកនិធិ “ទ្រព្យជូនយើងទៅទៀត” ។ ធម៌ទាំងនេះ លោកហៅថា វាសនា ឬបុណ្យបារមី ជាប់ជាមួយខ្លួនយើង យើងទៅណាទៅតាមប្រាកដ ដូចសម្លេងវិទ្យុ ឬខ្សែកាត់ដែលគេផ្សាយអ្វីតែបន្តិចក៏លេចឮចេញទាំងអស់ សម្លេងខ្លុយ ប៉ី ស្គរតូច-ធំ សម្លេងចម្រៀង ទាំងពីរោះទាំងមិនពីរោះ ចេញឮទាំងអស់ ជាមួយស្មើគ្នាមិនមុនមិនក្រោយទេ ។

តែបើយើងទៅជាសភាពបុថុជ្ជនភពណា អកុសលកម្មដែលយើងមិននឹកនាសោះនោះ តែងកើតមានភពនោះ យើងធ្លាប់បានឃើញធម៌អាក្រក់ទាំងឡាយ តែងតែកើតប្រាកដឡើង ជាធម៌ដែលគេពុំបានគិតទុកមុន ដោយពិសេស ក្នុងចំណោមបុគ្គលប្រសើរទាំងឡាយ ចុះដូចយើងជាមនុស្សសាមញ្ញ ម្តេចឡើយយើងនឹងមិនភ្លាត់ធ្វើអំពើអាក្រក់ច្រើនជាង ! ក្នុងករណីនេះ យើងមានគំនិតថា បុគ្គលប្រសើរម្ល៉េះ ពុំគួរឡើយនឹងប្រព្រឹត្តធ្វើអំពើផ្ទុយពីសីលធម៌ដូច្នេះទេ ។

តាមពិត អំពើធ្ងន់នេះ មិនមែនជាការចំឡែកទេ ព្រោះយើងធ្លាប់បានយល់អាថ៌កំបាំងអត្តភាពជាបុថុជ្ជនអស់ហើយ ឧទាហរណ៍ដូចព្រះទេវទត្ត ជាក្សត្រមួយព្រះអង្គប្រសើរក្នុងសាក្យត្រកូល បានបួសក្នុងសម្នាក់ពុទ្ធសាសនា បានសម្រេចឈានសមាបត្តិលោកិយ បុគ្គលប្រសើរម្ល៉ឹងៗហើយ នៅតែលុះក្នុងអំណាចធម៌ឥច្ឆា ព្យាយាមធ្វើឃាតកម្ម

ចំពោះអង្គព្រះសម្ពុទ្ធជាគ្រូរបស់ខ្លួន ៗ សមបើដែរ នេះហើយជាអំពើឧក្រិដ្ឋគ្រោះថ្នាក់នៃមនុស្សជាតិ ។

មួយទៀត មនុស្សម្នាក់ពីអតីត ពុំមែនសុទ្ធតែជាកស្តុតាងពិតនៃមនុស្សម្នាក់ក្នុងអនាគតទេ ព្រោះមនុស្សម្នាក់ ៗ បានប្រព្រឹត្តធ្វើកម្មថ្មី ៗ ថែមឡើងច្រើនទៀតពេលគឺ :

- ន័យមួយ យើងឥឡូវ ពិតជាយើងពីម្សិល ហើយយើងស្អែក ពិតជាយើងឥឡូវ ។

- ន័យមួយទៀត យើងឥឡូវ ពុំមែនជាយើងពីម្សិល ហើយ យើងស្អែក ពុំមែនជាយើងឥឡូវ ។

ដូចេះ អ្នកប្រព្រឹត្តធ្វើអំពើអាក្រក់ពីម្សិល អាចទៅជាអ្នកធ្វើល្អក្នុងថ្ងៃនេះ អាចត្រឡប់ទៅជាអ្នកធ្វើអំពើអាក្រក់ក្នុងថ្ងៃស្អែក ។ យើងវិនិច្ឆ័យខ្លួនយើង ដោយស្រួល និងដោយត្រឹមត្រូវបំផុត បានតែក្នុងបច្ចុប្បន្នកាលនេះទេ ។ ហើយយើងឥឡូវ យើងកំពុងសាបព្រោះពូជសម្រាប់អនាគតរបស់យើង ។ គ្រប់តែខណៈចិត្ត យើងធ្វើបាបកម្មណាមួយ ឈ្មោះថា យើងកំពុងកសាងឋាននរក ទុកសម្រាប់ឲ្យខ្លួនយើង យើងធ្វើបុញ្ញកម្មណាមួយ ឈ្មោះថាយើងកំពុងតែសាងឋានសួគ៌ទុកសម្រាប់ឲ្យខ្លួនយើង ។ តាមទស្សនវិជ្ជាពុទ្ធសាសនា កំណើតចុងក្រោយបំផុតរបស់យើង ផុតត្រឹមខណៈចិត្តចុងក្រោយបង្អស់ ។ នេះជាធម៌ដែលគួរ

ជីវ ហើយគួរកំណត់ទុកក្នុងជីវិត កុំបីភ្លេចរាល់ពេលវេលា ។ ក្នុងដំណើរជីវិតយើងដែលប្រព្រឹត្តទៅនេះ ខណៈចិត្តមួយ ៗ ដែលរលត់ទៅពុំមែនរលត់ទៅដោយឥតឲ្យផលអ្វីនោះទេ រលត់ទៅ បានប្រគល់នូវពលានុភាពរបស់ខ្លួនពោលគឺ អត្តសមណិធិ "ទ្រព្យប្រាកដស្មើដូចខ្លួនយើង" ឲ្យទៅខណៈចិត្តទៅទាំងអស់ ឯខណៈចិត្តទៅ ក៏ប្រគល់អត្ត-សមណិធិនេះ ឲ្យទៅខណៈចិត្តទៅទៀត តៗ គ្នារៀងទៅ ។ អ្វីទៅអត្តសមណិធិ ? គឺវិជ្ជាសម្បត្តិ "សម្បត្តិគឺការចេះដឹងទាំងអស់", ចរិ-យាសម្បត្តិ "សម្បត្តិគឺការទូន្មានរាចចិត្ត ដែលខ្លួនបានធ្វើទាំងអស់" ភាវសម្បត្តិ "សម្បត្តិគឺភាពខ្លួនជាទេវតា មនុស្ស សត្វ", លិង្គ-សម្បត្តិ "សម្បត្តិគឺជាភេទស្រ្តីបុរស" និយាយឲ្យខ្លី គឺបុណ្យបាបដែលយើងបានធ្វើទុកនេះឯង ។ ដោយហេតុនេះហើយបានជា បុគ្គលណាមួយបានវៀរចាកអកុសលធម៌ ហើយបានបំពេញកុសលច្រើន បុណ្យកុសលនេះជាអត្តសមណិធិ ជាធម៌ជាប់ជាមួយខ្លួនទៅ ហើយបានកើតទៅជាភាពខ្ពង់ខ្ពស់ ជាកល្យាណជន អរិយជនក្នុងដំណើរជីវិតតរៀងទៅរហូតបានសម្រេចភាពជាអរហន្តខីណាស្រព តាមវាសនាបារមីធម៌របស់ខ្លួន ៗ អត្តសមណិធិនេះ ជាធម៌ប្រសើរដូច្នេះ បានជាព្រះសម្ពុទ្ធត្រាស់ទូន្មានថា "ភិក្ខុទាំងឡាយ! អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ" ។

កម្មទាំងអស់ កុសលក្តី អកុសលក្តី ដែលបុគ្គលធ្វើហើយ ជា

"របស់ខ្លួន" មិនបេះសាបសូន្យបាត់ទេ ។ កម្មនេះ ជាតួសង្ខារធម៌ ជាធម៌តាក់តែងធ្វើឲ្យមានជាតិកំណើតទៀត ។ សង្ខារធម៌នេះ ជាធម៌ពិសេសពិសាលណាស់ នឹងពណ៌នាពុំបាន បេះស់ាង បេះធ្វើឲ្យពិសេស មិនមានអ្នកធ្វើត្រាប់តាមបានឡើយ ។

សេចក្តីពិត កុសលធម៌នាំទៅកាន់សុគតិ អកុសលធម៌នាំទៅកាន់ទុគ្គតិ ។ បុគ្គលដែលបានបំពេញកុសលធម៌ច្រើន តែក្នុងខណៈចិត្តចុងក្រោយគឺខណៈចុតិចិត្ត មានអកុសលចិត្តណាមួយកើតឡើង បុគ្គលនោះត្រូវទៅកាន់ទុគ្គតិ ប៉ុន្តែទៅទទួលផលអាក្រក់នេះមិនយូរទេ នឹងបានត្រឡប់ទៅកាន់សុគតិវិញឆាប់ ។ ព្រះនាង មល្លិកា ជាតាយិកាប្រសើរមួយព្រះអង្គ បានបំពេញកុសលច្រើន តែក្នុងពេលធ្វើមរណកាលគឺក្នុងខណៈចិត្តចុងក្រោយបំផុត ព្រះនាងមានព្រះចិន្តាជាអកុសល ទំរង់តទៅ ទ្រង់ទៅកាន់ទុគ្គតិ ។ ព្រះនាងសោយទុក្ខវេទនាត្រឹមតែ ៧ ថ្ងៃ ហើយព្រះនាងបានទៅកាន់សុគតិវិញ ដោយអំណាចកុសលកម្ម ដែលព្រះនាងបានសន្សំទុកមកច្រើនហើយ ។

និទានដូចព្រះនាង មល្លិកា នេះ មានហេតុផលត្រឹមត្រូវដែរឬទេ ? បើជាមនុស្សល្អ តែដោយមានឧប្បត្តិហេតុណាមួយដែលមិនបានដឹងមុនទៅសម្លាប់មនុស្សម្នាក់ មនុស្សនោះទុកជាមានទោស បទមនុស្ស-ឃាត ។ កុសលកម្មដែលមនុស្សនោះ បានធ្វើទុកពីអតីតកាលមិនបាត់បង់

ទៅណាទេ បិតនៅដដែល ហើយនឹងត្រូវឲ្យផលវិញពុំខាន ប៉ុន្តែដោយ កម្មបច្ចុប្បន្នជាអាសន្នកម្មមានកម្លាំង កុសលកម្មពីអតីតកាលទន់ខ្សោយ ទប់ទល់ពុំបាន បើកឱកាសអាសន្នកម្មឲ្យផលសិន ។ អ្នកប្រព្រឹត្តបទ មនុស្សឃាតនេះ ពេញចិត្តក្តី មិនពេញចិត្តក្តី ត្រូវតែទទួលផលគឺទៅ កាន់ទីបាបដែលជាហីនជាតិ "កំណើតបាប" ។ វិធីនេះសមរម្យដែរឬ ទេ ? វិធីនេះយុត្តិធម៌ហើយ គួរសាធុជនទាំងឡាយយល់ថា អកុសល-កម្មនេះឯង មានអានុភាពខ្លាំង អាចញ៉ាំងបុគ្គលប្រសើរបែបនេះ ឲ្យធ្លាក់ ទៅកាន់កំណើតបាបម្តងៗ បាន ។

ដើម្បីជាការងាយយល់ សូមសាធុជនទាំងឡាយស្តាប់និទាន ដូចសេចក្តីតទៅ :

ក្នុងពុទ្ធកាល មានព្រាហ្មណ៍ពីរនាក់ ម្នាក់ឈ្មោះបុណ្ណៈ ជាអ្នក ប្រតិបត្តិវត្តឆ្កែ "កុក្កុរវត្ត" ធ្វើគ្រាប់តាមទំនងជាឆ្កែ ម្នាក់ទៀត ឈ្មោះសេនិយៈ ជាអ្នកប្រតិបត្តិវត្តគោ "គោវត្ត" ធ្វើគ្រាប់តាមទំនង គោ ។ ទាំងពីរនាក់ ជជែកអួតជាក់គ្នា ពីវត្តប្រតិបត្តិរបស់ខ្លួនរៀងខ្លួនៗ ថ្ងៃមួយទាំងពីរនាក់ ចូលទៅគាល់អង្គព្រះសម្ពុទ្ធ ក្រាបទូលសួរអានិសង្ស វត្តប្រតិបត្តិរបស់ខ្លួន ដែលនឹងកើតមានទៅក្នុងអនាគតកាល ។ កាល នោះ ព្រះសម្ពុទ្ធត្រាស់ទេសនាថា :

"ក្នុងលោកនេះ មានមនុស្សកាន់វត្តឆ្កែ ទម្លាប់ខ្លួនដូចឆ្កែ ធ្វើចិត្ត

ដូចឆ្កែ កាន់ចរិយាដូចឆ្កែ ធ្វើអ្វីៗ ដូចឆ្កែសុទ្ធតែឆ្ពោះ ឥតល្អៀង ។ មនុស្សកាន់វត្តឆ្កែនេះ លុះបែកធ្លាយកាយធ្វើមរណកាលទៅ នឹងទៅកើតជាកំណើតសត្វឆ្កែក្នុងពពួកឆ្កែទាំងឡាយ ។ បើបុគ្គលណាមួយប្រកាន់ជឿថា "កាន់វត្តដូចឆ្កែនេះ ធ្វើតបធម៌ដូចឆ្កែ យល់ថាជីវិតឆ្កែប្រសើរ អាត្មាអញកាន់តាម នឹងបានទៅកើតជាទេវតា ក្នុងឋានសួគ៌ពិតប្រាកដ" បុគ្គលនោះឈ្មោះថា ជាអ្នកមិច្ឆាទិដ្ឋិ "អ្នកយល់ឃើញខុស" ។ បុគ្គលណាមួយ យល់ឃើញខុស ដូចបានពោលមកនេះ តថាគតពោលថា "អ្នកនោះនឹងទៅកាន់ទុគ្គតិ ក្នុងអនាគតកាលពិតប្រាកដ បើមិនទៅកើតឋាននរកទេ នឹងទៅកើតជាកំណើតសត្វតិរច្ឆានណាមួយពុំខានឡើយ" ។

ឯមនុស្សដែលពេញចិត្តកាន់តាមវត្តគោ "វត្តោ" ក៏មានគតិដូចមនុស្សកាន់វត្តឆ្កែ "សុនខវត្ត" ដែរ លុះបែកធ្លាយកាយបន្ទាប់ពីធ្វើមរណកាលទៅ នឹងទៅកើតជាកំណើតគោក្នុងពពួកគោទាំង-ឡាយ ។

បើកម្មមានពលានុភាពអាចនាំសត្វទៅកើតក្នុងសុគតិទីខ្ពង់ខ្ពស់បាន ផ្ទុយទៅវិញ កម្មនេះក៏មានពលានុភាពនាំសត្វទៅកើតក្នុងទុគ្គតិទីទាបថោកបានដែរ ។ នេះហើយដែលហៅថា "ត្រាជូនការវិវឌ្ឍន៍ទៅនៃសត្វលោកទាំងឡាយ" ។ ក្នុងខណៈសត្វតិរច្ឆានស្លាប់ គឺខណៈ

ចុតិចិត្ត បើមានកុសលចិត្តណាមួយកើតឡើង សត្វតិរច្ឆាននោះ នឹងវិលមកកើតជាកំណើតមនុស្សវិញ ។ ខណៈចិត្តចុងក្រោយនេះ មិនមានកំណត់ថាជាកុសល ឬអកុសលទេ ស្រេចហើយតែយថាកម្មកន្លងពេលនោះដូនកាលកុសលកម្មពីអតីតកាល ចូលមកឲ្យផល បើជាសត្វតិរច្ឆាន អារម្មណ៍ជាកុសលនេះ កើតឡើង នឹងដឹកនាំសត្វនោះឲ្យបានទៅកើតក្នុងសុគតិ មានកំណើតមនុស្សជាដើម ដូនកាលអកុសលកម្មពីអតីតកាលចូលមកឲ្យផល បើជាមនុស្ស ឬទេវតា អារម្មណ៍ជាអកុសលកើតឡើង នឹងដឹកនាំសត្វនោះឲ្យទៅកើតក្នុងទុគ្គតិវិញ ។ សេចក្ដីដូចពណ៌នាមកនេះ ជាច្បាប់ធម្មជាតិ ច្បាប់យុត្តិធម៌ដែលហៅថា "កម្ម" ប្រកបដោយចេតនា ដែលជាវិធីធ្វើឲ្យមានកំណើត គឺជាតិទៀតទៅក្នុងអនាគត ។

# និគមនវចន៍

ឥឡូវ យើងមិនដឹងថា "យើងមកពីណា យើងកំពុងទៅឯណា ហើយយើងនឹងទៅពេលណា" ទេ ។ ការពិត យើងដឹងត្រឹមតែថា "យើងត្រូវធ្វើដំណើរតទៅទៀត" ។ ពេលយើងទៅ ទ្រព្យសម្បត្តិ គ្រួសារញាតិមិត្រ ទាំងអស់របស់យើង មិនទៅតាមយើងទេ សូម្បីតែអត្តភាពដែលយើងប្រកាន់ថាជារបស់ខ្លួនយើង ក៏មិនទៅតាមខ្លួនយើងដែរ ។ អត្តភាពគឺរាងកាយ កើតបានមកពីការផ្សំធាតុ ត្រូវវិលទៅកាន់ធាតុដើមវិញ ។ ទ្រព្យគឺ ល្អ អាក្រក់ ជា អង្គសមឆិជិ ទៅជាមួយយើង ជូនយើងទៅ ដូចពុទ្ធភាសិតថា "រូបកាយ ចេះគ្រាំគ្រា តែនាមគោត្ត មិនចេះគ្រាំគ្រាទេ ចេះរស់នៅតទៅ" ។

សព្វថ្ងៃ យើងគ្រប់គ្នា កំពុងត្រាច់រង្គាត់ទៅ លិចអណ្តែត ។ កណ្តាលមហាសាគរប្រកបដោយខ្យល់ព្យុះ ហើយលេចរលចូលព្រៃគឺវដ្តសង្សារ ចេះតែរសាត់ទៅតាមយថាកម្មរបស់យើង មិនដឹងជាទៅកើតជាអ្វី ? ជាមនុស្ស ទេវតា ឬជាសត្វតិរច្ឆាន ? យើងកើតមកជួបជុំគ្នា ជាមាតាបិតា បងប្អូនកូនចៅ ញាតិមិត្រ កំពុងរស់នៅជួបជុំរហាន់ ហើយស្លាប់ព្រាត់ប្រាសចាកចោលគ្នាទៅ ជាមនុស្សកំព្រាទៅតែម្នាក់ឯង ដូចចោរជើងទាំងឡាយដែលដើរមកពីទិសានុទិស អស់

កម្លាំងណាស់ ឃើញដើមឈើមានម្លប់ត្រជាក់ស្រួល ចូលជ្រកសម្រាក កម្លាំង មានកម្លាំងគ្រាន់បើ កំពុងតែជួបជុំគ្នារហង់ លាក៏គ្នាដើរចេញទៅ ជួបគ្នាហើយបែកចេញទៅ បែកគ្នាហើយជួបគ្នាទៀត មិនស្គាល់គ្នាសោះ ៗ តាមពិត យើងធ្លាប់ជួបគ្នា ធ្លាប់ជាបិតា ធ្លាប់ជាមាតា ធ្លាប់ជាបងប្អូនប្រុសស្រី ធ្លាប់ជាកូនចៅ ធ្លាប់ជាញាតិមិត្រ ក្នុងពេលដែលយើងត្រាច់រង្គាត់នៅក្នុងវាលវែង គឺវដ្តសង្សារនេះ ៗ សេចក្តីនេះព្រះសម្ពុទ្ធត្រាស់ថា[1] ៗ

« បើបុគ្គលកាត់ស្មៅ ឈើធំ ឈើតូច ក្នុងប្រទេសទាំងមូល ( ឥណ្ឌា ) ហើយប្រមូលមកគរទុកជាគំនរធំ ៗ ហើយសន្មតទុកថា “គំនរនេះ ទុកជាមាតា គំនរនេះ ទុកជាបិតា គំនរនេះទុកជាបងប្អូន ៗល ៗ កាប់ស្មៅ កាប់ឈើអស់មួយប្រទេសនេះ ស្មៅឈើនោះ ៗ នឹងអស់ទៅ នៅតែមិនអស់មាតាបិតាបងប្អូនខ្លួនទេ ៗ

« បើបុគ្គលសូនមហាប្រឹថពីធំនេះ ជាគុលិកាមួយដុំ ៗ ឲ្យមានទំហំប៉ុនផ្លែកោឡា (ក្រចៅ ?) ហើយសន្មតទុកថា គុលិកានេះជាមាតា គុលិកានេះជាបិតា គុលិកានេះជាបងប្អូន គុលិកានេះជាជីដូនជីតា មហាប្រឹថពីនេះនឹងអស់ទៅ មាតាបិតាជីដូនជីតា ៗល ៗ ដែលធ្លាប់កើតជួបគ្នា នៅតែមិនទាន់អស់ទេ ៗ

---

១ សុត្តន្តបិដក ភាគ ៣២ សំយុត្តនិកាយ អនមតសំយុត្តៈ ទំព័រ ៧៩ . . . ៗ

ក្នុងពេលដែលយើងកំពុងតែត្រាច់រង្គាត់ ក្នុងវាលវែងវដ្តសង្សារនេះ យើងធ្លាប់បានមកកើតជួបគ្នា រស់នៅជាមួយគ្នា រួមសុខរួមទុក្ខជាមួយគ្នា អស់កាលយូរអង្វែងណាស់ ៗ ដោយទ្រង់បានជ្រាប ដំណើរនេះច្បាស់ ទើបទ្រង់ត្រាស់ថា :

"ជីវិតសព្វសត្វច្រើនអសង្ខេយ្យ រាប់មិនអស់ទេ ទុក្ខវេទនាកើតឡើងច្រើនណាស់ដែរ ៗ ឆ្អឹងទាំងឡាយរបស់មនុស្សសត្វម្នាក់ ៗ ដែលកើតហើយស្លាប់ទៅវិញ បើនឹងយកមកគរជាគំនរមួយយ៉ាងធំ បានប៉ុនភ្នំវិបុល (១) នៅក្រុងរាជគ្រឹះ ,

"យូរលង់ណាស់មកហើយ ! សត្វទាំងឡាយដែលសោកយំយែករង់ទុក្ខវេទនា ព្រោះតែស្លាប់មាតាបិតា ជីដូនជីតា បងប្អូនប្រុសស្រី ប្តីប្រពន្ធ ហើយក្នុងពេលយំយែកសោយសោកនោះ សត្វទាំងឡាយបានបង្ហូរទឹកភ្នែក ឲ្យហូរអស់ទៅច្រើនណាស់ ច្រើនសម្បើមជាងមហាសាគរទាំងបួនទៅទៀត ,

"យូរលង់ណាស់មកហើយ ! ឈាមទាំងឡាយដែលហូរចេញពីកាយ ដោយការដាច់ក្បាល ដៃជើង ខ្លួនប្រាណ កាលដែលសត្វទាំងឡាយបានកើតជាមនុស្ស គោ ក្របី ចៀម ពពែ ៗលៗ ហើយគេចាប់

---

១ ភ្នំនេះ ប៉ុនភ្នំបូកគោ ។

បងវាយដំកាប់សម្លាប់ ៗ ឈាមទាំងឡាយនេះ ច្រើនណាស់ ច្រើនក្រៃលែង ច្រើនសម្បើមអស្ចារ្យជាងមហាសាគរទាំងបួនទៅទៀត " ។

សព្វសត្វទាំងឡាយ ដែលបានរងទល់ទុក្ខវេទនា រងការុណកម្ម រងគ្រោះកាចចង្រៃ ទល់ទុក្ខវេទនាក្រៃលែង ស្លាប់ហើយកើត កើតហើយស្លាប់ បំពេញផ្លូវខ្មោច ឲ្យពាសពេញក្រឡាមហាប្រឹថពីកង់វាលវែងវដ្ដសង្សារ អស់កាលយូរអង្វែងសម្បើមយ៉ាងនេះ គួរតែកុំបណ្ដែតបណ្ដោយខ្លួនឲ្យរីករាយសប្បាយ ភ្លើតភ្លើនហួសពេក នៅក្នុងលោកដ៏គួរខ្លាចនេះ គួរខំប្រឹងប្រែងធ្វើការជាប្រយោជន៍ ដើម្បីរំដោះខ្លួនរួចចាកទុក្ខ មុខគួរភ័យខ្លាចទាំងអស់នេះ ដោយវិរិយភាពដ៏មុឺងម៉ាត់ ។

ពុទ្ធសាសនាជាជម្រកក្សេមក្សាន្ត ពុទ្ធោវាទជាឧបាយរំដោះទុក្ខ ជាផ្លូវត្រង់ទៅកាន់មោក្ខធម៌ ជាមាគ៌ាដ៏ប្រសើរដឹកនាំសត្វ ជាធម៌ស្រោចស្រង់ ដូចសំពៅកេត្រានាំសត្វទៅកាន់ត្រើយអមតមហានិព្វាន ។ ធម៌ដែលព្រះមានព្រះភាគសម្ដែងដោយប្រពៃនេះ គឺ អដ្ឋង្គិកមគ្គ មាគ៌ាប្រសើរប្រកបដោយអង្គ ៨ ប្រការ ដែលរួមខ្លីមកត្រឹមតែ ៣ ម៉ាត់គឺ

ក- សីល សីល ៥ សីល ៨ សម្រាប់ខ្លួនខាងកាយវាចា ទុកជាផែនដីសម្រាប់ទ្រសត្វ ។ សត្វដែលមានសីលជាផែនដីទ្រហើយ អាចធ្វើអ្វីបានទាំងអស់ ឈរលើផែនដីគឺសីល កាប់ឆ្ការធម៌ជាសឹកសត្រូវពោលគឺកិលេស ។ សីលជាលម្អមនុស្ស មនុស្សមានសីលជាគ្រឿង

អលង្ការ សីលជាទីស្រឡាញ់ពេញចិត្តសត្វទាំងឡាយ សីលជាគ្រឿងក្រអូបអប់សព្វសត្វឲ្យមានក្លិនក្រអូប ធ្វើមនុស្សឲ្យមានតម្លៃ ហើយឲ្យក្រអូបប្រាសខ្យល់ ។ លោកមនុស្ស បើមានអរិយធម៌ជាលម្អរបស់ខ្លួនហើយ នឹងបានជាទីសុខក្សេមក្សាន្ត និរទុក្ខនិរភ័យសម្រាប់មនុស្សលោកទូទៅ ។

ខ- សមាធិ ជាធម៌ទូន្មានចិត្ត ធ្វើចិត្តឲ្យបរិសុទ្ធផុតនីវរណធម៌ ។ ចិត្តដែលគេទូន្មានល្អហើយ នឹងនាំសេចក្ដីសុខមកប្រគល់ឲ្យ ។ បើចិត្តមិនតាំងនៅជាសមាធិទេ ចិត្តមិនបញ្ចេញអានុភាពចិត្តមកទេ ចិត្តប្រសើរគឺចិត្តសមាធិ ចិត្តមិនមានទំនប់នីវរណធម៌ ចិត្តនេះហើយ ដែលអាចឲ្យសម្រេចប្រយោជន៍គ្រប់ប្រការ បើនឹងមើលអ្វី មើលឃើញច្បាស់តាមពិត ដូចពុទ្ធភាសិតសម្ដែងទុកថា

"ភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរចម្រើនសមាធិចិត្ត បើបានធ្វើចិត្តឲ្យជាសមាធិហើយ មើលអ្វី មើលឃើញច្បាស់ ដូចបុគ្គលអង្គុយនៅមាត់សមុទ្រ មើលកាត់ទឹកឃើញហ្វូងមច្ឆាគ្រប់ពណ៌ ឃើញខ្យងខ្ចៅគ្រប់ពណ៌ ច្បាស់លាស់ពិតទៅតាមពិត ជាយថាភូតទស្សនញ្ញាណ ។

គ- បញ្ញា ប្រសើរបំផុត ។ បញ្ញាជាព្រះខ័នពេជ្រអាចកាត់អាសវធម៌ល្អិតសុខុមបាន ។ សេចក្ដីប្រាថ្នាមិនចេះស្កប់គឺ តណ្ហា ដែលមានអវិជ្ជាជាគ្រឹះមាំនេះ មានតែបញ្ញាទេ ដែលអាចកាត់ឲ្យដាច់ជាសមុច្ឆេទ-

បហានបាន ៗ បើបញ្ញាកាត់តណ្ហាជាសមុច្ឆេទបហានហើយ កម្មពុំមែនជាចេតនាកម្ម "កម្មមិនមានចេតនា" ទេ ទៅជា កម្មក្ខយកម្មក្ស័យ ឬជា តណ្ហាក្ខយ "តណ្ហាក្ស័យ" ៗ តណ្ហាក្ស័យហើយ កម្មមិនមានថាមពលឲ្យផលជាវិបាក គឺមិនមានវិបាកជាបុណ្យជាបាបឡើយ ៗ កម្ម-"អំពើ" កាយកម្មក្តី វចីកម្មក្តី មនោកម្មក្តី ទៅជាកិរិយា "ធ្វើក៏ធ្វើមិនបានផល" ព្រោះចិត្តអស់ថាមពលកម្មហើយ ដូចអគ្គិសនី បើអស់ថាមពល (Energy) ហើយ ចរន្តអគ្គិសនី ត្រូវឈប់ឈឹង មានឧបមាយ៉ាងណា មានឧបមេយ្យដូចកម្ម បើអស់ថាមពលកម្មហើយ កម្មមានតែជាកិរិយា ហៅថា "កិរិយាចិត្ត" ឈប់ឈឹងតែប៉ុណ្ណោះ ៗ កិរិយាចិត្តនេះ ជាចិត្តព្រះអរហន្តាខីណាស្រពទាំងឡាយ មានអង្គព្រះសម្មាសម្ពុទ្ធជាដើម ៗ កិច្ចដែលត្រូវធ្វើតទៅទៀតទាំងអស់ មិនមានទៀតទេ ចប់ប៉ុណ្ណោះឯង ៗ

សូមសព្វសត្វទាំងឡាយបានក្តីសុខគ្រប់គ្នា

-ចប់-

# ធម្មទេសនាផ្សាយតាមវិទ្យុជាតិ :

## យសោភិវឌ្ឍនកថា

ព្រះសាសនមុនី គិម - ទូរ រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាព សូមលើកយកពុទ្ធភាសិតមួយគាថាដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្ដែង ប្រោសពុទ្ធបរិស័ទទាំងឡាយ ក្នុងសម័យនោះ គឺក្នុងសម័យដែលព្រះអង្គទ្រង់គង់នៅឡើយ រហូតដល់សម័យបច្ចុប្បន្ននេះ ឃើញថា ពុទ្ធភាសិតនេះ មានអាយុតាំងនៅអស់រយៈកាលជាង ២៥ សតវត្សរ៍កន្លងទៅហើយ ។ ពុទ្ធភាសិតនេះ ដែលក្រុមព្រះសង្គីតិកាចារ្យ បានរៀបរៀងទុកក្នុងបិដកផ្នែកខាងសុត្តន្តបិដក គម្ពីរខុទ្ទកនិកាយ ត្រង់ធម្មបទថា : ។

ឧដ្ឋានវតោ សតីមតោ
សុចិកម្មស្ស និសម្មការិនោ
សញ្ញតស្ស ច ធម្មជីវិនោ
អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ប្រែថា យសតែងកើតកើនចំរើនជានិច្ចដល់បុគ្គលអ្នកមានព្យាយាម អ្នកមានស្មារតី អ្នកមានការងារស្អាតស្អំ អ្នកមានការពិចារណាជាមុន

ហើយទើបធ្វើ អ្នកសង្រួម អ្នករស់នៅតាមគន្លងធម៌ អ្នកមិនប្រមាទ ។

ពុទ្ធភាសិតដែលបានប្រែមកនេះ ឃើញថា ជាសេចក្តីសង្ខេបខ្លីពេក ពុំអាចនឹងស្តាប់សេចក្តីឲ្យបានចូលចិត្តគ្រប់គ្រាន់នៅឡើយ ។ ដោយហេតុនេះ សូមលើកយកពុទ្ធភាសិតខាងលើនេះ មួយបទម្តង ៗ មកធ្វើអត្ថាធិប្បាយពង្រីកសេចក្តី ឲ្យបានទូលំទូលាយតាមន័យក្នុងអដ្ឋកថាផ្សេងៗ ដើម្បីជូនជាសណ្តាប់នៃអស់លោកអ្នកសប្បុរសពុទ្ធបរិស័ទទាំងឡាយ ដូចតទៅនេះ :

ត្រង់ព្រះពុទ្ធដីកាថា ឧដ្ឋានវតោ ដែលប្រែថា អ្នកមានព្យា-យាម នោះបានសេចក្តីថា អ្នកដែលមានគំនិតយល់ឃើញនូវកិច្ចការណាមួយ ទោះតូច-ធំ ធ្ងន់-ស្រាល យ៉ាងណាក៏ដោយ ដែលជាការចាំបាច់ ឬជាការមានប្រយោជន៍ ក៏តាំងផ្គងចិត្តប្រារព្ធធ្វើកិច្ចការនោះដោយឥតមាននឿយណាយ ធុញទ្រាន់ ឬរាថយក្រោយហើយបោះបង់ចោលកិច្ចការនោះឡើយ តាំងចិត្តតស៊ូមិនរួញរា ដរាបទាល់តែញ៉ាំងកិច្ចការនោះឲ្យបានសម្រេចចប់ចុងចប់ដើម ។ សេចក្តីតស៊ូនេះ គួរយកតម្រាប់ដូចឫសនៃរុក្ខជាតិទាំងឡាយ មានឫសពោធិ៍និងឫសជ្រៃជាដើម, ធម្មតាឫសឈើខាងចុងទន់ខ្ចីល្អក់ បើគេចាប់យកចុងឫសនោះមកច្របាច់ដោយចុងម្រាមដៃ វាក៏បែកបាក់ល្អិតខ្ទេចទៅជាទឹក ជាធម្មជាតិផុយសោះទេ ប៉ុន្តែដោយអំណាចកម្លាំងនៃសេចក្តីព្យាយាមរបស់ឫសឈើ ដែលវាផុះលូតទៅ

មុះសន្ទើមៗ បន្តិចម្តងៗ មិនព្រមថយក្រោយសោះនោះ រាមានឥទ្ធិ-ពល អាចជ្រៀតជ្រែកបំបែកជុំថ្ម ឬជុំឥដ្ឋជាដើមដែលនៅពីមុខរាបានដោយងាយ យ៉ាងណាមិញ, មនុស្សម្នាក់ៗដែលមានគំនិតយល់ឃើញថា ការណាមានប្រយោជន៍ដល់ខ្លួន ឬដល់ប្រទេសជាតិ ក៏តាំងឆន្ទៈនិងសេចក្តីព្យាយាមដ៏មាំ ប្រឹងធ្វើមិនរាថយក្រោយ ឬមិនទម្លាក់ចោលទេ ការនោះសុទ្ធតែបានសម្រេចដល់នូវទីដៅរបស់ខ្លួនបានទាំងអស់ ទោះការនោះធំតូចធ្ងន់ស្រាល តិចច្រើនយ៉ាងណាក៏ដោយ ឥតមានអ្វីមកជាឧបសគ្គពាំងបានឡើយ ក៏ដូចគ្នានោះដែរ ។ ឧទាហរណ៍ ដូចការសិក្សាវិជ្ជាផ្សេងៗ ទោះបីវិជ្ជាខាងសាសនា ដូចគន្ធធុរៈ គឺបរិយត្តិព្រះត្រៃបិដកក្តី វិបស្សនាធុរៈក្តី ឬវិជ្ជាខាងផ្លូវលោក មានអក្សរសាស្រ្តជាតិខ្លួន ឬអក្សរសាស្រ្តជាតិបរទេសជាដើមក្តី សូម្បីវិជ្ជាទាំងនោះ ដែលខ្លួនមិនធ្លាប់ដែលបានជួបប្រទះសោះទេ ប៉ុន្តែបើមានឆន្ទៈ គឺចំណង់និងសេចក្តីព្យាយាមដ៏មាំចូលសិក្សាហើយ មិនយូរមិនឆាប់នឹងបានសម្រេចដល់ទីបំផុតនៃវិជ្ជាដែលខ្លួនប្រាថ្នានោះពុំខានឡើយ ។ សមដូចព្រះពុទ្ធ-ដីកាដែលព្រះអង្គទ្រង់សម្តែងថា វីរិយេន ទុក្ខមច្ចេតិ គេធ្លងនូវទុក្ខទោសគ្រោះថ្នាក់សេចក្តីលំបាកគ្រប់យ៉ាងក្នុងលោកនេះ និងក្នុងលោកខាងមុខទៅបាន ដោយសារតែវីរិយៈ គឺសេចក្តីព្យាយាមនេះឯង ។

តាមតែកិច្ចការអ្វីក៏ដោយ បើមានតែឆន្ទៈប្រាថ្នាចង់បានចំណេះ ចង់បាន

ទ្រព្យសម្បត្តិ ចង់បានសេចក្តីចំរើនរុងរឿង ប៉ុន្តែគ្មានសេចក្តីព្យាយាមតស៊ូធ្វើការនោះជាជំនួយផងទេ ឆន្ទៈគឺសេចក្តីប្រាថ្នាចង់បាននោះរមែងតែមិនបានសម្រេចប្រយោជន៍ទាំងអស់ ។

ដូចក្នុងសម័យសព្វថ្ងៃនេះ ប្រទេសកម្ពុជាយើងកំពុងកើតអសន្តិសុខពាសពេញទាំងប្រទេស ដោយមានពួកទមិឡជាសត្រូវឈ្លានពានចូលមកបង្កបង្កើតអសន្តិសុខបំផ្លិចបំផ្លាញជីវិតមនុស្ស សម្បត្តិជាតិ ព្រមទាំងព្រះពុទ្ធសាសនាផង; បើយ៉ាងនេះ តើជនជាតិយើងជាពុទ្ធសាសនិកអ្នកកាន់ព្រះពុទ្ធសាសនា ឱបដៃឈរមើលបណ្តោយឲ្យសត្រូវបំផ្លាញចោលទទេៗទៅឬ ? លទ្ធិរបស់សត្រូវទាំងនោះ កាលបើវាចូលមកបំផ្លិចបំផ្លាញប្រទេសយើង ធ្វើឲ្យនៅក្នុងអំណាចកណ្តាប់ដៃរបស់វាហើយ ព្រះពុទ្ធសាសនាប្រាកដជានឹងបាត់សូន្យឈឹងពុំខានឡើយ ព្រោះលទ្ធិរបស់សត្រូវទឹងព្រះពុទ្ធសាសនា ព្រោះហេតុនោះ យើងជាជាតិខ្មែរអ្នកកាន់ព្រះពុទ្ធសាសនាត្រូវតែភ្ញាក់រឭកគ្រប់គ្នាឡើង បញ្ចេញសាមគ្គីព្រមព្រៀងគ្នារួបរួមជាមួយនឹងរដ្ឋាភិបាលក្រោបស្រង់ជាតិ ដើម្បីព្យាយាមតស៊ូកម្ចាត់ពួកសត្រូវទាំងនោះឲ្យអស់ពីប្រទេស ទើបព្រះពុទ្ធសាសនានឹងបានគង់វង្សជាស្ថាពរតទៅ ។

ត្រង់ព្រះពុទ្ធដីកាថា សតិមតោ ដែលប្រែថា អ្នកមានស្មារតីនោះ មកពីសព្ទបាលីដើមថា សតិមា ឬ សតិមន្តុ ប្រែថា អ្នកមាន

សេចក្ដីនឹកឃើញ ចាំបាន រលឹកបាន ប្រុងប្រយ័ត្នមិនឲ្យភ្លេចចំពោះពាក្យសម្ដីឬកិច្ចការណាទីមួយដែលបាននិយាយរួចមកហើយ បានធ្វើរួចហើយ នៅតែនឹកឃើញ ចាំបាន រលឹកបាន ដោយសព្វគ្រប់ មិនភ្លេច ទើបហៅថាអ្នកមានស្មារតី ឬអ្នកមានសតិ ។ សតិនេះជាគូនឹង សម្បជញ្ញៈ ធម៌ទាំងពីរនេះអាស្រ័យទាក់ទងគ្នាប្រព្រឹត្តទៅជាមួយគ្នា នឹងបែកចេញដោយឡែកពីគ្នាពុំបាន, ព្រោះសតិមាននាទីឲ្យរលឹកនឹកឃើញជាមុនក្នុងវេលានឹងធ្វើ នឹងនិយាយ នឹងគិតនូវអ្វីៗទាំងអស់, សម្បជញ្ញៈប្រែថា ការដឹងខ្លួន គឺដឹងខ្លួនក្នុងវេលាកំពុងធ្វើ កំពុងនិយាយ កំពុងគិត មិនឲ្យភ្លាំងភ្លាត គឺមិនបណ្ដោយចិត្តឲ្យគិតៈភ្លើតភ្លើនទៅក្នុងអារម្មណ៍ផ្សេងៗ បុគ្គលដែលប្រារព្ធធ្វើអ្វីៗ ហើយភ្លាំងភ្លាត់ និយាយភ្លាត់ គិតភ្លាត់ គឺពី-ព្រោះតែគ្មានសតិសម្បជញ្ញៈគ្រប់គ្រាន់, ព្រោះហេតុនោះ សតិសម្បជញ្ញៈនេះ ទើបជាធម៌សំខាន់បំផុត ឬជាធម៌មានឧបការៈច្រើនបំផុត អាចធ្វើបុគ្គលឲ្យតាំងខ្លួននៅនឹងជំហរខ្ជាប់ខ្ជួនរហូតទៅបាន, បើប្រាសចាកសតិសម្បជញ្ញៈហើយ សេចក្ដីអន្ដរាយគ្រប់យ៉ាងក៏នឹងកើតឡើងគ្រប់វេលា សេចក្ដីល្អដទៃៗដែលមានក្នុងខ្លួន ក៏នឹងវិនាសបាត់បង់សាបសូន្យអស់ទៅ ប្រៀបដូចផ្ទះដែលបើកទ្វារចំហរចោលក្នុងវេលាយប់ ក៏ជាឱកាសឲ្យចោរចូលទៅលួចយករបស់ទ្រព្យបាន ។ សតិសម្ប-ជញ្ញៈនេះ ត្រូវឲ្យមានគ្រប់ឥរិយាបថ ដូចការឈានជើងដើរទៅមុខ ក៏

ដឹងខ្លួនថា អាត្មាអញឈានដើរទៅមុខ, ឈានដើរថយក្រោយ ក៏ដឹងខ្លួនថា អាត្មាអញឈានដើរថយក្រោយ, ឈរក៏ដឹងខ្លួនថាឈរ អង្គុយក៏ដឹងខ្លួនថាអង្គុយ, ដេកក៏ដឹងខ្លួនថាដេក, ធ្វើការអ្វីក៏ដឹងខ្លួនថាធ្វើការនោះ ទើបហៅថា អ្នកបរិបូណ៌ដោយ សតិសម្បជញ្ញៈ

ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ យើងម្នាក់ៗត្រូវឲ្យមាន សតិសម្បជញ្ញៈ នឹកគិតពិចារណា ឲ្យដឹងខ្លួនជានិច្ចថា សត្រូវដែលឈ្លានពាន ចូលមកបង្កបង្កើតអសន្តិសុខពាសពេញ ក្នុងប្រទេសយើងសព្វថ្ងៃនេះ តើសត្រូវទាំងនោះវាជាជាតិអ្វី? ឆសត្រូវទាំងនោះ វាជាជាតិបរទេស គឺមិនមែនជាជាតិខ្មែរយើងទេតើ, ពួកវានាំគ្នាកាន់អាវុធចូលមកសម្លុតគម្រាម កាប់សម្លាប់ជនជាតិខ្មែរ ដណ្តើមយកទឹកដី របស់ខ្មែរយើង ទៅធ្វើជាទឹកដីរបស់វាវិញ, មិនតែប៉ុណ្ណោះ វាបំផ្លាញបំបាត់ព្រះពុទ្ធសាសនាដែលជាទីគោរពកាន់អានរបស់ខ្មែរយើង ពីព្រោះព្រះពុទ្ធសាសនាជាសត្រូវនឹងលទ្ធិរបស់គេ, បើដូច្នេះ យើងត្រូវឲ្យមាន សតិសម្បជញ្ញៈ នឹកគិតពិ-ចារណាឲ្យដឹងខ្លួនច្បាស់ថា ខ្លួនយើងជាជាតិខ្មែរ រស់នៅលើទឹកដីខ្មែរ ពួកអ្នករដ្ឋការទាំងអស់ តាំងពីរដ្ឋាភិបាល រហូតចុះមកដល់អភិបាលខេត្ត អភិបាលស្រុក ចៅតំបន់ ចៅសង្កាត់និងកងទ័ព សុទ្ធតែជាជាតិខ្មែរទាំងអស់ បើយ៉ាងនេះ យើងត្រូវឲ្យយល់ច្បាស់ទៀតថា ជាតិខ្មែរ ទើបស្រឡាញ់ជាតិខ្មែរ ជាតិខ្មែរមិនមែនស្រឡាញ់ជាតិបរទេស

លើសពីជាតិខ្មែរទេ, ឯជាតិបរទេសគេស្រឡាញ់ជាតិរបស់គេ គេមិនស្រឡាញ់ជាតិខ្មែរលើសពីជាតិគេនោះទេ ។ ដោយហេតុនេះ យើងជាជាតិខ្មែរ ដែលធ្លាប់មានសទ្ធាជឿ កាន់ព្រះពុទ្ធសាសនាអស់កាលជាយូរអង្វែងមកហើយ កុំទៅជឿសេចក្ដីឃោសនាកុហកបញ្ឆោតបោកប្រាស់របស់ជនបរទេសដែលវាថាដូច្នេះដូច្នោះនោះឡើយ គឺសុទ្ធតែជាសម្ដីមិនពិតទាំងអស់ ។ យើងត្រូវតែមានចិត្តស្មោះត្រង់ជឿស្ដាប់ពាក្យឃោសនារបស់រដ្ឋការជាតិខ្មែរយើងនិងកងទ័ពជាតិយើងវិញ ទើបរដ្ឋាភិបាលនិងកងទ័ពជាតិយើងមានកម្លាំងកម្ចាត់ពួកសត្រូវបរទេស ឲ្យចេញផុតពីទឹកដីយើងទៅ ទើបយើងបានសេចក្ដីសុខសាន្តត្រាណតទៅ ។

ត្រង់ព្រះពុទ្ធដីកាថា សុចិកម្មស្ស ដែលប្រែថា អ្នកមានការងារដ៏ស្អាតស្អំនោះ បានសេចក្ដីថា ការងារដែលធ្វើដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី សុទ្ធតែជាការងារប្រាសចាកទោសទាំងអស់ ទើបហៅថា អ្នកមានការងារដ៏ស្អាតស្អំ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងថា បុគ្គលណាលះបង់កាយទុច្ចរិតចេញ ហើយបំពេញកាយសុចរិតប្រព្រឹត្តល្អដោយកាយ គឺមិនសម្លាប់សត្វ, មិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ, មិនប្រព្រឹត្តខុសចំពោះកូនប្រពន្ធរបស់អ្នកដទៃដោយកាម, លះបង់វចីទុច្ចរិតចេញ ហើយបំពេញវចីសុចរិតប្រព្រឹត្តល្អដោយវាចា គឺមិននិយាយកុហកបោកប្រាស់អ្នកដទៃ, មិននិយាយពាក្យ

ញុះញង់បំបែកបំបាក់អ្នកដទៃ មិននិយាយពាក្យទ្រគោះបោះបោកទៅរក
អ្នកដទៃ, មិននិយាយពាក្យរោយរាយឥតប្រយោជន៍, លះបង់មនោ-
ទុច្ចរិតចេញ ហើយបំពេញមនោសុចរិតប្រព្រឹត្តល្អដោយចិត្ត គឺមិន
សម្លឹងលោភលន់ចង់បានទ្រព្យរបស់អ្នកដទៃមកធ្វើជាទ្រព្យរបស់ខ្លួន, មិន
ចងគំនុំគុំគួនចង់ឲ្យគេដល់នូវសេចក្តីវិនាសដោយហេតុណាមួយ, មិន
មានគំនិតយល់ខុសផ្ទុយពីសេចក្តីពិត, បុគ្គលនោះ ទើបឈ្មោះថាអ្នក
មានកាយវាចាចិត្តដ៏បរិសុទ្ធស្អាត ឬហៅថា អ្នកមានមនុស្សធម៌ (ធម៌-
របស់មនុស្ស) ឋិតនៅក្នុងខ្លួនក៏បាន ។ មនុស្សណាគ្មានមនុស្សធម៌
តាំងនៅក្នុងខ្លួនទេ ។ មនុស្សនោះ ទុកដូចជាសត្វតិរច្ឆាន ព្រោះមនុស្ស
លោកចែកចេញជា ៤ ពួកគឺ :

១- មនុស្សបេតោ មនុស្សដូចជាប្រេត បានដល់មនុស្សដែល
មានរូបរាងកាយពិការអាក្រក់ ទ័លក្រហេមហោម មានជីវភាពថោក
ទាប រស់នៅត្រដាបត្រដួស ។

២- មនុស្សនេរយិកោ មនុស្សដូចជាសត្វនរក បានដល់
មនុស្សដែលគ្មានសេចក្តីសុខ មានតែសេចក្តីទុក្ខគ្រប់សង្កាត់ជានិច្ចកាល
គេធ្វើទារុណកម្ម ឲ្យទទួលរងទុក្ខវេទនា ដោយឥតមានមេត្តាករុណាត្រា-
ប្រណី ។

៣- មនុស្សតិរច្ឆានោ មនុស្សដូចជាសត្វតិរច្ឆាន បានដល់មនុស្សដែលគ្មានហិរិឱត្តប្បៈ គ្មានសីលធម៌ និងមនុស្សធម៌ឋិតនៅក្នុងខ្លួន មានរូបកាយជាមនុស្សពិតមែន ប៉ុន្តែចិត្តគំនិតរបស់មនុស្សនោះដូចសត្វតិរច្ឆាន ។

៤- មនុស្សភូតោ មនុស្សមានឋានៈជាមនុស្សពិតប្រាកដ បានដល់មនុស្សត្រឹមត្រូវ គឺមនុស្សដែលមានហិរិឱត្តប្បៈ មានសីលធម៌ និងមនុស្សធម៌ឋិតនៅក្នុងខ្លួន ។ បណ្ដាមនុស្សទាំង ៤ ពួក ដូចបានពណ៌នារៀបរាប់មកនេះ ត្រង់មនុស្សតិរច្ឆានោ មនុស្សដូចសត្វតិរច្ឆាននេះ ជាមនុស្សលាមកអាក្រក់ក្រៃលែងលើសពីសត្វតិរច្ឆានមែនៗទៅទៀត, ធម្មតាសត្វតិរច្ឆានដូចឆ្កែជាដើម ឆ្កែមិនដែលដើរបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកស្រុកទទេៗទេ មិនដែលដើរទៅរកខាំសម្លាប់មនុស្សទទេៗទៀតលែងតែឆ្កួត ទើបវាដើរទៅរកខាំគេ ឯពួកសត្រូវជាតិបរទេសដែលវាឈ្លានពានចូលមកក្នុងទឹកដីផ្ទះយើង ព្យាបាទបំផ្លាញជីវិត បំផ្លាញទ្រព្យសម្បត្តិ បំផ្លាញព្រះពុទ្ធសាសនារបស់ជាតិយើង បំផ្លាញសេចក្ដីសុខសាន្តរបស់ជាតិយើងក្នុងសម័យបច្ចុប្បន្ននេះ វាជាមនុស្សអាក្រក់ហួសពីសត្វតិរច្ឆានទៅទៀត, បើតាមគតិខាងព្រះពុទ្ធសាសនាថា បើសម្លាប់មនុស្សល្អមានគុណធម៌ក្នុងខ្លួន មហា សាវជ្ជោ មានទោសធំ, ទោសច្រើន, បើសម្លាប់មនុស្សអាក្រក់គ្មានគុណធម៌ក្នុងខ្លួនទេ អប្បសាវជ្ជោ មាន

ទោសបន្តិចបន្តួច (បើតាមយោបល់របស់អាត្មាផ្ទាល់ថា សឹងតែគ្មានទោស អ្វីផងទេ រកគល់ទឹងត្រឡប់ទៅជាបានសេចក្តីគាប់ប្រសើរល្អទៅវិញផង) ព្រោះហេតុអ្វីបានជាថាដូច្នេះ ព្រោះហេតុថាមនុស្សតិរច្ឆាន បើយើង មិនប្រឆាំងតបទេ ទុកឲ្យវានៅឡើងបាន វានឹងសម្លាប់ខ្លួនយើងបំផ្លាញ ទ្រព្យនិងសេចក្តីសុខរបស់យើងផង វាអាចទៅសម្លាប់បំផ្លាញជីវិតទ្រព្យ និងសេចក្តីសុខរបស់មនុស្សទាំងឡាយដទៃ ៗ កប់រយកប់ពាន់នាក់តទៅ ទៀតផង បើយើងមានសេចក្តីក្លាហានប្រឆាំងនឹងវា ធ្វើឲ្យវាវិនាសខ្ចាត់ ខ្ចាយទៅ វាខានទៅព្យាបាទសម្លាប់ជីវិតគេ ខានទៅបំផ្លាញទ្រព្យ និង សេចក្តីសុខរបស់គេកប់រយកប់ពាន់នាក់តទៅទៀតដែរ ឈ្មោះថា យើង បានឲ្យជីវិត ឲ្យសេចក្តីសុខដល់មនុស្សកប់រយកប់ពាន់នាក់ផងទៀត, មិន តែប៉ុណ្ណោះ ឈ្មោះថា យើងបានធ្វើបុណ្យបានឲ្យអភយទានដល់មនុស្សទាំង-ឡាយកប់រយកប់ពាន់នាក់ដើម្បីឲ្យគេបានសុខចម្រើនដោយសារយើង ៗ យើងធ្វើដូច្នេះនេះ គឺយើងគ្រាន់តែការពារសត្រូវកាចឃោរឃៅដែលវា ឈ្លានពានចូលមកបង្កហេតុនៅលើទឹកដីផ្ទះយើងទេតើ សូម្បីច្បាប់ខាង អាណាចក្រផ្លូវលោក ក៏គង់វិនិច្ឆ័យកាត់ឲ្យយើងរួចខ្លួន គ្មានទោសពៃរ៍ អ្វីដែរ" ៗ

ម្យ៉ាងទៀត មនុស្សជាតិយើងណាដែលមានចិត្តវៀចវេរ មិន ស្មោះត្រង់នឹងរដ្ឋការជាតិរបស់ខ្លួន ឃើញសត្រូវជាតិបរទេសចូលមក

បៀតបៀនបំផ្លាញជីវិត ទ្រព្យ សេចក្តីសុខរបស់ជាតិឯង ក៏ត្រឡប់ជាចូលដៃ សម្តែងសេចក្តីពិតស្មោះត្រង់កប់អានសត្រូវទៅវិញ ជួយទំនុកបម្រុងឲ្យបាយទឹកនិងប្រាក់កាសដល់សត្រូវ ធ្វើឲ្យសត្រូវរឹងរឹតតែមានកម្លាំង ដើរឈ្លានពានកាប់សម្លាប់បំផ្លាញទ្រព្យសម្បត្តិយកទឹកដីរបស់ជាតិឯងទៅវិញ មនុស្សជាតិយើងនេះដែលប្រព្រឹត្តធ្វើដូច្នេះ បើតាមគតិធម៌ខាងព្រះពុទ្ធសាសនាចាត់ថាមានទោសជាទម្ងន់ សូម្បីច្បាប់ខាងផ្លូវលោកក៏គង់កាត់ឲ្យមានទោសជាទម្ងន់ដែរ ព្រោះចូលដៃឲ្យកម្លាំងដល់មនុស្សខូចអាក្រក់ ៗ ដូចគ្នានឹងមនុស្សណាមួយដែលបានដឹងថាបព្វជិតហ្នឹងជាមនុស្សទ្រុស្តសីលលាមក ហើយនៅតែចិញ្ចឹមទំនុកបម្រុង ឲ្យបព្វជិតហ្នឹងមានកម្លាំងនៅត្រាំត្រែងបង្អាប់បង្អោនព្រះពុទ្ធសាសនាឲ្យវិនាសសាបសូន្យទៅ តើអ្នកទំនុកបម្រុងនឹងចាត់ឲ្យមានទោសដែរឬទេ?

ម្យ៉ាងទៀត អាត្មាសូមជម្រាបរំលឹកជាទូទៅ ចំពោះអស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយដែលមានសញ្ជាតិជាខ្មែរក្តី មានសញ្ជាតិជាបរទេសក្តី ដែលរស់នៅលើទឹកដីខ្មែរឲ្យមានការភ្ញាក់រលឹកគិតឃើញគ្រប់គ្នាឡើងថា អស់លោកអ្នកដែលមានសទ្ធា បានលះបង់ចំណាយទ្រព្យធនកសាងសាលារៀនសម្រាប់ឲ្យពួកយុវជនកុមារា កុមារីរៀនសូត្រមានការចេះដឹងក្តី កសាងមន្ទីរពេទ្យ សម្រាប់ឲ្យសាធារណជនចូលមកព្យាបាលរោគ ដើម្បីឲ្យមានសុខភាពល្អក្តី ហើយយល់ឃើញថាការធ្វើនេះបានបុណ្យច្រើន,

ចំណាយទ្រព្យកសាងថ្នល់ កសាងស្ពាន ឲ្យគេដើរទៅមកបានស្រួល យល់ឃើញថា បានបុណ្យច្រើន, ចំណាយទ្រព្យកសាងវត្ត កុដិវិហារ ឧបដ្ឋានសាលា កសាងសាលាបាលី ជួយទំនុកបម្រុងភិក្ខុសាមណេរ ដោយបច្ច័យទាំង ៤ ជាកិច្ចជួយជ្រោមជ្រែងធ្វើព្រះពុទ្ធសាសនាឲ្យថ្កុំថ្កើង រុងរឿង យល់ឃើញថាបានបុណ្យច្រើន ។ល។ ចុះឥឡូវនេះ បើសត្រូវជាតិបរទេស "ដែលហៅថា យួនវៀតកុង វៀតមិញ ជាទមិឡចិត្តសាហាវ ឃោរឃៅឈ្លានពានចូលមកកាប់សម្លាប់ ដុតបំផ្លាញសាលារៀន មន្ទីរពេទ្យ បំផ្លាញថ្នល់ ស្ពាន បំផ្លាញវត្ត កុដិ វិហារ សាលាជាដើម ឲ្យវិនាសអន្តរាយហិនហោចអស់យ៉ាងនេះ គួរឲ្យស្តាយសែនស្តាយ ទឹងរកអ្វីមកប្រៀបមិនបាន ។ បើហេតុភេទកើតឡើងយ៉ាងនេះ តើយើងជាជាតិខ្មែរជាប្រជាពលរដ្ឋទាំងអស់គ្នា ដែលនៅគ្រប់ទិសទីក្នុងប្រទេសកម្ពុជាទាំងមូល ត្រូវធ្វើដូចម្តេច? យើងត្រូវធ្វើយ៉ាងនេះ ។

ទី ១– ត្រូវឲ្យមានចិត្តស្នេហាស្មោះត្រង់រួបរួមជាមួយនឹងរដ្ឋការជាតិយើងនិងកងទ័ពជាតិយើង, ទី ២- ត្រូវតម្លើងពុកតម្លើងមានះ ធ្វើទឹកចិត្តឲ្យរឹងប៉ឹងឡើងគិតថា សត្រូវនេះមិនមែនជាយក្ស មិនមែនជាហនុមានមកពីណាទេ វាជាមនុស្សមានដៃ ២ ជើង ២ ដូចជាអញដែរ, អញត្រូវតែរួបរួមគ្នាប្រឆាំងការពារខ្លួនតបតវិញ, ទី ៣ ត្រូវតែនាំយកកិច្ចការអាថ៌កំបាំងរបស់សត្រូវមកប្រាប់ខាងរដ្ឋការជាតិយើងនិងកងទ័ពជាតិយើង

ទី ៤- ត្រូវបើកប៉ុស្តិ៍វិទ្យុស្តាប់សម្លេងវិទ្យុជាតិយើងនៅភ្នំពេញ ដែលមានផ្សាយពត៌មានផ្សេងៗផង ទើបអាចនឹងដឹងការណ៍ពិតក្នុងប្រទេស, ទី៥- ត្រូវតាំងចិត្តឲ្យរឹងប៉ឹង កុំភ័ន្តគំនិតជឿសេចក្តីឃោសនារបស់សត្រូវឲ្យសោះ ព្រោះសម្តីនិយាយទាំងប៉ុន្មាន សុទ្ធតែជាសម្តីកុហកបោកប្រាសជាតិយើងទាំងអស់, ទី៦ គប្បីយល់ថា ពេលនេះជាពេលពិសេសជាងពេលណាៗទាំងអស់ យើងត្រូវលះមច្ឆរិយៈ សេចក្តីកំណាញ់ចោលចេញហើយនាំយកប្រាក់កាស និងគ្រឿងឧបភោគ និងគ្រឿងបរិភោគទៅជួយឧបត្ថម្ភដល់រដ្ឋការ និងកងទ័ពជាតិយើងឲ្យបានច្រើន ដើម្បីឲ្យរដ្ឋការនិងកងទ័ពជាតិយើងមានកម្លាំងរឹងប៉ឹង អាចធ្វើចម្បាំងការពារយកជ័យជម្នះបណ្តេញពួកខ្មាំង សត្រូវឲ្យបរាជ័យខ្ចាត់ខ្ចាយចេញអស់ពីប្រទេសយើង, បូរណៈភាពទឹកដី អព្យាក្រឹតរបស់ជាតិយើងក៏នៅគង់វង្ស, សម្បត្តិផ្សេងៗ ដែលយើងបានសាងដូចសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ស្ពាន និងវត្តអារាម កុដិ វិហារ សាលា និងព្រះពុទ្ធសាសនា ។ល។ ក៏នៅគង់វង្ស ។ ដោយអំណាចនៃការជួយទំនុកបម្រុងរដ្ឋការ និងកងទ័ពជាតិយើងច្បាំងយកជ័យជម្នះការពារឲ្យនៅសល់គង់វង្សនេះ ឈ្មោះថាអស់លោកអ្នកបានបុណ្យច្រើនណាស់គឺបានបុណ្យ ច្រើនដូចកាលដែលបានចេញទ្រព្យកសាងពីដំបូងនោះដែរ ។

សេចក្ដីដែលបានពណ៌នាមកទាំងប៉ុន្មាននេះ ហើយអស់លោកអ្នកបានស្ដាប់ប្រតិបត្តិតាមឈ្មោះថា អស់លោកអ្នកបានធ្វើកាយវាចាចិត្តឲ្យបានស្អាតបរិសុទ្ធដោយពិតប្រាកដ ។

គ្រង់ព្រះពុទ្ធដីកាថា និសម្មការិនោ ដែលប្រែថា អ្នកមានការពិចារណាជាមុនហើយទើបធ្វើនោះ បានសេចក្ដីថា កិច្ចការណាអ្វីមួយនោះជាកិច្ចការខាងផ្លូវលោកក្ដីផ្លូវធម៌ក្ដី ដែលខ្លួនកំពុងធ្វើឬបម្រុងនឹងធ្វើតទៅ ត្រូវតែគិតលៃលកពិចារណាឲ្យបានល្អិតល្អន់ ឲ្យឃើញថាសមហេតុសមផលឬទេជាមុនសិន ហើយសឹមធ្វើ ទើបកិច្ចការនោះនឹងបានទទួលលទ្ធផលគាប់ប្រសើរទៅបាន, ផ្ទុយទៅវិញ បើបែរជាមិនបានគិតមិនបានពិចារណាឲ្យបានច្បាស់លាស់ជាមុនសិនទេ ហើយស្រាប់តែចាប់ធ្វើតែម្ដងទៅ កិច្ចការដែលធ្វើនោះ មុខជាមិនបានសម្រេចប្រយោជន៍សមតាមបំណងរបស់ខ្លួនឡើយ ។ អ្នកប្រាជ្ញទាំងឡាយដែលផ្ដងគំនិតនឹងធ្វើការអ្វីផងទាំងពួង លោកតែងកំណត់ពិចារណាឲ្យឃើញថា "បើមានហេតុការណ៍យ៉ាងនេះកើតឡើង អាត្មាអញនឹងត្រូវធ្វើយ៉ាងនេះឬយ៉ាងនោះ" ឧទាហរណ៍ដូចជាការព្យាបាលរោគរបស់គ្រូពេទ្យ ធម្មតាគ្រូពេទ្យដែលត្រូវព្យាបាលអ្នកជំងឺមួយ ៗ កាលបើឃើញអ្នកជំងឺចូលមកដល់មន្ទីរពេទ្យភ្លាម ហើយក៏ចាក់ថ្នាំឲ្យភ្លាម មិនមែនដូច្នោះទេ គ្រូពេទ្យតែងតែសាកសួរអំពីអាការៈរោគនៃអ្នកជំងឺឲ្យដឹងជាមុនហើយពិនិត្យរាវរក សន្និដ្ឋានរោគ

ដែលនាំឲ្យឈឺនោះ ឬដូនកាល គ្រូពេទ្យយកឈាម ឬលាមក ឬក៏ទឹកមូត្ររបស់អ្នកជំងឺនោះទៅពិនិត្យ សមុដ្ឋានរោគផងទៀត ដើម្បីឲ្យដឹងជាមុនថា ទុរោគនេះត្រូវប្រើថ្នាំនោះ, រោគនោះ ត្រូវប្រើថ្នាំនេះ ទើបការព្យាបាលរបស់គ្រូពេទ្យនោះ នឹងមានប្រសិទ្ធិភាពសម្រេចផលប្រយោជន៍ដ៏ល្អតទៅបាន យ៉ាងណាមិញ, ចៅក្រមជំនុំជម្រះរឿងអធិករណ៍ណាមួយក្តី អ្នកធ្វើកសិកម្ម (របរស្រែចម្ការ) ក្តី អ្នកធ្វើពាណិជ្ជកម្ម (របរជំនួញ) ក្តី អ្នកធ្វើបុណ្យផ្សេងៗ មានទានសីលជាដើមក្តី ។ល។ ត្រូវតែពិចារណាអំពើរបស់ខ្លួនដែលធ្វើនោះឲ្យឃើញជាក់ច្បាស់ជាមុនសិន ហើយសឹមចាប់ធ្វើ ទើបការនោះមិនភ្លាត់ខុសហើយអាចសម្រេចផលល្អដោយប្រពៃទៅក៏ដូច្នោះដែរ ។

ឯក្នុងសម័យសព្វថ្ងៃនេះ ប្រទេសយើងកំពុងកើតអសន្តិសុខនាំឲ្យវិនាសអន្តរាយខូចខាតជីវិតមនុស្សទ្រព្យសម្បត្តិជាច្រើន យើងត្រូវពិចារណារកបុព្វហេតុឲ្យឃើញថា អសន្តិសុខនេះ ខ្មែរយើងជាអ្នកបង្កើត ឬអ្នកណាជាអ្នកនាំបង្កើត? ថាទេ មិនមែនខ្មែរយើងទេ, បើមិនមែនខ្មែរយើងទេ ចុះអ្នកណា? ថា យួនវៀតកុងនិងយួនវៀតមិញបង្កើតឡើង ។ យួនវៀតកុង-វៀតមិញនេះជាជាតិបរទេស វានៅប្រទេសវាឯណោះទេ ហេតុក៏បានជាវាចូលមកបង្កើតអសន្តិសុខច្បាំងដណ្តើមយកទឹកដីខ្មែរយើងទៅវិញ? ត្រង់នេះអស់លោកអ្នកទាំងឡាយសឹងតែ

បានផ្តាច់អស់ហើយ ដែលពួកយៀកកុង-យៀកមិញ ដើរឃោសនាប្រាប់បងប្អូនខ្មែរយើងស្ទើរគ្រប់កន្លែងថា យើងខ្ញុំ ចូលមកធ្វើចម្បាំងដណ្តើមយកទឹកដីពីរដ្ឋាភិបាលសព្វថ្ងៃនេះបានហើយ នឹងប្រគល់ឲ្យដល់អ្នកនេះអ្នកនោះ ហើយយើងខ្ញុំ នឹងនាំគ្នាត្រឡប់ទៅនៅឯប្រទេសយើងខ្ញុំវិញទេ ។ សម្តីឃោសនាអស់ទាំងនេះ សូមអស់លោកអ្នកទាំងឡាយពិចារណាមើលចុះថា យួនយៀកកុង-យៀកមិញនេះ វាឈឺចិត្តឆ្អិតទ្រូងអ៊ីម្ល៉េះ បានជានាំគ្នាយកជីវិត មកចំណាយចោលឲ្យស្លាប់រាប់រយពាន់នាក់តរជើងគ្នាទៅលើទឹកដីខ្មែរ ពីព្រោះតែចង់បានទឹកដីឲ្យដល់អ្នកដទៃទៅវិញ ។ ក្នុងពិភពលោកទាំងមូល ពុំដែលឃើញមានសោះ ជាតិសាសន៍ទៅប្រទេសមួយហើយនាំគ្នាទៅ ឲ្យគេសម្លាប់រាប់ពាន់រាប់ម៉ឺននាក់ដើម្បីជាប្រយោជន៍ដល់ជាតិសាសន៍ទៅប្រទេសមួយទៀតទទេៗនោះ មិនដែលឃើញមានទាល់តែសោះ ។ សម្តីឃោសនារបស់យួនយៀកកុង-យៀកមិញនេះជាសម្តីកុហកបោកបញ្ឆោតខ្មែរយើងទេ តាមការណ៍ពិតគឺវាច្បាំងប្លន់ដណ្តើមយកទឹកដីខ្មែរយើង ដាក់ទៅជាស្រុកចំណុះជាប្រយោជន៍របស់វាទេ ។

អាស្រ័យហេតុដូចពណ៌នាដោយសង្ខេបខាងលើនេះ សូមអស់លោកអ្នកទាំងឡាយពិចារណា ឲ្យឃើញជាក់ច្បាស់ហើយពង្រឹងចិត្តពង្រឹងស្មារតីឲ្យរឹងប៉ឹងឡើង កុំជឿពាក្យឃោសនារបស់សត្រូវឲ្យសោះ, ត្រូវ

ស្តាប់ ត្រូវជឿតែពាក្យឃោសនារបស់រដ្ឋការជាតិយើងតែម្យ៉ាងប៉ុណ្ណោះ ទើបហៅថា ជាអ្នកមានគំនិតជ្រាជ្រះគិតពិចារណា ។

ត្រង់ព្រះពុទ្ធដីកាថា សញ្ញតស្ស ដែលប្រែថា សង្រួម ឬប្រុងប្រយ័ត្ននោះ បានសេចក្តីថា បុគ្គលត្រូវសង្រួមប្រុងប្រយ័ត្នទ្វារទាំង ៣ គឺ កាយទ្វារ វចីទ្វារ និង មនោទ្វារ ពីព្រោះទ្វារទាំង ៣ នេះឯង ជាទីហូរចូលមកនៃអំពើទាំងល្អទាំងអាក្រក់, កាលបើកិលេសគឺ លោភៈ ទោសៈ មោហៈ កើតឡើងមានកម្លាំងក្នុងសន្តានចិត្តនៃបុគ្គលណាហើយ អាចដឹកនាំបុគ្គលនោះ ឲ្យប្រព្រឹត្តធ្វើអំពើអាក្រក់ដោយកាយ មានការកាប់សម្លាប់បំផុតជីវិតគេ និងការលួចប្លន់របជាន់ដណ្តើមយកទ្រព្យសម្បត្តិរបស់គេជាដើម, ប្រព្រឹត្តធ្វើអំពើអាក្រក់ដោយវាចា មានការនិយាយពាក្យកុហកបោកប្រាស់គេ និងការនិយាយពាក្យអុជអាលញុះញង់បំបែកបំបាក់ ឲ្យគេកើតវិវាទឈ្លោះទាស់ទែងគ្នា ធ្វើគេឲ្យព្រាត់ប្រាសគ្នាជាដើម, ប្រព្រឹត្តធ្វើអាក្រក់ដោយចិត្ត មានការលោភលន់ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន និងការព្យាបាទចងគំនុំគុំគួន ចង់ឲ្យគេដល់នូវសេចក្តីវិនាសអន្តរាយដោយហេតុណាមួយជាដើម ។ យើងជាជាតិខ្មែរជាពុទ្ធសាសនិក អ្នកគោរពជឿកាន់ព្រះពុទ្ធសាសនា យល់ឃើញថាការធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត ដូចបានពោលមកនេះ សុទ្ធតែជាអំពើលាមកអាក្រក់ពុំគួរប្រព្រឹត្តធ្វើ

ឡើយ ។ បំណែកខាងពួកសត្រូវ គឺយួនយៀកកុង យៀកមិញមិនដូច្នោះទេ វាបែរជាចូលមកកាត់ក្បាលកាប់សម្លាប់ប្លន់យកទ្រព្យសម្បត្តិគេ ដោយឥតកោតញញើតយ៉ាងនេះទៅវិញ ។ ហេតុនេះយើងជាអ្នកកាន់ព្រះពុទ្ធ-សាសនា ពេលនេះ មិនត្រូវសង្រួមធ្វើស្លូតហួសហេតុទេ បណ្ដោយឲ្យសត្រូវចូលមកសម្លាប់ជីវិតខ្លួន ប្លន់យកទ្រព្យសម្បត្តិខ្លួន បំផ្លាញព្រះពុទ្ធ-សាសនារបស់ខ្លួន មិនសមសោះឡើយ ។ យើងគ្មានរំលោភទៅលើគេទេ, គេទេតើដែលរំលោភមកលើយើង, យើងគ្រាន់តែជាអ្នកការពារខ្លួនប៉ុណ្ណោះ ។ ហេតុនេះត្រូវយើងនាំគ្នាក្រោកឡើង រួមជាមួយនឹងរដ្ឋការជាតិយើង និងកងទ័ពជាតិយើង តស៊ូប្រឆាំងនឹងសត្រូវ, ការពារជីវិត ការពារទ្រព្យសម្បត្តិ ការពារព្រះពុទ្ធសាសនា ការពារទឹកដីរបស់យើងឲ្យបានគង់វង្សតទៅ ទើបឈ្មោះថាជាអ្នកសង្រួមប្រុងប្រយ័ត្ន ។

ត្រង់ព្រះពុទ្ធដីកាថា ធម្មជីវិនោ ដែលប្រែថា អ្នករស់នៅតាមគន្លងធម៌នោះ បានសេចក្ដីថា បុគ្គលទាំងឡាយដែលកើតមកក្នុងលោកត្រូវតែធ្វើការងារស្វែងរកគ្រឿងឧបភោគនិងគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត ប៉ុន្តែការងារដែលធ្វើនោះត្រូវឲ្យប្រកបដោយគន្លងធម៌ផង, បើខាងគ្រហស្ថ ត្រូវវៀរ មិច្ឆាជីវកម្ម មានការលក់ចេញទិញចូលប្រវ័ញ្ចដោយក្លែងជញ្ជីងជាដើម ហើយប្រកបការងារចិញ្ចឹមជីវិតដោយសម្មាជីវៈ មានកសិកម្ម, គោរក្ខកម្ម និងពាណិជ្ជកម្មជាដើម, ខាងបព្វជិតត្រូវវៀរ

បាបធម៌ ៥ និងអនេសនៈ ២១ មានវេជ្ជកម្ម និងទូតកម្មជាដើម, ហើយចិញ្ចឹមជីវិតដោយកិច្ចការប្រកបដោយសមធម៌ ។ គ្រហស្ថនិងបព្វជិតប្រ-ព្រឹត្តធ្វើយ៉ាងនេះទើបឈ្មោះថា ជាអ្នកចិញ្ចឹមជីវិតរស់នៅតាមគន្លងធម៌ ។ អស់លោកអ្នកទាំងឡាយ ជាពុទ្ធសាសនិកបានគោរពប្រតិបត្តិនូវពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់, បានវៀរចាកការចិញ្ចឹមជីវិតខុសដោយមកពីខាងបាប, ជីវិតអស់លោក-អ្នកឈ្មោះថាជាជីវិតប្រសើរ កាលបើអស់លោក-អ្នកដល់នូវទីបំផុតនៃអាយុជីវិតទៅ អស់លោក-អ្នកនឹងត្រូវទៅកាន់សុគតិ ក្នុងភពណាមួយមិនខាន ។ ជីវិតរបស់ពួកមនុស្សដែលគ្មានសាសនា គ្មានជឿបុណ្យជឿបាប ប្រព្រឹត្តធ្វើអំពើអាក្រក់ដោយឥតគោតញ្ញើត ឈ្មោះថាជាជីវិតហោមកៈថាកទាបបំផុត សមដូចបុរាណសុភាសិតថា "រស់នៅគ្រាន់តែល្អមើល តែមិនល្អស៊ី" មនុស្សពួកនេះកាលបើអស់អាយុជីវិតស្លាប់ទៅហើយ ទៀងតែសំយុងក្បាលចុះទៅកើតក្នុង ទុគ្គតិភព គឺនរក ប្រេត អសុរកាយ តិរច្ឆានពុំខានឡើយ ។ ព្រោះហេតុនោះ សូមអស់លោក-អ្នកទាំងឡាយសាមគ្គីរួបរួមគ្នាការពារព្រះពុទ្ធសាសនា ដើម្បីកុំបណ្ដោយឲ្យពួកទមិឡចូលមកបូនដណ្ដើមយកទឹកដីបំផ្លាញបំបាត់ព្រះពុទ្ធសាសនាបានឡើយ ។

ត្រង់ព្រះពុទ្ធដីកាថា អបរិអត្តសន្តុ ដែលប្រែថា អ្នកមិនប្រមាទអ្នកមិនធ្វេសប្រហែសនោះបានសេចក្ដីថា អ្នកដែលមិនលះបង់ ឬមិនបណ្ដោត

បណ្ដាយសតិ ឲ្យកយមាយក្អើតក្អើនទៅក្នុងអារម្មណ៍ជាអកុសលឥតប្រ-យោជន៍ ទើបឈ្មោះថាជាអ្នកមិនធ្វេសប្រហែស ។ មនុស្សដែលកើតមកក្នុងលោកនេះមាន ២ ពួក មនុស្សប្រមាទ ១ ពួក មនុស្សមិនប្រមាទ ១ ពួក ។ មនុស្សណាប្រមាទធ្វេសប្រហែស មនុស្សនោះទុកដូចជាស្លាប់ស្រេចទៅហើយ សូម្បីកំពុងមានជីវិតរស់នៅ ក៏ទុកដូចជាស្លាប់ដែរ ។ មនុស្សណាមិនប្រមាទ មិនធ្វេសប្រហែស មនុស្សនោះឈ្មោះថា មានជីវិតរស់នៅ សូម្បីស្លាប់បាត់ទៅហើយ ក៏ទុកដូចជារស់នៅដែរ ។

សេចក្ដីស្លាប់របស់មនុស្សមាន ២ យ៉ាងគឺ ស្លាប់ជីវិតមួយ ស្លាប់គំ-និតមួយ ។ បណ្ដាសេចក្ដីស្លាប់ទាំង ២ យ៉ាងនេះ ត្រង់សេចក្ដីស្លាប់គឺអស់ខ្យល់ចេញនិងខ្យល់ចូល ទាំងវិញ្ញាណក៏ប្រាសចេញផុតចាកកងកាយទៅហើយ ហៅថា ស្លាប់ជីវិត, ស្លាប់បែបនេះជាការគាប់ប្រសើរ ជាងស្លាប់គំនិត ។ មនុស្សណាដែលមានសេចក្ដីប្រមាទធ្វេសប្រហែសបណ្ដែតបណ្ដាយគំនិតស្មារតី ឲ្យកយមាយលង់ទៅក្នុងកាមគុណ ឬក្នុងអំពើឥតប្រយោជន៍ ឬក្នុងអំពើអាក្រក់ណាមួយ ដោយកាយវាចាចិត្ត ដែលជាអំពើឃ្លាងផុតស្រឡះពីសេចក្ដីល្អ សេចក្ដីចម្រើនខាងផ្លូវលោក និងផ្លូវធម៌ ទាំងក្នុងបច្ចុប្បន្ន និងក្នុងបរលោក មនុស្សនោះឯង លោកហៅថាមនុស្សប្រមាទ ឬមនុស្សស្លាប់គំនិត ។ មនុស្សប្រមាទស្លាប់គំនិតនេះ សូម្បី

មានជីវិតរស់នៅក៏ដោយ ទុកដូចជាមនុស្សស្លាប់ស្រេចទៅហើយ ។ ធម្មតាមនុស្សស្លាប់ជីវិត ដែលមានវិញ្ញាណប្រាសចាកផុតពីរាងកាយទៅហើយ ឥតដែលមានគំនិតគិតថា អាត្មាអញនឹងឲ្យទានរក្សាសីលឬគិតធ្វើកិច្ចការណាមួយទុកជាស្នាដៃ ឬជាប្រយោជន៍សោះឡើយ យ៉ាងណាមិញ, ឯមនុស្សប្រមាទ គឺមនុស្សស្លាប់គំនិត ក៏គ្មានដូច្នោះដែរ ។

មនុស្សប្រភេទណាក៏ដោយ ទោះគ្រហស្ថឬបព្វជិតដែលមានសេចក្តីប្រមាទនៅក្នុងខ្លួនហើយ, មនុស្សនោះទុកដូចជាជដ្គត់ក្នុងលោក ឬជាមនុស្សបំព្រៃលោក ។ បើនិយាយឲ្យកក់ងាយស្តាប់ គឺមនុស្សណាមួយនៅក្នុងភូមិស្រុកណាឥតបានធ្វើអ្វីទុកជាប្រយោជន៍ខាងផ្លូវលោកឬខាងផ្លូវសាសនា ក្នុងភូមិស្រុកនោះឡើយ មានតែបង្កហេតុអាក្រក់គឺទុក្ខទោសអពមង្គលបំផ្លិចបំផ្លាញផលប្រយោជន៍ និងសេចក្តីសុខចម្រើនរបស់គេឲ្យវិនាសអន្តរាយហិនហោច ដោយសារខ្លួនតែម្យ៉ាងប៉ុណ្ណោះ មានតែអំពើអាក្រក់របស់ខ្លួនដែលធ្វើនោះ ទុកជាប្រវត្តិ ឬជាស្នាដៃឲ្យអ្នកផងស្អប់ខ្ពើមចាំទុកមិនភ្លេច, មនុស្សប្រមាទស្លាប់គំនិតនេះ ជាអ្នកថោកថយអន់ក្រៃលែង សូម្បីដើរ ឈរ អង្គុយ ដេក ឬធ្វើអ្វី ក៏ឥតដឹងខុសត្រូវ ឥតដឹងការគួរពុំគួរឡើយ ។ បើបង្រួមសេចក្តីឲ្យខ្លីមកថា មនុស្សប្រមាទស្លាប់គំនិត ឈ្មោះថា ស្លាប់ទាំងរស់ គឺស្លាប់ប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក ជាមនុស្សមិនទាន់សម័យនិយម មិនអនុវត្តន៍

ទៅតាមកាលៈទេសៈ មានតែខ្យល់ដង្ហើមចេញចូល ដូចជាស្លាប់, រស់នៅគ្រាន់តែបរិភោគអាហារ ឬគ្រាន់តែកប់ថ្ងៃខែឆ្នាំមួយៗ ដែលកន្លងទៅហើយប៉ុណ្ណោះ ។

ចំណែកខាងមនុស្សដែលមានអាកប្បកិរិយាផ្ទុយស្រឡះពីមនុស្សដូចបានសម្តែងរៀបរាប់មកក្នុងខាងលើនេះ ហៅថាមនុស្សមិនប្រមាទ មិនស្លាប់គំនិត ។ ធម្មតាមនុស្សមិនស្លាប់គំនិត តែងមានគំនិតរស់រវើកជានិច្ច តែងតែពិចារណាថា ថ្ងៃមួយ យប់មួយដែលកន្លងទៅហើយ តើអាត្មាអញបានធ្វើអ្វីខ្លះ ទុកជាប្រយោជម៍ខ្លួន ឬជាប្រយោជន៍អ្នកដទៃ កាលបើគិតឃើញហើយ មិននៅដម្កល់ទម្រន់ តែងស្វះស្វែងខំនាំបំ-ពេញកិច្ចការនោះៗ តាមកម្លាំងនិងសមត្ថភាពគ្រាតែបានសម្រេចលទ្ធផលជាទីផុត ។ មនុស្សបែបនេះ កាលដែលមានជីវិតកំពុងរស់នៅ អ្នកផងរមែងចូលចិត្តស្រឡាញ់រាប់អាន មានកេរ្តិ៍ឈ្មោះក្រអូបសាយទៅសព្វទិសទី សូម្បីរូបកាយស្លាប់រលាយបាត់ទៅហើយក៏ដោយ ឯនាមនិងគោត្តព្រមទាំងកេរ្តិ៍ឈ្មោះនៅរស់រវើក មិនចេះស្លាប់បាត់សូន្យទៅជាមួយផងឡើយ បច្ចាជនតែងកត់ចំណាំចាំទុកអស់កាលជាអង្វែង ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា មនុស្សប្រមាទសូម្បីមានជីវិតរស់នៅ ក៏ទុកដូចជាស្លាប់ស្រេចទៅហើយ ឯមនុស្សមិនប្រមាទ សូម្បីស្លាប់បាត់ទៅហើយ ក៏ទុកដូចជានៅរស់ដែរ ។

សភាជពៅ បពិត្រអស់លោកអ្នកសប្បុរសទាំងឡាយ អាត្មាភាព បានលើកយកពុទ្ធឱវាទរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់មកសម្ដែង អធិប្បាយពង្រីកសេចក្ដីតាមអត្ថន័យក្នុងពុទ្ធឱវាទនីមួយ ៗ ជូនជាសណ្ដាប់ក្នុងឱកាសនេះ ក៏បានចប់សព្វគ្រប់ហើយ បើអស់លោកអ្នកដែលបានយកចិត្តទុកដាក់ស្ដាប់ចាំហើយ បានគោរពប្រតិបត្តិតាមដោយទៀងទាត់ ប្រាកដជាអស់លោកអ្នកនឹងបានទទួលនូវឥស្សរិយយស ភោគៈ កិត្តិស័ព្ទកេរ្តិ៍ឈ្មោះ និងសេចក្ដីគោរពរាប់អាន អំពីសម្នាក់មនុស្ស និងទេវតាទាំងឡាយដទៃពុំខានឡើយ ។

-ចប់-

# វិចារណកថា:

## បញ្ហាអប់រំនៅក្រៅសាលា

ដោយ លី ឆាម តេង

---

ប៉ុន្មានថ្ងៃនេះ មានសារពត៌មានជាតិ បានធ្វើអត្ថាធិប្បាយជាច្រើនអត្ថបទ ស្តីអំពីបញ្ហាអប់រំយុវជន ៗ បញ្ហានេះ ពិតជាចម្បងបំផុត បើយើងប្រមើលមើល រកឫសគល់ នៃទឹកចិត្តរបស់ពលរដ្ឋ ក្នុងប្រទេសនីមួយៗ ៗ បើប្រទេសណាមានការអប់រំយុវជនឲ្យបានល្អ ពលរដ្ឋនៃប្រទេសនោះទាំងមូល ក៏មានសន្តានចិត្តមុះមុតអង់អាច ហើយប្រកបដោយចរិយាមានវិន័យនិងសេចក្តីថ្លៃថ្នូរជាទីសរសើរ ៗ ផ្ទុយទៅវិញ បើការអប់រំយុវជនមិនបានហ្មត់ចត់ ឬមានធ្វើដែរ ប៉ុន្តែមិនត្រូវតាមន័យដែលប្រទេសជាតិចាំបាច់នោះ លក្ខណចរិយា ឬ សន្តានចិត្តពលរដ្ឋ ក៏នៅខ្វះខាតគ្រប់វិស័យលុះដល់គ្រាមានអាសន្នម្តង ៗ ឡើង ពុំងាយនឹងពត់ហាត់ហ្វឹកហ្វឺនឲ្យត្រូវផ្លូវ តាមគោលដៅជាតិឡើងវិញ បានដោយងាយឡើយ ជាហេតុនាំឲ្យមានការយឺតយ៉ាវខាតពេលយ៉ាងច្រើន ចម្រាំតែណែនាំ ឬស្ទួយស្ទូចស្ថានការណ៍ឲ្យយឺតយោងខ្ពស់ឡើងរួចនោះ ៗ

វេលានេះ យើងក៏សូមជួយធ្វើភាគទានបន្ថែមលើសហសេវិកអ្នកនិពន្ធ ដែលបានអធិប្បាយមកហើយ ចំពោះចំណុចណាដែលមិនទាន់

សព្វគ្រប់ទៅទៀយ ។

គ្រប់អត្ថបទដែលសម្ដែងមកហើយ សុទ្ធសឹងតែឆ្ពោះត្រង់យុវជនដែលមានវ័យពេញការសិក្សា គឺជាច្រើនតែសំដៅយកយុវជននៅក្នុងសាលា ទាំងសាលាជាន់ទាប ជាន់កណ្ដាល និងជាន់ខ្ពស់ ៗ ឯមតិបន្ថែមរបស់យើង, យើងសូមសិក្សាល្បងមើល អំពីការអប់រំយុវជននៅក្រៅសាលា និងពិសេសគឺការអប់រំកុមារតូច ៗ ដែលកំពុងចាប់ផ្ដើមដុះនិស្ស័យរៀនមើលយកតម្រាប់ទាំងការនិយាយស្ដី ទាំងកាយវិការ និងទាំងទម្លាប់ចិត្តផ្ដើម តាមបែបអ្នកដែលនៅជិតខាងខ្លួនរៀងរាល់ថ្ងៃ គឺចណ្ដាកុមារ-កុមារីមានអាយុពី ២ ឆ្នាំឡើងទៅ ៦ ឬ ៧ ឆ្នាំ ៗ យើងសូមសម្ដែងមតិនេះមួយវគ្គម្ដង ដូចតទៅ ៖

## ១- បំពោះការអប់រំទូទៅនៅក្រៅសាលា

បញ្ហាអប់រំនៅក្រៅសាលា មានទំហំធំទូលាយពេកណាស់ ស្ទើរតែរកកំណត់ព្រំដែនមិនកើត ប៉ុន្តែគេអាចសន្មតយកប៉ុនណា ដែលការអប់រំនោះ ជួយកម្រិតឲ្យបានប៉ុណ្ណោះសិន ទុកជាលទ្ធផល ហើយបើហេតុការណ៍នេះ រាលាតសន្ធឹងទៅដល់ណាទៀត សឹមគេដេញតាមរាប្តទៅទៀត ៗ ការអប់រំនៅក្រៅសាលា មិនមែនសម្រាប់តែយុវជនទេ ថែមទាំងសម្រាប់ជនទូទៅ ពិសេសមាមីងចាស់ៗ ដែលខ្វះខាតការសិក្សាពីដើមមក ឬក៏ជាចំណាប់បន្ថែមសម្រាប់អ្នកមានការចេះដឹងហើយ តែផុត

ពេលពីការសិក្សាអប់រំក្នុងសាលា ។

ចុះការអប់រំរបៀបនេះ ធ្វើឡើងតាមវិធីណា ?

មានវិធីច្រើនទៀត សម្រាប់ផែនការអប់រំនេះ ឲ្យកើតឡើងបាន ដែលយើងលើកយកមកអធិប្បាយជាគោល ៗ មាន :

ក – ការអប់រំតាមសម្លេងវិទ្យុ ដែលផ្សាយពីពត៌មានវប្បធម៌ , ពីបែបបទសិក្សា, ពីការចេះដឹងទូទៅ មានប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, អក្សរសាស្ត្រ, វិទ្យាសាស្ត្រ ជាដើម ;

ខ- ការអប់រំតាមទូរទស្សន៍ ដែលផ្សាយអំពីលក្ខណៈដូចគ្នានឹងការផ្សាយតាមវិទ្យុដែលយើងរាប់មកហើយនេះដែរ តែទូរទស្សន៍មានលក្ខណៈជាក់ស្តែងថែមទៀតផង គឺមានចេញជារូបពិតៗ មែនៗ ម៉្លោះហើយគេងមានការថ្លែលក្ខណៈរូបភាពនោះផងទៀត ។

គ- ការអប់រំតាមទស្សនីយភាពសិល្បៈ ដែលបានផ្សាយទៅតាមគ្រប់មជ្ឈដ្ឋាន គឺថាបានជួបផ្ទាល់ជាមួយអ្នកស្រុកតែម្តង មានក្រុមល្ខោន ភ្លេង, ចម្រៀង, ភាពយន្ត ។ល។

ឃ- ការអប់រំតាមបាឋកថា, សន្និសីទផ្សេង ៗ ដែលចាត់ចែងឡើងតាមគ្រឹះស្ថានសិក្សានានា ឬតាមភូមិស្រុកទាំងអស់ក្នុងក្របខណ្ឌនៃការអប់រំ ។

ង- ការអប់រំតាមការបោះពុម្ពផ្សាយ, ការបោះពុម្ពផ្សាយនេះ មានផ្សាយជាសារពត៌មាន ទស្សនាវដ្តី និងសៀវភៅគ្រប់បែបទាំងអស់ ៗ ការ

ផ្សាយផ្នែកនេះ  មានឥទ្ធិពលមុតជ្រៅទៅក្នុងសន្តានចិត្តបណ្តាជនខ្លាំងជាងគេ  ព្រោះមានជាប់ជាលាយលក្ខណ៍អក្សរច្បាស់ក្រឡាជានិច្ច  មិនងាយនឹងរលុបរលាយទៅវិញឡើយ ។

ដូច្នេះ  យើងសូមទាញអារម្មណ៍ជនជាតិយើងជាសំខាន់គឺអ្នកអប់រំ និងពពួកអ្នកយកចិត្តទុកដាក់ក្នុងការអប់រំ  ព្រមទាំងអ្នកមាននាទីផ្សាយការអប់រំនៅក្រៅសាលា  មានអ្នកនិពន្ធ កវី សិល្បករតូរ្យតន្ត្រី  អ្នកចម្រៀង សិល្បករល្ខោន ។ល។  មួយអន្លើនឹងអ្នកអាន អ្នកស្តាប់  អ្នកទស្សនាទូទៅ ជួយត្រិះរិះពិចារណាក្នុងរឿងនេះផងដែរ ។  ព្រោះស្នាដៃសិល្បៈនោះជាការសរសេរនិពន្ធក្តី  ការសម្តែងក្តី  ការផ្សាយចេញសូរសំនៀងក្តី សុទ្ធតែជ្រួតជ្រាបទៅក្នុងសន្តានចិត្តអ្នកស្រុក  សន្តានទិស្ស័យយុវជននិងកុមារតូចៗ ដែលកំពុងតែរៀនក្រេប  រៀនយកតម្រាប់មួយថ្ងៃបន្តិចៗ អំពីរសជាតិនៃការផ្សាយនេះ ។

បើដូច្នេះហើយ  មុននឹងចេញផ្សាយស្នាដៃសិល្បៈណាមួយ  តោងតែគិតឲ្យច្បាស់ពីបញ្ហានេះ  ឲ្យបានសព្វគ្រប់ជាមុនសិន ។

## ២ - ចំពោះការអប់រំកុមារតូច ៗ ពុំទាន់ដឹងក្តី .-

ពាក្យថាពុំទាន់ដឹងក្តី  បានន័យថាក្មេងពុំទាន់យល់ការខុសត្រូវដោយខ្លួនឯង · ចេះគិតចេះគូរហ្មត់ចត់ដូចមនុស្សធំនៅឡើយ  គឺមានអាយុប្រមាណពី២ ឆ្នាំទៅ ៦ ឬ ៧ ឆ្នាំ ។  ក្នុងវ័យនេះ  កុមារកំពុងរៀនយក

តម្រាប់ បើធៀបនឹងត្រួយវល្លិ៍ដែលទើបតែលូតក្នុងពេលមានភ្លៀងដំបូង វាមានដុះដៃ ឬ ចុងត្រួយនោះឯង លូតហក់ទៅមុខជាដរាប រកមែកឈើ ឬជន្ទល់ល្មមតោងបានក៏តោងក្តាម ម៉្លោះហើយ បើប៉ះទៅលើជន្ទល់ល្អក៏តោងក្តាប់ទៅបានល្អ បើប៉ះជន្ទល់ពុក ឬមែកឈើឆាប់ ក៏ធ្លាក់រុះជាប់ត្រួយឬមួយហក់ចុងត្រួយទៅក្រោមវិញក៏មាន ។

ការធៀបប្រៀបបង្ហាញថា កុមារក្នុងវ័យនេះ ត្រូវតែបានទទួលការអប់រំឲ្យហ្មត់ចត់ ជៀសវាងកុំឲ្យវាជ្រួសផ្លូវ ឬវាផ្តេសផ្តាស់ខុសគន្លង ឧបមាដូចជាចុងត្រួយនៃវល្លិ៍ ដែលគ្មានជន្ទល់មាំទាំនោះឯង ។

តើវិធីអប់រំក្មេងក្នុងវ័យនេះ តាមបែបណា ?

ក្រៅពីមាតា-បិតា បងប្អូនញាតិមិត្តដែលជាមជ្ឈដ្ឋានអប់រំផ្ទាល់ ហើយជាអចិន្ត្រៃយ៍របស់វាផងនោះ យើងសូមស្នើគិតពីរឿងអប់រំខាងផ្លូវសម្ភារៈមុន ហើយពុំបានជាល្អិតណាស់ណាទេ សូមច្បិចយកតែរឿងទាក់ទងមកខាងអ្នកអក្សរសាស្ត្រ អ្នកវប្បធម៌ប៉ុណ្ណោះ ដូចជា :

ក. គ្រឿងប្រដាប់លេង .— គួរតប្បីតែមានវិធីពិចារណាយ៉ាងដិតដល់ក្នុងកិច្ចការបង្កើតឲ្យមានគ្រឿងលេង ដែលគេច្រើនធ្លាប់មាត់ហៅជាពាក្យបារាំងថា “ ហ្ស៊ូអេ ” នោះ, គឺធ្វើយ៉ាងណាឲ្យមានគ្រឿងលេងនេះច្រើនបែបច្រើនយ៉ាង គឺថាឲ្យសម្បូណ៌ហូរហៀរ ហើយឲ្យមានតម្លៃថោក ងាយស្រួលទិញយកទៅឲ្យក្មេងលេងបានគ្រប់គ្នា ។ គ្រឿង

លេងនោះ តោងជ្រើសពីន័យដែលបង្ហាញក្មេងឲ្យហ៊ឺហាឥតប្រយោជន៍ ហើយបញ្ចូលន័យឲ្យធ្ងន់ទៅខាងរបៀបអប់រំវិញ ជាការបណ្ដុះនិស្ស័យក្មេង ឲ្យចេះយល់ខាងវិទ្យាសាស្ត្រ ដូចជាប្រដាប់រៀនដោះរៀនតម្រៀបនូវខ្ចៅខ្ទង់គ្រឿងតម្លើងអ្វីមួយ ជារូបស្ពាន រូបឡាន រូបផ្ទះ រូបត្រាក់ទ័រឈ្លូជ័ ។ល។ ដែលសព្វថ្ងៃអ្នកបច្ចេកទេស និងអ្នកចិត្តសាស្ត្រ បានបង្កបង្កើតឡើង មកហើយស្រាប់ ៗ ក្រៅពីនេះ គួរមានការពត់ហាត់ឲ្យមានសតិស្មារតីជាតិ គឺបណ្ដុះចិត្តឲ្យស្គាល់រូបភាពក្នុងព្រៃព្រឹក្សា ប្រាសាទបុ-រាណ និងផលានុផល កើតមាននៅស្រុកខ្មែរ ។ល។

ខ- ក្មេងបម្រៀងខ្លីៗ .— ត្រូវមានបទឆាយៗ ទំនុកខ្លីៗ សម្រាប់ឲ្យក្មេងរៀនច្រៀងចាំមាត់ខ្លួនឯង ជៀសវាងកុំច្រៀងបទតំអូញហួស ឬទំ-នុកនាំឲ្យខ្លាច ដូចជាថាខ្លាចមៀម ទីទុយ ជីងចក់, . . . ឬថាឲ្យខ្ជិល ស៊ីដើរលេងឥតប្រយោជន៍, កុំឲ្យក្មេងឮឬចាំទុកឲ្យសោះ ។

គ- សៀវភៅរូប. គ្រប់ប្រទេស គេយកសៀវភៅរូបធ្វើជាមធ្យោ-បាយ ធំណាស់សម្រាប់អប់រំកុមារតូចៗ ម្ល៉ោះហើយបានជាស្រុកខ្លះសៀវភៅបែបនេះ ត្រូវបោះពុម្ពមានចំនួនរាប់លានក្បាល ត្បិតក្មេងត្រូវការអានច្រើនគ្នាណាស់ ។

តើរូបគំនូរបែបណា? សូមកុំប្រឡំជា រូបគំនូរដែលជារឿងមានកំសត់កម្រ ស្នេហាផ្ដេកផ្ដិត នោះឲ្យសោះ ។ បែបនោះមិនមែនជាការអប់រំទេ

ជួនឡប់ទៅជាបង្ខូចសតិអារម្មណ៍ក្មេងទៅវិញក៏មាន ។ ដូច្នេះ សៀវភៅដែលយើងត្រូវធ្វើសម្រាប់អប់រំក្មេងក្នុងគ្រានេះ មានសណ្ឋានប្លែក ដែលយើងសូមអធិប្បាយឲ្យវែងឆ្ងាយបន្តិច ត្រូវមានលក្ខណៈពិសេសរបស់វាគឺ :

- ត្រូវមានរូបពណ៌ឲ្យច្បាស់ ៗ គំនូរធំៗ ។
- ត្រូវមានទំហំខ្នាតសៀវភៅឲ្យធំ ហោះអក្សរក៏ធំ ៗ ។
- រឿងខ្លី ៗ តែប្រហែល ៤ ឬ ៦ ឬ ៨ ទំព័រប៉ុណ្ណោះឲ្យចប់ ។
- ពាក្យឃ្លាប្រយោគឲ្យងាយៗ ហើយបំប្រួញឲ្យតិចបំផុត ។
- រឿងនោះ ជារឿងឲ្យគតិ ជាការភ្ញាក់រឭក ឬ ការស្គាល់ទំនៀមទម្លាប់ជាតិឯងច្បាស់លាស់ ឬទ័យដំបូន្មានស្រួលៗយល់ ។
- ក្របក្រៅត្រូវធ្វើជារូបភាពពណ៌ឲ្យល្អវិចិត្រ គ្រាន់តែក្មេងក្រឡេកឃើញ ចាប់ចិត្តចង់កាន់ ចង់បើកមើលភ្លាម ។
- តម្លៃ ក៏ឲ្យថោកគួរសម ងាយក្មេងៗ ឬមាតាបិតាដែលគ្នាជាអ្នកធុនល្មមរកលុយកាក់ទិញបាន ។
- បើគ្មានអក្សរទេ គោងរឿងនាឲ្យងាយយល់តាមរូបភាពនោះតែម្តង ។

សៀវភៅប្រភេទនេះ បើនិយាយឲ្យចំ ពីមុនមកពុំទាន់មានសោះនៅឡើយក្នុងប្រទេសយើង យើងធ្លាប់ឃើញតែបរទេសគេធ្វើរបស់គេ

មកលក់គរគោកនៅស្រុកយើងទៅវិញ ។ នៅសម័យកម្ពុជាថ្មី ការកសាងជាតិត្រូវបិតនៅលើមូលដ្ឋានសេរីភាព ប្រជាធិបតេយ្យពិតប្រាកដ យើងគួរតែមានសៀវភៅបែបនេះឲ្យគ្រប់គ្រាន់ហើយឲ្យទាន់ពេលវេលាផង ព្រោះកុំឲ្យកុមារយើងនៅខ្វះសម្ភារៈអប់រំ ដែលទុកដូចជាចំណីអាហាររបស់វាដែរនោះឡើយ ។ បានជាយើងពោលដូចនេះ ព្រោះយើងសង្កេតឃើញ ក្មេងតូចៗ ចូលចិត្តមើលរូប មើលពណ៌ប្លែកៗ មើលផ្ទាំងគំនូរ ពិសេសគឺពណ៌ស្រស់ដែលទាក់ទាញអារម្មណ៍វាមួយភ្លែតៗ ។ ត្រង់ចំណុចហ្នឹងឯង ដែលយើងសង្កត់យកជាការឲ្យណាស់ ត្បិតវាចូលចិត្តរបស់នេះស្រាប់ ពុំបាច់យើងណែនាំវាឲ្យចូលចិត្តទេ យើងគ្រាន់តែច្នៃរបៀបការចូលចិត្តរបស់វានោះ ឲ្យត្រូវផ្លូវទៅតាមគន្លងដែលយើងចង់ពត់ទិសយកវា តែម្តងទៅ ជាការស្រេច ។

សេចក្តីរាប់រៀបនេះ គ្រាន់តែជាការល្បងគិតមួយដំហានសិន ដរាបណាយើងស្រុះស្រួលគ្នាថាមតិនេះត្រូវល្មមទុកជាគោលការណ៍ហើយ សឹមយើងគិតគូរគូសវាសផែនការ ដើម្បីអនុវត្តគោលការណ៍នេះតទៅទៀត ។ ជាពិសេសក្រសួងអប់រំជាតិ ដែលមាននាទីយ៉ាងទូលំទូលាយក្នុងមុខងារដ៏ធំនេះ ពិតជាមានមធ្យោបាយល្អប្រពៃ សម្រាប់អនុវត្តគោលការណ៍នេះ ឲ្យបានសម្រេចមិនខាន ។

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា

## ងួ - ហ៊ន

## ប្រែ - រៀបរៀង

## (ត)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ខុងបេងថា: អ្នកឯងកុំអាលតូចចិត្តដៀតទៅក្រោយគេប៉ុណ្ណោះ ឯម៉ាចេកនិងអងបេង កោសៀងនោះ មុខជាតស៊ូនឹងទៀវខាប់ពុំបានទេ, អ្នកលើកទ័ពទៅក្រោយគេគ្រានេះ តាមដោយរ៉ះឃើញថានឹងបានគុណគាប់ម្តងទៀត, ព្រោះតម្បន់កេតេងនោះ អ្នកកុំអាលថាជាទីតូចបង្អៀតឥតតម្លៃឡើយ, បើប្រទះហើយគង់យល់ថាជាទីសំខាន់ណាស់, អ្នកកុំស្រាលរហ័សធ្វេសប្រមាទ ចូរខំសង្វាតយកចិត្តគិតត្រួតត្រាការពារឲ្យមាំចុះទើបនឹងមិនអន្តរាយ, អ៊ុយអៀនបានស្តាប់ ក៏មិនទាន់អស់ស្ងាយ, ខំប្រើកិរិយាគោរពយដោយខ្វាបខុងបេង ក៏គំនាប់លើកទ័ពចេញទៅ លុះដល់ហើយ ក៏ចាត់ទាហានឲ្យពួន បង្កប់ផ្កាប់ក្រោយទីកេតេងតាមខុងបេងបង្គាប់ ។

ទើបខុនបេនឲ្យហៅជូឡុងនិងគេងដីមកបង្គាប់ថា : អ្នកចូរនាំកងទ័ពទៅបញ្ឆោតទ័ពសុម៉ាអ៊ីនៅតម្បន់អំកុក ព្រោះបើមិនបានតទល់មុខច្បាំងគ្នាក្តី, គង់តែពលសុម៉ាអ៊ីនឹងព្រួញញញើតដៃមិនខាន, ខ្ញុំឯងនឹងលើកទ័ពហ្លួងភាំងប៉ុន្មានស្រុតទៅស្រុកប៉ៃសៀតែម្តង, បើវាយបានស្រុកប៉ៃសៀហើយ, មិនលែងឡើយនឹងបានស្រុកទៀងអាន់ទៀត, ជូឡុងនិងគេងដីក៏ទទួលបង្គាប់គំនាប់លាខុនបេនលើកទ័ពទៅ ឯខុនបេនតាំងកៀងអ៊ុយជានាយកងទ័ពមុខហើយ ក៏លើកព្រមគ្នាចេញទៅពីទីក្តីសាន ។

កាលម៉ាចេកលើកទ័ពទៅដល់តម្បន់កេគេង ក៏សង្កេតមើលកន្លែងភូមិឋានហើយ ក៏អស់សំណើចថា: តម្បន់ទីនេះមានជ្រោះជ្រលងដងព្រៃក្តីច្រើនអន្លើ ណាឡើយសុម៉ាអ៊ីរកវេចូលមកបាន មិនគួរបោះឧបកដនឹងរំខានព្រួយបារម្ភសោះ អងបេងឆ្លើយថា: ឯតម្បន់កេគេងនេះ គួរមកោឧបកដនឹងកំដាប់ប្រាប់ឲ្យប្រុងប្រយ័ត្នបែន ព្រោះជាទីបង្កៀតញាតស្បាតខុសនឹងទីដទៃ, យើងកុំគប្បីប្រមាទ, សុំឲ្យលោកទំនុកហាតហាត់-ការឲ្យឆ្លើបដ្ឋាយធំពាសពាត់ផ្លូវនេះទកចុះ, នឹងមិនខុសព្រោះមានផ្លូវតូចៗបែកជា ៥ ចំមកលើផ្លូវ ១ នេះ ជួបគ្នាជាដើមផ្លូវទៅពីនេះទៅ បារម្ភក្រែងមានសត្រូវលបលើកវាយពែញកប្រសព្វចូលមកនឹងកេសង្គ្រលប់ចូលបាន គួរឲ្យស្មានកុំខកបិត្តឲ្យសោះ ។

ម៉ាចេកថា: ដែលនឹងបោះបន្ទាយកាយទទឹងផ្លូវនៅត្រង់នេះគ្មានទំ-នៀមទេ ព្រោះមានភ្នំនៅមុខផ្លូវនេះចំពោះជាគោល ១ ហើយ នៅជើង

ភ្នំ  ក៏មានព្រៃធំជាប់បាំង  ដូចនេះតាមកន្លែងតាំងជ័យភូមិឲ្យយើង ។ គួរនឹងលើកទាហានឡើងទៅបោះបន្ទាយលើកំពូលភ្នំនឹងមិនស្រួលទេឬ ? អង់បេងថា:  ដែលនឹងបោលទ័ពសំខាន់ត្រង់ណោះ  លះទៅធ្វើលើភ្នំមិនសមសោះ,  ខ្ញុំមិនឃើញផងទេ  បើតាំងបន្ទាយបិទផ្លូវធំជាមេនៅត្រង់នេះ ទោះបីសត្រូវជាងនេះ  នឹងលើកពលដល់មុឺនសែនមកកាន់កិនយ៉ាងណា ក៏ឃើញថានឹងពារទំលាយទៅមិនបាន,  បើលោកនឹងនាំទាហានទៅតាំងលើកំពូលភ្នំឲ្យបាន,  សត្រូវដឹងនឹងលើកទាហានទៅឡោមព័ទ្ធវិញ  នឹងមិនទាល់តែចុះចេញមិនរួចទេឬ ?  ។

ម៉ាចេកអស់សំណើចហើយថា:  អ្នកនិយាយយ៉ាងនេះដូចជាទាល់តម្រិះប្រាជ្ញា  ឧបមាដូចស្រីខ្វីគំនិតណាស់,  បុរាណចាស់ទុំនិយមទុកមកថា  បើនឹងធ្វើសង្គ្រាមឲ្យព្យាយាមរកទីខ្ពស់ស្រឡះ,  ទើបនឹងរឹតតបឈ្នះបច្ចាមិត្រមិនបង់ប្រៀប  បើនឹងធៀបដូចគេពុះឬស្សីដូច្នោះ  ទោះស៊ូម៉ាអ៊ីលើកមកយើងនឹងដេញចម្រុះឲ្យចុះទៅយ៉ាងឆាប់  មិនឲ្យមានក្រើសជាប់នៅនឹងខ្លួនបានឡើយ  ។

អង់បេងថា:  បុរាណក៏មានពោលទុកមកហើយថា  ធ្វើសង្គ្រាមឲ្យព្យាយាមរកទីខ្ពស់ក៏មែន,  តែថាបើយើងគ្រានេះទៅនៅលើភ្នំ  បើសត្រូវលើកព័ទ្ធជុំបិទបាំងផ្លូវទឹកអស់,  តើពលយើងនោះនឹងចុះទៅផឹកឯណាបាន  បើយ៉ាងដូច្នេះចាសបុរាណមានថាយ៉ាងណាទៅទៀត,  ម៉ាចេកថា:  អ្នកនេះមិនទាន់ចេះធ្វើការសឹកសោះ  ព្រោះបុរាណថាធ្វើ

សិកឲ្យទឹកទៅរកទីស្លាប់ជាមុន រួចសឹមគន់រកទីរស់ជាក្រោយ, បើសត្រូវហោមព័ទ្ធយើងមិនឲ្យពលចេញទៅរកទឹកផឹកបាន ក៏ដូចគេមានទោសជាប់គុក មុខជាទាហានយើងស្ទុះទំលាយមិនងាយនឹងទ្រាំនៅអត់ទឹកនោះឡើយ, ម៉្លោះហើយនឹងកើតក្រដួរខឹងប្រឹងស្មើដៃគ្នា ទោះតែម្នាក់ៗ ក៏អាចតស៊ូនឹងគេដល់ហោធាបាន គង់នឹងទំលាយមិនក្រប៉ុន្មានទេ យើងបានគិតគ្នាតាមក្បួនពិជ័យសង្គ្រាម ដែលព្យាយាមរៀនមកឃើញសព្វគ្រប់ហើយ, សូម្បីមហាឧបកដ ក៏បានប្រឹក្សាឲ្យដោះឆ្លើយមិនដែលទើសទាល់ទោះ, ហេតុម្តេច ក៏អ្នកនៅមិនអស់ចិត្តមកគិតមើលងាយយើងនៅដែទទឹងដូច្នេះ ៗ

អងបេងថា: បើលោកមិនយកតាមពាក្យខ្ញុំ ខំតែលើកទាហានឡើងទៅតាំងលើកំពូលភ្នំ ក៏តាមអធ្យាស្រ័យលោកចុះ, សុំឲ្យបែងរំលែកទាហានឲ្យខ្ញុំបាទតែពាក់កណ្តាលប៉ុណ្ណោះ ខ្ញុំបាទនឹងបានកាប់ក្តារពាំងទុកតាមកម្លាំង ខណៈកាលកំពុងនិយាយជជែកគ្នា មានពួកអ្នកស្រុកព្រៃលើ ៩ គងបែកធ្ងុងរត់មកដល់ប្រាប់ថា ឥឡូវសុម៉ាអ៊ីលើកទ័ពជិតមកដល់តម្បន់នេះហើយ ម៉ាចេកឮដូច្នោះ ក៏ពិគ្រោះនឹងអងបេងថា: យើងនឹងបែងរំលែកទាហានឲ្យអ្នក ៥ ពាន់ ចូរអ្នកនាំទៅតាំងឲ្យទាន់ការចុះ សល់ពីនោះយើងនឹងនាំឡើងទៅតាំងលើកំពូលភ្នំ, បើយើងបានចំកម្ចាត់សត្រូវមានជ័យជម្នះវេលានេះ យើងមិនត្រូវការលើកគុណគាប់ឲ្យដល់អ្នកផងទេ អងបេងទទួលពលចំណែកខ្លួនហើយ ក៏លើកទៅតាំងនៅឆ្ងាយ

ពីភ្នំប្រមាណ ១០០សិន (៤គី.) ទើបតាំងគូព្រោងជាផែនទីបាត់បម្រើ នាំស្រូវទៅជូនខុងបេង ។

ឯសុម៉ាអ៊ី ក៏ប្រើសុម៉ាជៀវជាបុត្រឲ្យនាំពលចេញទៅស៊ើបល្បាត ស្តាប់ដំណឹង, បើទឹងដល់ទៅតម្បន់កេតេងហើយ កុំរាលជ្រួលជ្រើម ត្រូវត្រៀមបង្អង់មើលកលការ, បើឃើញខុងបេងបាត់ពលយោធាទៅតាំង នៅទីនោះហើយ, ត្រូវវិលទៅប្រាប់ឲ្យឆាប់វិញ, នោះសុម៉ាជៀវ ក៏នាំ ពួកល្បាតចេញទៅ, ឃើញទាហានខុងបេងទៅតាំងនៅតម្បន់កេតេង ក៏ ត្រឡប់ទៅថ្លែងប្រាប់សុម៉ាអ៊ីជាបិតា ។

សុម៉ាអ៊ីដឹងការ ក៏ដកដង្ហើមធំថា : ខុងបេងនេះប្រាជ្ញាយល់ការ រហូតមិនសល់សោះ, បំពោះដូចទេវតា ប្រាជ្ញាយើងមិនយល់ដល់ឡើយ, សុម៉ាជៀវតបឆ្លើយថា : ហេតុម្តេចបិតាប្រញាប់ព្រួយម្ល៉េះ, ខ្ញុំបាទឃើញ ថាតម្បន់កេតេងនេះ, បើទឹងច្បាំងយកតាមតម្រិះ ក៏បានដោយងាយមិន ព្រួយអ្វីទេ ។

សុម៉ាអ៊ីសួរថា : ម្តេចក៏ចៅហ៊ានប្រមាទដូច្នេះ ? សុម៉ាជៀវឆ្លើយ ថា : ខ្ញុំបាទទៅល្បាតឃើញហើយ, តម្បន់កេតេងនោះ, ទាហានខុង-បេងនឹងបានតាំងបន្ទាយត្រង់ទីសំខាន់ក៏ទេ, គឺឡើងទៅតាំងនៅលើកំពូល ភ្នំ, សុម៉ាអ៊ីឮដូច្នោះ ក៏សោមនស្សក្នុងចិត្តណាស់ថា បើដូច្នោះ ក៏ហាក់ ដូចទេវតាជួយយើងឲ្យបានសេចក្តីគាប់ប្រសើរពិត, ហើយសុម៉ាអ៊ី ក៏តែង ខ្លួនសម្តែងវិធីពាក់ក្រោះឡើងជិះសេះនាំទាហាន ១០០ ពាន់ ស្រូតទៅ

មើលដល់តម្បន់កេតេង ស្វែងត្រូតមើលប្រកល្អកនឹងលើកចូលបេញនៅទីកំនោះ, ហើយក៏ត្រឡប់មកវិញ ។

ខណៈនោះ, ម៉ាបេក ក៏បង្គាប់ពួកទាហានថា: បើយើងកងទ័ពសុម៉ាអ៊ុលើកមកដល់តម្បន់នេះហើយ, ឃើញយើងបោកទង់វេលាណា, ឲ្យអ្នកពល់គ្នាស្រុះស្រួល ចុះពីលើភ្នំទៅតដៃវាយបំបែកទ័ពសុម៉ាអ៊ីឲ្យបាន ។

ឯសុម៉ាអ៊ីនោះ, លុះត្រឡប់ទៅដល់ទីឋាន ក៏នៅមិនទាន់ច្បាស់ថាទីតម្បន់កេតេងនោះ នរណាអេះជានាយទ័ពលើកទៅតាំងនោះ, ទើបចាត់បម្រើម្នាក់ឲ្យទៅស៊ើបយកការ, បម្រើទៅស៊ើបហើយ ក៏វិលសាមកប្រាប់ថា នាយកងទ័ពឈ្មោះម៉ាបេកជាប្អូនម៉ាលៀងលើកទាហានមកតាំងនៅទីកេតេងនោះ, សុម៉ាអ៊ីឮដូច្នោះ ក៏អស់សំណើចថា ម៉ាបេកនោះប្រាកដក៏តែឈ្មោះ, ឯតម្រិះនឹងថ្វីដៃជាមនុស្សអប្រិយប្រាជ្ញា, ខុងបេងប្រើមនុស្សមិនជាការកំឡៅដូច្នេះគង់ខូសការជាប្រាកដ ហើយទើបសួរទាហានថានឹងលើកទៅតាំងនៅទីនោះ តែម៉ាបេកមួយកងទេឬ ។ មានទាហានតាំងនៅទីណាខ្លះ, ទាហានឆ្លើយថា អងបេងនាំទាហានទៅតាំងនៅឆ្ងាយពីភ្នំប្រហែលផ្លូវ ១០០ សិន មានបន្ទាយមួយ ។

សុម៉ាអ៊ុក៏ ចាត់ឲ្យទៀវខាប់លើកទ័ពទៅស្កាត់ផ្លូវខាំងទុក ដើម្បីមិនឲ្យអងបេងលើកមកជួយគ្នាបាន, ហើយឲ្យស៊ុនតាំនឹងសុទធិ ២ នាយលើកទាហានទៅស្កាត់បិទផ្លូវដែលទាហានម៉ាបេក នឹងលើកចុះមកដងទឹកផឹកនោះឲ្យបាន, ហើយបង្គាប់ថា បើឃើញយើងធ្វើការបានចំណាប់

ហើយ, ត្រូវឲ្យជួយគ្នាជាប្រញាប់ ស៊ុម៉ាអ៊ីបាត់កងទ័ពស្រេចពីពេលកណ្ដាលយប់ លុះភ្លឺស្រាង ក៏ឲ្យលើកទ័ពចេញទៅ កងទ័ពស៊ុម៉ាអ៊ី ក៏តាំងនៅព័ទ្ធជុំភ្នំ ។

ឯម៉ាចេកឃើញទ័ពស៊ុម៉ាអ៊ីលើកមកព័ទ្ធភ្នំជុំវិញហើយ ក៏បោកទង់សញ្ញាឲ្យពលយោធាទាំងអស់ចុះមកទម្លាយទ័ពស៊ុម៉ាអ៊ី, ទាហានម៉ាចេកឃើញសឹកសត្រូវព័ទ្ធនៅច្រើនណាស់ ក៏នឹកខ្លាចពុំអាចប៉ះពារទម្លាយចេះតែភ័យរាយរែកបែកគ្នា ម៉ាចេកឃើញទាហានរួញរាមិនហ៊ានចូលទៅប្រកាប់ប្រចាក់ ក៏នឹកខឹងលើសលុប ស្ទុះទៅកាប់នាយទាហាន ២ នាក់ស្លាប់នៅទីនោះ ពួកទាហានឃើញដូច្នោះ ក៏ភ័យខ្លាចជ្រួលច្របល់ ម៉ាចេក ក៏ស្ទុះទៅតទល់នឹងទ័ពស៊ុម៉ាអ៊ីជាសន្ធឹកសន្ធាប់ ទ័ពស៊ុម៉ាអ៊ី ក៏ចូលប្រកាប់ជាប់ដៃឥតភ្លឹកសោះ បិទផ្លូវមិនឲ្យមានចន្លោះច្រកត្រង់ណា ទាហានម៉ាចេកនឹករអារពុំហ៊ានពារទម្លាយ នាំគ្នារត់ព្រាត់ព្រាយថយឡើងទៅវិញ ម៉ាចេកឃើញដូច្នោះមិញ ក៏នឹកតូចចិត្តគិតទោមនស្សពន់ប្រមាណ ប្រមូលទាហានឡើងទៅនៅលើកំពូលភ្នំចាំមើលគេលើកទ័ពទៅជួយ ។

ឯអងបេងឃើញស៊ុម៉ាអ៊ីលើកទ័ពទៅព័ទ្ធភ្នំដូច្នោះ ក៏លើកទាហានទាំងអស់នឹងទៅជួយម៉ាចេក លុះលើកទៅ ក៏ប្រទះនឹងទ័ពទៀវខាប់ជាពន្លឹកមហិមាពាំងទទឹងផ្លូវ នោះទាហានខាងសត្រូវ ក៏ចូលច្បាំងតាំងប្រយុទ្ធគ្នា ទាហានទៀវខាប់ចេះតែពាំងរាំងមិនឲ្យចូលទៅបាន ក៏ថយត្រឡប់ទៅវិញ ស៊ុម៉ាអ៊ី ក៏ជាប់ត្រួតត្រាឲ្យពលយោធានៅព័ទ្ធភ្នំពុំថយសោះ, តាំងពីព្រឹក

លុះថ្ងៃត្រង់ ទាហានម៉ាបេកបេះតែស្រេកទឹកទាំងអស់គ្នា នឹងចុះមកដងទឹកទៅបរិភោគក៏ពុំបាន ពលទាហានក៏កាន់តែរសេះរសោះអស់កម្លាំងណាស់ ខ្វះទ្រាំមិនបាន ក៏នាំគ្នាលបគេចរត់ចុះទៅចូលខាងទ័ពស៊ុម៉ាអ៊ីជាច្រើន, ឯទាហានដែលសល់នៅលើកំពូលភ្នំនោះ ស៊ុម៉ាអ៊ី ក៏បង្គាប់ឲ្យពលទាំងអស់ឈូលភ្លើងឲ្យឆេះកលឡើងទៅ ទាហានម៉ាបេក ក៏ភ្ញាក់ផ្អើលដោយក្តៅរត់ប្រទាក់ប្រទូនលើគ្នា ម៉ាបេកស្លុតតក្កមានឹងទ្រាំតទល់ពុំបាន ក៏នាំទាហានពានទម្លាយរត់ចុះទៅ ស៊ុម៉ាអ៊ីក៏ក្លែងឲ្យទាហានញែកបើកផ្លូវឲ្យម៉ាបេករត់ទៅបាន ។

ទៀវខាប់ឃើញម៉ាបេកបែកទ័ពរត់បំពានចុះមក ក៏លើកទាហានដេញដិតប្រកិតពីក្រោយឲ្យបាប់ម៉ាបេក, ទទួលអ៊ុយអៀនចេញទាហានគគ្រឹកមកជួយទាន់, ក៏ករពានទៅការយកខ្លួនម៉ាបេកបាន, ហើយអ៊ុយអៀនស្ទុះបំពានទៅប្រយុទ្ធគ្នានឹងទៀវខាប់ ៗ តស៊ូមិនបាន ក៏ថយរត់ទៅ, អ៊ុយអៀនបានចំណាប់ ក៏ដេញប្រដាប់តាមទៀវខាប់ទៅនឹងដណ្តើមយកទីកេតេងវិញ, លុះស្រូតតាមទៅចម្ងាយផ្លូវប្រហែល ៥០ សិន (២ គ.ម.) ប្រទះឃើញស៊ុម៉ាអ៊ី, ស៊ុម៉ាដៀវ លើកទាហានមកបង្កប់ត្រឡប់ចេញពីព្រៃមកខ្ទប់អ៊ុយអៀនសងខាងផ្លូវ, ទៀវខាប់ឃើញដូច្នោះក៏ត្រឡប់វកទៅតទឹងអ៊ុយអៀន ៗ ក៏នៅក្នុងចំណោម បេះតែវិលតព្រមទាំង ៣ ជ្រុងពុំរង់ក ។

ខណៈនោះទ័ពអ៊ុយអៀនក៏មរណាប្រហែលពាក់កណ្តាល, ទទួលអងបេងលើកទាហានមកដល់ ឃើញស៊ុម៉ាអ៊ីព័ទ្ធអ៊ុយអៀនជាប់នៅកណ្តាល

ពួកពល, ក៏ចូលបំពារទៅជួយអ៊ុយអៀន ។ ឃើញអង់បេង ក៏មានគំណរថា ទីនេះយើងមិនស្លាប់ទេ, តាំង ២ នាយ ក៏វាយកាប់ចាក់ទ័ពសុម៉ាអ៊ីស្លាប់ដេរដាសច្រើនណាស់, សុម៉ាអ៊ីនិងសុម៉ាជៀវ ទៀវខាប់ ក៏ថយទ័ពទៅវិញ, អ៊ុយអៀននិងអង់បេង ក៏នាំគ្នាចូលទៅក្នុងបន្ទាយ លុះទៅទឹងដល់ក្រឡេកយល់ឃើញទង់ដោតដេរដាសលើសេនច្រើនណាស់ ដឹងច្បាស់ជាសត្រូវដណ្តើមយកបន្ទាយបាន ទើបឲ្យទាហានបង្អង់នៅ ។

ឯស៊ុនតាំនិងស៊ុនងីដែលចូលទៅនៅក្នុងបន្ទាយនោះ លុះឃើញអ៊ុយ-អៀងនិងអង់បេងត្រឡប់តម្រង់ទឹងចូលបន្ទាយ, ក៏វាយទាហានតទល់ខ្ទប់ អ៊ុយអៀន អង់បេង ក៏ត្រឡប់រត់ទៅរកកោសៀងឯស្រុកលីវសៀ ខណៈនោះកោសៀងដឹងថា តម្បន់កេតេងបែក ក៏ញែកទាហានលើកទៅជួយ, ទទួលប្រទះនឹងអ៊ុយអៀន, អង់បេងបែកទ័ពត្រឡប់រត់មក ក៏សាកសួរដឹងសេចក្តីគ្រប់ប្រការហើយថា ក្នុងពេលយប់នេះ, យើងត្រូវជួយគ្នាលើកទ័ពទៅលុកយកបន្ទាយកេតេងវិញឲ្យបាន, លុះប្រឹក្សាយល់ព្រមគ្នា វេលាយប់ ក៏ញែកកងទ័ពជា ៣ កង, ឲ្យអ៊ុយអៀនជាកងមុខ, កោសៀងជាកងក្រោយ ។

លុះអ៊ុយអៀនលើកទៅដល់តម្បន់កេតេង ឃើញតែបន្ទាយសូន្យធេងទទេគ្មានមនុស្សសោះ ក៏ពិគ្រោះឃើញថា សុម៉ាអ៊ីប្រើកលទឹកពិភាល់ណាស់ ឲ្យទាហានតាំងអស់នៅទីនោះ កោសៀង ក៏ស្រូតលើកទ័ពមកទាន់គ្នាប្រឹក្សាយល់ថា យើងលើកទ័ពមកដល់យល់ឃើញតែបន្ទាយទទេ,

មិនបានឃើញសុម៉ាគ៊ីជាមេសម្រេចពជការ និងតាំងទៅឯណា គឺមិនច្បាស់ មួយទៀត អង់បេងក៏នៅមិនដឹងការលើកពលយោធាមកមិនទាន់ដល់ ថា មិនទាន់ផុតមាត់ ស្រាប់តែព្រួសូរផាវអុជឡើង, ទាហានស្រែកហ៊ោអឺងកង កក៏ភ័យណាស់ ក្រឡេកទៅឃើញពន្លឺភ្លើងភ្លឺច្បាស់ គេះពលមកដល់ត្បែរផ្លូវ ទាហានទាំងអស់ ក៏ស្ទុះទៅរកគ្នា សុម៉ាគ៊ី ក៏បរពលយោធាព័ទ្ធកោ-សៀងនិងអ៊ុយអៀនជុំវិញ អ៊ុយអៀននិងកោសៀងនោះមិញ ក៏ដេញទាហានចូលប្រយុទ្ធអាវុធនិងអាវុធព័ទ្ធពាក់លើគ្នា អង់បេង ក៏លើកពលយោធាមកដល់ជើងភ្នំ ឃើញកោសៀង, អ៊ុយអៀន ប្រជាប់និងកងទ័ពធំ សុម៉ាគ៊ី ក៏ឲ្យអុជផាវសញ្ញាដេញពលយោធាចូលចោមវាយជួយកោសៀង និងអ៊ុយអៀន ពួកទាហានក៏វិនាសស្លាប់ជាច្រើនណាស់ អង់បេង ក៏ប្រឹងជួយដោះយកខ្លួនកោសៀងនិងអ៊ុយអៀនចេញពីចំណោមបាន ហើយនាំគ្នាប្រមូលទាហានរត់ទៅស្រុកលិវសៀ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

## របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សាល់

## (ត)

## វគ្គទី ៥០

ខណៈលោកយាយក្រេមនការី ក៏ហៅកូនប្រុសគាត់មកប្រាប់ អំពីរឿងដែលគាត់បានស្ដីដណ្ដឹងកូនគេ ថាគេព្រមឲ្យហើយ ពុទ្ធូប្ដោះលោកញញឹម រួចឆ្លើយតបទៅវិញ :

–ឃើ! និយាយត្រូវគ្នាអស់ទៅហើយ ? ម៉ែធ្វើការអីក៏លឿនម្ល៉េះ?

ម្ដាយពេញចិត្តនឹងនាងហិមណាលីនីណាស់កូន ។ ម្ដាយឃើញកូនហ្នឹង ដូចជាថ្ងូរអំពីក្មេងដទៃ ៗ តាមពិតគឺជាមិនខ្វះទេ ស្រីដែលល្អជាងនាងនេះ ហើយនាងនេះថែមទាំងអន់សម្បត្តិផង ប៉ុន្តែ . . .

–សុំទោសម៉ែ ខ្ញុំមិននិយាយពីរឿងខ្លួនទេ តែខ្ញុំរៀបការជាមួយនឹងនាងមិនបានទេ !

–ចុះរឿងអ្វី បានជាកូនឯងរៀបការជាមួយនឹងនាងមិនបាន ?

ង៉ាយអ៊ឹងពន្យល់មាតាលោក ឲ្យយល់ច្បាស់ ថាលោករៀបការជាមួយ

នាងម្ដេចបាន បើនាងទុកលោកដូចជាឪពុកឬដូចជាគ្រូទៅហើយ មើលទៅដូចជាពិបាកនិយាយពេក លោកក៏ស្ងៀមសិនទៅ ។

តែលោកយាយយល់ថា កូនគាត់សុខចិត្តហើយ ពីព្រោះមិនឮប្រកែកគ្នាទៀត ។

−ម្ដងនេះឯងកុំមកប្រកែកគ្នាទៀតឲ្យសោះ ម៉ែលែងស្ដាប់កូនឯងហើយ ដូចជាហួសហេតុពេកណាស់ អាយុប៉ុណ្ណឹងចង់ធ្វើតាមស ម្ដាយមិនព្រមជាដាច់ខាត ។

−ខ្ញុំមានរឿងមួយត្រូវជម្រាបម៉ែ ហើយខ្ញុំសុំចិត្តម៉ែកុំឲ្យបារម្ភឲ្យសោះ ព្រោះរឿងដែលខ្ញុំនឹងជម្រាបម៉ែនេះ ជារឿងចាស់ ដែលកើតឡើងប្រហែលមួយឆ្នាំទៅហើយ បានជាថា បើម៉ែព្រួយទៅ ក៏ឥតអំពើដែរ ។ ខ្ញុំដឹងថា សតិម៉ែឆាប់រំភើបណាស់ ទោះជាការភ័យនោះ ហួសបាត់ទៅហើយ ក៏ម៉ែនៅតែកាត់មិនដាច់ដែរ បានជាខ្ញុំមិនជម្រាបម៉ែមួយមាត់ណាសោះ ម៉ែខំចង់ស្រន់ឬធ្វើម្ដេច ឲ្យខ្ញុំរួចអំពីការឧបទ្រពចង្រៃក៏ដោយ ក៏ធ្វើទៅចុះ កុំតែដាក់ចិត្តស្ដាយឲ្យទៅទុក្ខជាលំអុកទ្រូង ។

−រឿងអីទៅកូន និយាយឆាប់មក កុំវល់បួរបត់ច្រើនពេក ម្ដាយភ័យណាស់ :

−ម៉ែចាំទេ កាលពីខែកុម្ភៈឆ្នាំទៅ ខ្ញុំបានលះបង់អតិថិជន[១]នៅ

១- ភ្ញៀវដែលមកពឹងការងារ ។

រង្គបូរីពេលសស់ ដើម្បីផ្លោះទៅកាន់ក្រុងកាល់កុត្តា ។ លុះធ្វើដំណើរមកដល់ផ្លូវបំបែក ត្រង់ស្រុកសាភ ខ្ញុំនឹកភ្នកចង់ជិះកប៉ាល់ម្ដង គឺចុះពីរថភ្លើងទៅបន្តដំណើរតាមកប៉ាល់ ។ ពីរថ្ងៃក្រោយមក ខ្ញុំក៏បានជួបនឹងមិត្តចាស់ខ្ញុំម្នាក់ឈ្មោះប៊ូប៉េន ធ្វើជាចាងហ្វាងក្នុងក្រសួងតុលាការនៅតំបន់នោះ ដែលមានដំណើរទៅត្រួតត្រាការក្នុងពេលនោះដែរ គេបានហៅខ្ញុំឲ្យទៅលេងនឹងគេ ហើយក៏នាំគ្នាទៅឈប់នៅភូមិដូបាពូរ ពេលល្ងាចគេបាននាំខ្ញុំដើរលេងមើលភូមិ-ស្រុក ហើយបានចូលទៅសំពកដើងនៅផ្ទះមួយ ។ ពនបរាណផ្ទះនោះ ជាសាលារៀនរបស់កូនអ្នកភូមិ គ្រូបង្រៀនអង្គុយលើដីទម៉ា ឯកូនសិស្សតូចៗ កាន់ក្ដារខៀនមួយ ។ ម្នាក់អង្គុយផ្ទាល់ដីជុំកន់ជុំវិញគ្រូ ។ នៅពេលនោះ តារីទីធគ្រូដ៏ជាម្ចាស់ផ្ទះ ចេះតែមានការសួរប៊ូប៉េនច្រើនពេក ទាល់តែពេលត្រឡប់មកវិញ ប៊ូប៉េនបែបសង្ស័យ ក៏ប្រាប់ខ្ញុំថា "ឯងមុខជាមានគេចង់ឲ្យកូនហើយ" ។ តារីទីធគ្រូដ៏ជាមនុស្សកេសុំអាវគេ ចង់ការប្រាក់យកមកថ្លៃម្ហូបប្រមាណ កំណាញ់កេមនុស្សប្រៀបគ្មានទេ ហើយឲ្យតែឮថាមានភ្នាក់ងាររាជការមកទីនេះភ្លាម គាត់ប្រញាប់ធ្វើបុកគាត់ជាអ្នកគិតដល់ប្រយោជន៍សាធារណ៍សម្បើមណាស់ គាត់ហៅកូនអ្នកស្រុក មកឲ្យរៀនពេញផ្ទះគាត់មួយរំពេច តែតាមពិត គ្រូបង្រៀននេះ គ្មានបានបង្រៀនកូនសិស្សទេ គាត់ឲ្យបាយពីពេលក្នុងមួយថ្ងៃ គ្រាន់តែជួយគិតបញ្ជីប្រាក់កាសឲ្យគាត់

ប៉ុណ្ណោះ ប្អូនស្រីគាត់មួយឈឺ គាត់ទុកឲ្យគ្នាស្លាប់ មិនខ្ចីទាំងមើលគ្នាផង ៗ នាងនោះស្លាប់ចោលកូនស្រីម្នាក់ ទុកឲ្យរស់នៅជាមួយគាត់វេទនាដូចសត្វដូចធាតុ សព្វថ្ងៃគាត់កំពុងតែរកប្ដីឲ្យក្មួយនោះ ដើម្បីឲ្យចេញផុតអំពីបន្ទុកគាត់ទៅ នាងក្មួយនោះ កាលនោះមានអាយុយ៉ាងតិចទៅហើយ តែគ្មានអ្នកណាចូលស្ដីសោះ ព្រោះគេមិនពេញចិត្តនឹងគ្រួសារ ១៨ ឆ្នាំ តារិនោះ ប៉ុន្តែក្មួយគាត់នោះ ល្អមែនទែន នាងឈ្មោះកាមាលា ៗ តែកាលណាមានអ្នកកាន់សាសនាដូចគាត់មកកាន់ទិន្នេះ គាត់បញ្ចុកបញ្ចៀឲ្យរៀបការនឹងក្មួយគាត់ភ្លាម គ្មានខ្លាចអ្នកណាសើចយំអីទេ ម្ដងនេះ ឯងជឿចុះ មុខជាដល់វេនឯងហើយ! ម៉ែអើយ កាលនោះខ្ញុំគ្មានបានគិតវែងឆ្ងាយទេ ខ្ញុំក៏ឆ្លើយទៅគេវិញភ្លាមទៅថា "មានអាសការអ្វី ខ្ញុំនឹងរៀបការជាមួយនាង" ៗ ប៉ូប៉េនបាត់មាត់ឈឹងដូចគេបុក ៗ

ល្ងាចថ្ងៃដដែលនោះ តារិនីត្រូវដើ មករកដែលខ្ញុំដល់ផ្ទះខ្ញុំសំណាក់ ហើយនិយាយអួតអំពីគុណសម្បត្តិរបស់នាងកាមាលា យ៉ាងយូរ ខ្ញុំជាក់ចិត្តនឹងសម្ដីគាត់ ហើយសុខចិត្តរៀបការជាមួយនាង ដោយមិនទាន់ទាំងបានឃើញរូបនាងផង ៗ លុះខ្ញុំប្រាប់គាត់ថា ឲ្យសម្រេចពីរឿងរៀបអាពាហ៍-ពិពាហ៍នៅថ្ងៃណា គាត់ឆ្លើយភ្លាមថា រៀបការខាងស្អែក ៗ ចុះអីក៏ឆាប់ម្ល៉េះ? គាត់សំអាងថាកុំឲ្យខាតសោហ៊ុយច្រើន ខ្ញុំក៏សុខចិត្តរៀបចំការជាមួយនឹងនាងនោះទៅ ៗ

- កូនការប្រពន្ធរួចទៅហើយ! (លោកយាយក្ដាត់មាត់ទាំងអស់សង្រ្វម) កូននិយាយមែនឬលេងហ្នឹង ?

- ពិតឥតក្លែងទេ ម៉ែ . . . រៀបការរួច ស្អែកឡើង ខ្ញុំធ្វើដំណើរតាមទូកជាមួយនឹងប្រពន្ធខ្ញុំទៅពេលរសៀល ព្រោះថា នៅខែមិនា ពេលល្ងាច ច្រើនអាកាសធាតុល្អ ប៉ុន្តែមិនដឹងជាចង្រៃអ្វីថ្ងៃនោះ ស្រាប់តែមានខ្យល់កំបុតត្បូងយ៉ាងសាហាវបណ្ដាលឡើង ធ្វើឲ្យលង់លិចអ៊ីៗ នៅក្នុងទន្លេគ្មានសល់ ខ្លួនខ្ញុំនេះក៏បានត្រូវព្យុះបោកទៅលើឆ្នេរខ្សាច់ តែគ្មានឃើញមនុស្សម្នាណាម្នាក់រស់សោះ ខ្ញុំបានទៅប្ដឹងក្រុមប៉ូលិស ប៉ុន្តែគ្មានរកខ្មោចអ្នកដំណើរណាឃើញមួយទេ . . . ។

លោកយាយក្រៀមក្រំ ឡើងមុខស្ងាំង

- ពុទ្ធោអើយ! "លោកដកដង្ហើមធំ" កូនអើយ កុំនិករឿងនេះមកប្រាប់ម្ដាយទៀត តែនឹកឡើងកាលណាម្ដាយញ័រខ្លួនអស់ហើយ

- បើកុំតែម៉ែបង្ខំឲ្យកូនរៀបការ កូនឥតនឹកនាំនិយាយជម្រាបម៉ែឡើយ ។

- ចុះបើរឿងនោះហួសផុតអស់ទៅហើយ ម្ដេចកូនទៅតែមិនព្រមរៀបការជាថ្មីទៀត គ្មានអ្នកណាដែលជួបតែរឿងស៊យ មួយជីវិតនោះទេ

- សុំជម្រាបម៉ែថា ចុះបើនាងការមាណមិនទាន់ស្លាប់ទេ គេមិន

សើចខ្ញុំទៅហើយ ធ្វើម្ដេចកើត បើយើងមិនទាន់ដឹងច្បាស់នៅឡើយ អំពីនាង ។

— ទេកូន ! បើនៅរស់ មិនលែងអីនឹងឮដំណឹងទេ តែឈឹងយ៉ាងនេះមានតែស្លាប់ !

— ម៉ែ ! នាងឥតទាន់ស្គាល់មុខខ្ញុំនោះទេ ហើយនៅពេលរៀបការខ្ញុំនឹកថា នាងប្រហែលជាមិនហ៊ានទាំងបើកភ្នែកមើលមុខខ្ញុំផង ដូច្នេះហើយបានជាខ្ញុំយល់ថា ចាំមើលមួយឆ្នាំសិន បើមិនលេចឮដំណឹងអ្វីទេ សឹមទុកនាងជាស្លាប់ទៅចុះ ។

— បើចាំក៏ចាំទៅចុះ ប៉ុន្តែក្នុងរយៈពេលចាំនោះ កូនគួរតែទទួលនាងហ៊ិមណាបទីជាគូដណ្ដឹងសិនទៅ ។

## វគ្គ ទី ៥១

តើនាងកាមាលាទៅជាយ៉ាងម្ដេចទៅហើយ ?

នៅពេលដែលនាងដើរទៅដល់មាត់ទន្លេគង្គា ព្រះអាទិត្យអស្ដង្គតក៏លិចផុតទៅដែរ នាងយកដៃក្បង់ទឹកមកស្រោចក្បាលតាមទំនាមឥណ្ឌា រួចដើរចុះទៅក្នុងទឹក លើកដៃទាំងពីរកាន់ផ្កាប្រណម្យដាក់លើក្បាល រួចលែងផ្កាចោលឲ្យអណ្ដែតទឹកទៅ ។ នាងទើបមកលើ

ប្រាំងវិញ ហើយអង្គុយសំពះស្ទឹងស្ទាក់ ចំពោះវត្តសក្តិសិទ្ធ យ៉ាងយូរ នាងនឹកក្នុងចិត្តថា នៅបុគ្គលមួយរូបទៀតដែលនាងត្រូវគោរព គឺប្តី ដែលបានរៀបការជាមួយនឹងនាង ហើយដែលនាងមិនដែលហ៊ានមើល មុខគេចំម្តងណាសោះ សូម្បីតែនៅពេលផ្សំដំណេក ក៏នាងពុំហ៊ាន មើលមុខប្តីនាងដែរ ។ ពេលបញ្ចប់កិច្ចអាពាហ៍ពិពាហ៍មង្គលការនោះ យប់ក៏ជ្រលបខ្ចិចទៅផង នាងនៅក្មេងមិនសូវធន់នឹងការងារ ក៏ឆាប់ គេងលក់ទៅ ទាល់តែព្រលឹមឡើងមិត្តស្រីម្នាក់ ដែលគេមានប្តីមុន នាង មកដាស់ ទើបនាងភ្ញាក់ នាងក្រោកឡើង គ្មានឃើញប្តីនៅ ក្បែរនាងសោះ ហេតុនេះហើយ បានជានាងមិនស្គាល់មុខប្តី រហូតដល់ ថ្ងៃនេះ ។

ឯសំបុត្រដែលកាមេស្ហសរសេរទៅនាងហ៊ិមណាលិទី នាងចងទុក នៅនឹងជាយសំពត់សារ៉ននាងនៅឡើយ ។ នាងលាសំបុត្រនោះមក មើលត្រង់កន្លែងដែលដាក់ថា ប្តីនាងឈ្មោះណាលីណាក់ស្ហាធត្ថប៉ាធ្យាយ ដែលជាគ្រូពេទ្យមួយរូបនៅវគ្គបុរី ។

ពាក្យថាណាលីណាក់ស្ហាជាថ្នាំម្យាង សម្រាប់លាបលើមុខរបួសនៃ ជេះដូងរបស់នាង នាងអង្គុយទឹកសង្វេគ បង្ហូរទឹកភ្នែករហាមឥតគាក់ ហើយនឹកក្នុងចិត្តថា " កន្លែងផតផ្សាវនេះត្រូវបានពេញវិញហើយ ភាព ងងឹតអន្ធការក៏បានភ្លឺស្វាងឡើងវិញដែរ ឯរូបខ្ញុំនេះទៀតសោតក៏មាន

នាទីជាអ្វីមួយក្នុងចំណោមសត្វលោកទាំងឡាយដែរ ហើយនាងខំបួងសួងសុំឲ្យបានជួបនិងបុគ្គល ដែលនាងត្រូវធ្វើបក្ការៈបូជាអស់មួយជីវិត ព្រោះថា ព្រះលោកបានទុកជីវិតនាងដើម្បីបម្រើអ្នកនោះហើយ បានជានាងមិនស្លាប់... នាងយកបង្កោមសារបោះចោលទៅឆ្ងាយក្នុងទឹក ព្រមទាំងកន្ទះដែលកាមេស្នហបានទិញឲ្យនាង រួចដើរសម្ដៅទៅបស្ចឹមទិស នាងគ្រាន់តែនឹកថា នាងត្រូវតែចេញឲ្យផុតអំពីទីនេះ តែនាងមិនដឹងជាត្ពោះទៅទីណា.... ។

រាត្រីកាលនៃសិសិររដូវក៏សន្សឹមចុះមក គ្របផ្ទៃផែនដីតសូន្យ មើលទៅផ្ទៃមេឃដែលពាសពេញដោយតារាដេរដាស កំពុំមានរស្មីប៉ុន្មានព្រោះខ្វះព្រះចន្ទ ។ នាងកាមាលាមើលទៅមុខមិនឃើញអ្វីឆ្ងាយទេ តែនាងត្រូវតែដើរទៅមុខទាំងមិនដឹងថាមានអ្វីទៅទីនោះផង ។ ដើម្បីជៀសការសួរនាំអំពីអ្នកស្រុក នាងសុខចិត្តដើរតាមមាត់ទន្លេរហូត ហើយគិតក្នុងចិត្តជាស្រេចថា បើប្រសិនជាមានអាសន្ន នាងអាចលោតចុះក្នុងទឹកទន្លេនេះភ្លាមបាន ។

ភាពងងឹតនៅពេលរាត្រីពិតមែនហើយ តែមិនទាន់ដល់ទៅមើលផ្លូវមិនឃើញកាលណា លុះយប់កាន់តែជ្រៅ សម្លេងក្តែក្រលូបណ្តាញគ្នាក្នុងព្រៃឆ្ងាយក៏កាន់តែឮខ្លាំងឡើងៗ ។

នាងកាមាលាដើរតែម្នាក់ឯង តាំងពីព្រលប់តាមឆ្នេរខ្សាច់ ស្រាប់តែមកដល់កន្លែងមួយនោះ ទន្លេមានច្រាំងចោតខ្ពស់ ជាដីល្បាប់ទៅវិញ មើលទៅមុខឃើញកុម្ពមួយ នាងនឹកអរផ្អុក ៗ ក្នុងចិត្ត តែលុះនាងដើរទៅដល់ជិត អ្នកកុម្ពនោះដេកស្ងាត់ឈឹង នាងដើរព័ទ្ធមើលបន្តិចទាំងញញើត តែនាងអស់កម្លាំងណាស់ ទន់ជើងទន់ដៃ ក៏ទម្លាក់ខ្លួនគេងនៅក្រោមដើមឈើធំមួយលក់ទៅ ។

លុះនាងភ្ញាក់ខ្លួនឡើង ព្រះចន្ទលិចចុះអស់ជាងពាក់កណ្ដាលមណ្ឌលទៅហើយ នៅសល់ពន្លឺស្រាង ៗ ប្រឡំនឹងពន្លឺនៃសេតារុណ ។ យាយចាស់ម្នាក់ដើរមកក្បែរនាង សួរនាងថា :

– យប់ត្រជាក់ម្ល៉ឹង ម្ដេចនាងមកនៅធ្វើអ្វីក្រោមដើមឈើនេះ ?

នាងកាមាលាស្ទុះក្រោកយ៉ាងរហ័ស ងាកមើលជុំវិញខ្លួននាងឃើញទូកពីរចតនៅមាត់ទន្លេ មិនឆ្ងាយប៉ុន្មានពីជម្រកនាង ។ យាយចាស់នោះប្រហែលជាអ្នកដំណើរ គាត់ក្រោកពីព្រលឹម ដើម្បីលបមុខលបមាត់កុំឱ្យអ្នកស្រុកក្រោកទាន់ ។ យាយសួរបញ្ជាក់ថែមទៀតដូចជាឃ្លានចង់ដឹងណាស់ :

– នាងមានការដូចជាអ្នកបង្កាលីមែនទេ ?

ចាសមែន ! លោកយាយ

– ចុះម្ដេចក៏មកគេងនៅទីនេះ ?

– ចាស់ ! ខ្ញុំទៅបេណារេស ខ្ញុំអស់កម្លាំងពេក ខ្ញុំឈប់ទទួលទានដំណេកនៅទីនេះទៅ ។

– ពុទ្ធោ ! អ្នកណាដែលត្រូវទៅបេណារេសដែរ ឡើងជិះទូកនោះទៅ ចាំយាយដូតទឹករួច យាយទៅជាមួយដែរ ។

មួយសន្ទុះក្រោយមក យាយក៏ឡើងទៅលើទូកនោះដែរ គាត់និយាយរឿងរ៉ាវប្រាប់នាង ថាគាត់ទើបនឹងត្រឡប់មកអំពីផ្ទះបងប្អូនម្នាក់ឈ្មោះ ស៊ុឌុហាប៊ូ គេរៀបការកូនគេ ថាគាត់ឈ្មោះ ណាប៊ិនកាលី ប្ដីគាត់ឈ្មោះ មុគុណជាឡាលជាត្តា គាត់ជាអម្បូរកាយាស្ថ: គាត់កើតនៅបង្គាល តែគាត់មកតាំងទីលំនៅនៅបេណារេសតាំងពីយូរយាមកម្លេះ ។

នាងកាមាលាក៏ប្រាប់ឈ្មោះខ្លួនទៅលោកយាយវិញទាំងនិយាយរឿងខ្លួនថា នាងជាអម្បូរព្រាហ្មណ៍ ប្ដីនាងបានធ្វើមរណៈកាលមួយថ្ងៃក្រោយពេលដែលនាងរៀបការ នាងនិយាយបន្ថែមទៀតថា នាងទៅបេណារេសនេះ គ្មានបំណងអ្វីក្រៅអំពីទៅរកការធ្វើ ដើម្បីឲ្យមានដំបូលមួយជ្រកនឹងបាយចម្អែតពោះមួយថ្ងៃពីរពេលតែប៉ុណ្ណោះ ហើយនាងចង់រកនៅជាមួយនឹងគ្រួសារណា ដែលគេមានចិត្តសប្បុរសផង ព្រោះនាងចេះធ្វើម្ហូបចំណីល្មមក៏អាចបម្រើគេបាន ។

លោកយាយណាប៊ិនកាលីទឹកអរព្រួចក្នុងចិត្ត នឹងបានស្រីអម្បូរព្រាហ្មណ៍មកបម្រើគាត់ សុំតែបាយបរិភោគនឹងដំបូលជ្រកប៉ុណ្ណោះ តែគាត់ខំទប់មិនធ្វើឲ្យនាងដឹងទេ ?

ខ្ញុំមិនដឹងជាយកនាងទៅឲ្យធ្វើការអ្វីទេ ព្រោះខ្ញុំមានមនុស្សប្រើគ្រប់គ្រាន់ទៅហើយ ម្យ៉ាងទៀតខ្ញុំត្រូវការតែអ្នកចេះការមែនទែន ចុងភៅរបស់ខ្ញុំឯនោះគេស៊ីថ្លៃណាស់ ប៉ុន្តែបើនាងពិបាករកកន្លែងនៅ ទៅនៅផ្ទះយាយទៅ យាយធ្លាប់ចិញ្ចឹមមនុស្សទាំងគ្រួទៅហើយ ទោះជាលើសនាងម្នាក់ ក៏មិនមានការអ្វីដែរ ហើយនាងក៏មិនមានការអ្វីធ្វើច្រើនដែរ ព្រោះថា យាយនៅតែពីរនាក់ប្តីប្រពន្ធទេ កូនចៅយាយ គេមានប្តីសីចេញទៅតាមប្តីអស់ទៅហើយ សព្វថ្ងៃនៅសល់តែកូនប្រុសមួយទេ គេធ្វើជាសកាតបុរស តែគេឥតមាននៅជាមួយយាយទេ ឥឡូវនេះ ។

មិនយូរប៉ុន្មាន ដោយត្រូវជំនោរខ្យល់ជួនល្អ ទូកក៏បានមកដល់បេណារេស រួចគេនាំគ្នាឡើងឆ្ពោះទៅភូមិគ្រឹះមួយនៅក្រៅទីក្រុង មានទីធ្លាទូលាយជាសួនព័ទ្ធជុំវិញ តែគ្មានឃើញអ្នកធ្វើបាយណាសោះ នាងត្រូវក៏ប់ខាងជើងក្រានតែម្នាក់ឯង ។

លោកយាយណាប៊ិនកាលី ឧស្សាហ៍ហាមប្រាមនាងណាស់ មិនធ្វេសមាត់ទេ ។

- នែ ! បេណារ៉េស មិនមែនជាទីក្រុងសម្រាប់ក្មេងដូចនាងទេណា៎ កុំចេញទៅណាម្នាក់ឯងរហេតរហូត បើចង់ទៅងូតទឹក ចាំយាយទៅ សឹមទៅជាមួយយាយ ។

តាមការពិត គឺយាយគាត់ខ្លាចនាងចេញទៅក្រៅ ជួបនឹងស្រីៗឯទៀត គេបញ្ឆោតបញ្ឆុងនាងខានបានបម្រើគាត់ ។ ពេលថ្ងៃ គាត់រកការឲ្យនាងធ្វើ គ្មានសល់ពេលទំនេរ ពេលយប់គាត់និយាយអួតអំពីទ្រព្យសម្បត្តិគាត់ ទុកនៅឯបឹង្គាលី ឲ្យនាងស្តាប់ កុំឲ្យនាងយល់ថាគាត់អន់ គាត់និយាយថាគាត់មានបានមាស បានប្រាក់ គាត់មិនយកមកដោយខ្លាចគេលួច....... ។

- ផ្ទះយាយនៅឯនោះ ធំណាស់ ឈ្នួលបម្រើក៏ច្រើនរាប់មិនអស់ ប៉ុន្តែយកមក ឲ្យរស់នៅត្រង់ណា លោកតាខ្ញុំចង់ជួលផ្ទះជិតនេះដែរ តែខ្ញុំមិនព្រម ព្រោះខ្ញុំចាស់ហើយ ចង់ឲ្យស្ងាត់បន្តិច កុំឲ្យអ៊ូអរពេក ។

(នៅមានត)

# រឿង ចរទេព្យ-សុរទេព្យ

(ចម្លងពីសាស្ត្រាស្លឹករឹត)

លោក លី-ធាមតេង ស្រាវជ្រាវ-ពិនិត្យផ្ទៀងផ្ទាត់

---

## (ក)

### បទ កាកគតិ

បន្ទូលនោះណា ស្ដេចសូត្រគាថា ប្រសើរថ្កើងថ្កាន
យក្សភិតភ័យខ្លាច ពុំអាចនៅបាន រត់ចេញលលាន
ដូចផល់ហានក្រៅ ។
យក្សគិតឯងថា នេះអ្នកឯណា ឯងអាចមកនៅ
មណ្ឌលសាលា មោហាយោរយៅ បើអញចូលទៅ
សម្លាប់នេះម្ដង ។
យក្សយល់ភិតខ្លាច ពិតពុំបានអាច ទៅទៀតឡើយហោង
រីឯព្រះបាទ នរនាថកន្លង ស្ដេចបិត្រគង
ព្រះប្អូនថ្លាថ្លៃ ។
បន្ទូលត្រាស់ថា ហៃប្អូនស្នេហា ពន្លកហឫទ័យ
រីយក្សនោះណា មោហាពេកក្រៃ យើងនៅនេះន័យ
សមមកទៀតណា ។

បើតែបងឯង បងមិនគិតក្រែង ខ្លាចយក្សហឹង្សា
ឥឡូវមាសស្ងួន ខ្ញុំមខ្លួនពុំផា យក្សយល់ហើយណា
ក្រែងពុំកោតបង ។

គួរនឹងយាត្រា ចេញទៅនេះណា ទើបរួចរំលង
ពីយក្សហឹង្សា អាត្មាយើងហោង បើនៅនេះមួង
ពុំរួចឡើយណា ។

ព្រះអង្គគិតស្រេច ហើយនៃទើបស្តេច ពាព្រះប្អូនក្មារ
រួចរត់រំលង ដោយដងមាគ៌ា ដើរដល់ឆ្នេរមហា
សមុទ្រសោតសល់ ។

លុះព្រឹកព្រហាម មើលទៅលលាម ឃាត់ត្រើយពុំយល់
ឮតែសន្ធឹក ស័ព្ទទឹកនឹងខ្យល់ ក្រនឹងបានយល់
ត្រើយត្រាណជលសា ។

ស្តេចបន្ទូលថ្លាត់ ថាហៃប្អូនរ័តន៍ ម្នាសមិត្តស្នេហា
បើនៅនេះហោង ពុំធ្ងន់ឡើយណា សមរក្សគោត្តា
យើងស្លាប់នេះមួង ។

បើស្លាប់ក្តីណា គិតអីប្អូនក្មា មកយើងនៅធ្ងន់
ប្អូនអើយយើងក្រ កម្រក្តាត់ហោង ម្ល៉េះប្អូននិងបង
ស្លាប់សល់ផងគ្នា ។

ក្បៀណក្បែរទិមិល មៀងមើលយល់ដល់ សាត់ដោយគង្គា
ស្តេចចាប់សំណាត់ ច្រពាក់អាត្មា ហែលច្នងជលសា
ទាំងតីរព្រះអង្គ ។

ហេតុពៀរវេរា ពីព្រេងនាយណា តាមមកពុំលង់
ស្តេចហែលដល់ហៀប ដល់មាត់កំពង់ ខ្យល់ចក់មកត្រង់
រលកមហិមា ។

បោកបុកផ្ទាក់ផ្ទាយ របូតខ្លួតខ្លាយ ព្រាត់ចេញពីគ្នា
ងងឹតសោតសល់ ពុំយល់ទិសា សម្តេចកស្តា
របូតចេញបាត់ ។

នាងហែលពុំបាន រលកបោកប្រាន ដូចដល់ចុងខ្សាច់
នាងឡើងម្នីម្នា រេករកស្តេច ព្រះនេត្រាត្រាច់
មៀងមើលពុំយល់ ។

នាងដើរទៅមក រេករត់រក ដោយខ្សាច់ផ្ទាក់ផ្ទ
ពុំឃើញព្រះបាទ នរនាថទសពល នាងសោយសោកសៈ
ខ្ញុមហាក្សត្រា ។

ឱម្ចាស់ខ្ញុំអើយ អ្នកដល់ត្រើយហើយ ឬនៅគង្គា
ក្រែងខ្លាចបវែល កំភេលមច្ឆា ក្រពើធ្វាមរ៉ា
កាប់កាត់ក្សត្រថៃ ។

ឬជួបផល់ត្រើយ　ឆ្នេរសាគរហើយ　ស្តេចចរចូលព្រៃ
ក្រែងខ្លាចអម្រឹត　ពន្លឹកក្រាសក្រៃ　ហឹង្សាក្បត្រថ្ងៃ
អន្តរាយអសារ　។
ក្រែងសត្វឥន្ទ្រីយ　យក្សាយក្ស　គជសីហ៍គជសារ
ទ្រឹស្តទ្រុស្តផាលដេញ　ប្រហចប្រហារ　ទាន់ក្សត្រកន្ទាច
ឆក់ស៊ីហោងណា　។
ហៃអស់ទេព្រក្ស　អ្នកហោងសំណាក់　និត្យនៅរក្សា
សាគរជាធំ　ពព្រោតខាមា　កបកើតកលមហា
សមុទ្រនេះហោង　។
ក្រែងយល់ក្សត្រា　ស្តេចឋិតឋានណា　អ្នកប្រាប់ខ្ញុំផង
ខ្ញុំទឹងទៅរក　ព្រះអង្គដូចផង　បម្រើឥតហ្មង
ដូចកាលប្រក្រតី　។
បពិត្រទេព្តា　ឋិតឋាននៅផា　ទិសទាំងប្រាំបី
ឋិតនៅព្រឹក្សា　នូវមារ ប្រឋពី　អាកាសនទី
សោឡសសួគ៌ា　។
ក្រែងអ្នកយង់យល់　ព្រះអង្គទសពល　គម្តែងក្រម្យា
សូមទានប្រាយប្រាប់　ឆាប់ៗមកកា　ខ្ញុំទឹងយាត្រា
ទៅរកព្រះអង្គ　។

នៃព្រៃព្រឹក្សា    រំយោលផ្លែផ្កា    លូតលាស់បំពង់
សម្រាប់ពីព្រេង    ដុះឯងរហង់    ខ្លះវៀចខ្លះត្រង់
    វៀចវៀងដោយគ្នា    ៗ

នៃតែព្រះអង្គ    និកសប្បាត់បង់    បាកពំនុក
ឲ្យខ្ញុំផ្សាខ្លោច    ត្រមោចកំព្រា    ស្តេចបិតបាំងណា
    ខ្ញុំនឹងទៅរក    ៗ

នព្រះឥស្សរ    ស្តេចជាបណ្ឌុល    ពន្ទឹកពន្ទក
ធ្វើម្តេចនឹងបាន    រួមហាំនមូលមក    ខ្ញុំនឹងតែរក
    ត្រង់ណាលោកអើយ    ៗ

នពីព្រះមហា    ក្សត្រស្តេចបានជា    ម្ចាស់ខ្ញុំឯងហើយ
ពុំដែលឲ្យអាក់    ថ្នមថ្នាក់ចិត្តឡើយ    ទេះម្តងម្តេចឡើយ
    ស្តេចប្រោសពីខ្ញុំ    ៗ

ឲ្យខ្ញុំជាទុក្ខ    ចិត្តពុំស្រណុក    សង្រេងថ្ងូញយំ
ភិតភ័យម្នាក់ឯង    វង្វេងទូរគម    អ្នកអើយសមខ្ញុំ
    ស្លាប់ឯងហោងណា    ៗ

នាងថ្ងូញទង្គឹះ    ក្រឹកក្រលផ្អូកផ្អឹះ    ឯកឯងអាត្មា
បម្រះមមៀល    នទៀលអង្គា    នៅផ្នូរដលសា
    សន្ទប់សូឲ្យសុង    ៗ

លុះភ្ញាក់ស្មារតី ជាស់ឡើងអំពី ស្រេចហើយគម្រង់
ស្មារតីទល់ទប់ ចំប្រប់អស់អង្គ នាងឈរឡើងផ្គង់
ជូតជលនេត្រា ៗ

ទើបនាងយកស្បៃ ជោគជាំទន់ជ័យ នៅខ្សាប់នោះណា
នាងផ្ដាតស្រេចហើយ ក្សិណនាងលីលា ដើរដោយមាគ៌ា
ព្រៃព្រឹក្សជ្រលង ៗ

អាសូរក្សត្រី ពុំដែលដើរដី ព្រះបាទទុំពេន
ជាលដូចសិនឈាម រអាមក្ដាត់ហោន ឯណាគតិផង
ជាបីខែហើយ ៗ

នាងអតថ្ងាថ្ងៃ វង្វេងផ្លូវព្រៃ ពុំដឹងដើមឡើយ
គិណាតសោយសោក អមោឃឥតស្បើយ ឥតឯល្ហែឡើយ
ទៀនទួញកជា ៗ

តែមួយក្សត្រី ភ្ញាំងភ្លេចស្មារតី ភិតភ័យតក្កមា
ទ្រហោស្រែកយំ ជាលដំឱក ហើយទួញសោកា
ថ្ងៃថ្ងឹនពុំបាន ៗ

ដើរចូលដោយព្រៃ ទឿយណាស់ពេកក្រៃ ឈរឈប់សម្រាន្ត
ស្រប់ម្លប់ព្រឹក្សា សាខាយោនយោន ក្រសុំក្រសាន
រកើយរាំតា ៗ

## បទកុជង្គលីលា

សរសើរដំណើរព្រឹក្សា ដក់ដិតក្ដាត់ណា ផុះដោយជ្រលង ៗ
ស្នែស្នាច់លាយលេបភ្លូង ពោនពោជកេងគង អង្កោលក្រញូងក្រៃ ៗ
ព្រៀងព្រូសជន្ទួសស្មាតស្វាយ រលួសរលាយ ទន្ទាប់ទន្ទា ៗ
វល្ហិយដក់ពាយដក់ពា ក្រវាន់ក្រៀលស្វា សោមសមផ្តោកផ្តៅ ៗ
ខ្ទរណាំងក្រសាំងពិន្លពន្លៅ បង្ការបង្កៅ រលួសកីការ ៗ
មង្ឃុតមានល្មុតសែដា ទទុម្ពក រទាលធ្មិនផ្អៅ ៗ
ដើមដូងដំឡូងគ្រៀកគ្រៅ ចាកចេកអំពៅ ប្រដាកន្ទ្រាន្ទិត ៗ
ក្រណោញកន្ទ្រាញ់ផុះផិត វៀបវៀនប្រកិត ដាដួវៀនកល់ ៗ
ដកពរសង្ខ្យរសង្ខ្យាល សំពោយសំពារ គ្រឡាកគ្រឡក ៗ
របើសបារប្រើសបប្រេក ចំបក់ទន្ទេក កាកោះដុំ ៗ
មេកងគង់ត្រងឆាត់សម ព្រាលព្រោចប្រឡំ រលៀកឃ្លាឃ្លៃ ៗ
ក្រកស្វាពុព្រាក្រញូងព្រៃ សំពេងជ្រៅជ្រៃ លូតលាស់លំពង់ ៗ
អង្កោលកន្ទោលខ្ទឹងគង់ គ្រឡាតផ្អោផ្អុង ស្កុកស្កុលស្កឹស្កៅ ៗ
ល្វាតស្រឡីស្រឡៅ គ្រៀកគ្រាចតាត្រៅ ជ្រើសជ្រួយផ្ទឹកកាំង ៗ
ស្វែងខ្ទុងធ្នាថ្នងគ្រៀលគ្រាង ក្រញូងបែងបាំង ក្រកោះកែវកោជ ៗ
ពណ៌ពាបក្សាផងសោត ហិចហើរលេងលោត លើមែកព្រឹក្សា ៗ
សត្វសេកករើកហារិកា ក្រួចក្រៀលទទា ពពូលហូពូ ៗ

ស្និតហៅតាពើអកផ លលោតលេងទៅ លើមែកព្រឹក្សា ។
ប៉ុលតោកក្តោកតុងតា តោមតោចក្រសារ ក្រាស់ក្រៃភ្ទឹក ។
ដំណក់សេរសើរអម្រឹក គៀងគូគគឹក ដើរដោយហ្វូងហ៊ ។
ប្រើសព្រាយទន្សាយស្វាឧស្វា មោសខ្លោងខ្លា នាំងនោះផង ។
គៀងគូស្រម៉ូវញែងញែង ខ្វះរត់លេងលង ដាញដល់គ្នាឯង ។
គោព្រៃក្រាស់ក្រៃគគ្រេង លោសចុងស្នែង គ្រើព្រោត ៗ ។
ក្របីតុមទីយារយោប ងើយងរថ្ងូចថ្ងាច ដាញដល់គ្នាលេង ។
ខ្វះស្រង់ញ៉ែងញ៉ងត្រាំត្រែង ខ្វះដល់គ្នាលេង ផ្សៀងផ្សងរេក ។
មានខ្លាចតុំអាចចរចា ភិតភ័យតក្កមា ឡូខឡង់ស្មារតី ។
វង្វេងភិតភ័យភ្ញាស្រី ញ័រអស់ឥន្ទ្រិយ ចំប្រប់អាត្មា ។
ដើរត្រាច់លុះលេចព្រឹក្សា លុះគម្រប់ជា ប្រាំពីរខែស្អាត ។
ដើរផុងដល់ចុងស្រុកថ្វាត់ នគរមហាក្សត្រ ព្រះបាទសុវណ្ណ ។
ស្រីថ្ងៃដើរព្រៃលុះលង់ សំលៀកពុំគង់ ដាលដាច់ឥតបើ ។
នាងខ្លាស់នាងខ្លាស់ស្លឹកឈើ ស្រេចហើយនាងធ្វើ ជាសំពត់ណា ។
ស្លៀកស្រេចហើយត្រាច់យាត្រា ដើរដោយមាគ៌ា ឆ្ពោះទៅព្រះនគរ ។

## បទ កាកគតិ

កូនស្រុកនោះមាន តាចាស់មួយប្រាណ ដើរត្រាច់ចេញចរ
លើផ្លូវលំដែន និងផ្ចាំសរ ចេញពីព្រះនគរ
ជាអ្នកថ្មើរព្រៃ ។

បណ្ដើរនូវឆ្កែ ហែមកជាស្រែ ប្រក្រតីសព្វថ្ងៃ
ឆ្កែនោះវាយល់ ទាន់នាចថ្វាថ្ងៃ វាព្រុសកងព្រៃ
ទាន់រត់មិនមា ។

ឆ្កែនោះវាដេញ ដោយគិតទៅខ្លាញ់ ហៀបតាន់សត្វា
ទាន់រត់ខ្ញីឃ្មាត សង្កេតយាត្រា ឃើញថ្មុកមួយណា
ជ្រោះជ្រៅស្រឡូន ។

ទាន់គិតក្ដាក់ណា លោតបុះមិនមា ពួនក្នុងអណ្ដូង
ឆ្កែវាដេញផល វាចោមជុំប្រូង វាព្រុសរលូង
បន្ទយម្ចាស់វា ។

ឯតាចាស់នោះ ឮឆ្កែវាព្រុស រត់ទៅមិនមា
គាត់មានអំណរ អរឯងមហិមា គាត់គិតស្មានថា
សត្វដូចសព្វដង ។

តាចាស់ធាកចុះ　កូនអណ្ដូងនោះ　ឃើញនាងនោះហោង

តាចាស់គិតថា　ជាខ្មោចព្រៃផង　ឬអ្នកលង

អញជួបប្រទះណា　។

តាចាស់គិតហើយ　ពិតពុំលងឡើយ　គាត់ដណ្ដឹងថា

នេះជាខ្មោចព្រៃ　ឬនៃមនុស្ស　នេះមកពីឯណា

ធ្វើខ្លួនជួបប្រទះ　។

ឥតគ្នីឥតគ្នា　ហេតុអ្វីកំព្រា　ពិបាកដល់ម្ល៉េះ

គ្មានទាំងសំលៀក　ស្លៀកទៅចង្កេះ　ចូរនាងសំណេះ

ប្រាប់មកនេះម្ដង　។

ទើបនាងឆ្លើយថា　អ្នកអើយអ្នកតា　ខ្លួនខ្ញុំនេះហោង

ត្រាច់ដើរទិសទី　ទូរប្ដីខ្ញុំផង　វង្វេងហែលឆ្លង

សមុទ្រជលសា　។

ហែលហៀបដល់ត្រើយ　មើលយល់ច្រាំងហើយ　ហេតុកម្មវេរា

គាប់ខ្យល់បក់មក　រលកមហិមា　ខ្ញាត់ព្រាត់ពីគ្នា

ពុំយល់ឡើយហោង　។

បពិត្រអ្នកតា　សូមទានករុណា　អាសូរនេះម្ដង

ខ្ញុំនឹងនៅជា　ខ្ញុំអ្នកតាហោង　បម្រើឥតហ្មង

សងគុណអ្នកតា　។

បើឃើញប្តីខ្ញុំ សូមអ្នកមកសុំ ឲ្យថ្ងៃឯណា
តាចាស់ស្តាប់ហើយ គាត់ឆ្លើយរឹងថា ឆារតាជាទា
ចិញ្ចឹមនេះម្តង ៗ

តាចាស់ម្នា កាន់កាំបិតព្រា កាប់ឈើមកផ្គង
ហើយបោះសំពត់ ឲ្យទៅនាងផង ដាក់លើនោះផ្គង
ឲ្យនាងឡើងមក ៗ

នាងនាថសោភា អរឯងម្នីម្នា ប្រញាប់យក
សំពត់ផ្លាស់ស្រេច ហើយនាងឡើងមក តាចាស់នេះយក
បណ្តើរនាងទៅ ៗ

តាចាស់ក្រអាល បណ្តើរនាងនាថ ដូចដល់លំនៅ
ប្រពន្ធតាចាស់ ខឹងណាស់ចៅកើ យល់តាចាស់ទៅ
បណ្តើរនឹងនាង ៗ

ប្រែក្រោយប្រែមុខ សម្លឹងសម្លក់ ជេរមកបំផាង
ថាតាកញ្ចាស់ មុខក្រាស់ប្រឆាំង ចាស់គោកំពង
ធ្វើខ្លួនកំឡោះ ៗ

នាំរត់កូនគេ បំពួនសព្វតែ ដោយព្រៃសាន្តគ្រោះ
លុះដើមពេញថ្ងៃ គាប់ថៃថេះថោះ ថាខ្លួនឥតមោះ
ឥតហេតុឥតការណ៍ ៗ

តាចាស់នោះណា ចាស់ឆ្លើយវាចា ថាយើកអាល
ដេរពាលឥតច្បាប់ ឥតស័ព្ទឥតសារ រង់អញជំណាល
ប្រាប់ក្បួនខ្លាចអ្វី ៗ
ខាងនោះវង្វេង ដើរមកតែឯង ព្រាត់ប្រាសស្វាមី
លោកដែលមកថា ជាតាត់លួចប្ដី មេនេះរអី
រអូវមុសា ៗ
រង់ស្ដាប់ស្គាប់ ពុំទាន់បានប្រាប់ កំដេរម្ល៉េម្ល៉ា
មេនេះចណ្ឌាល ឥតការវេណា ដូចឆ្កួតពុំច្បា
ពុំដឹងខុសគាប់ ៗ
ដូនចាស់វង្វឹង ប្រុសស្ដេចដេរវង មេដែងឥតច្បាប់
ប្រវើទៅណា ថាដាមិនគាប់ ខ្ញុំវិលក្រឡាប់
ជាខុសវិញណា ៗ
កញ្ចាស់ព្រាក ដល់ស្អែកគេប្រែក ឃ្លាំងកាប់ក្បាលអា
គេព្រៃថងឯង ចំនលំនៃយណា ត្បិតអាមោហា
ចំផើមគួរគេ ៗ
ក្បិណាលោតទៅវាយ ចាប់សក់ដេរក្ដាយ តាចាស់សព្វតែ
ក្ដិចខាំក្រវៅ ព្រានទៅហើយដោ រំលើងគគង
យកបុរះហើយណា ៗ

ហើយដើរទៅមាន នោះហោរគំរាន សាមានឲ្យមាយា
មុខរនិកំណាច កិច្ចកាចសោះសា ជុំមិនទាំពារ
អង្គុយព្រងើយ ។
ហោរដេញៗទៅ កុំបីបាននៅ នាហាននេះឡើយ
ផកទងអប្រិយ៍ ល្អូចប្ដីអញហើយ ធ្វើជាកន្ទើយ
ពិតពុំទាំពារ ។
នាងនាថស្រីតេន ស្ដាប់ហើយគន់គិត រំពឹងឯងថា
បើគាត់សម្លាប់ អញស្លាប់ក្ដីណា តាមតែវេរ
វិបាកអញហោង ។
បំណាចតាចាស់ គាត់មានគុណណាស់ អញអត់ខូវសង
គុណគត់បន្ទិច ស្រាប់ស្រេចឥតហ្មង ហើយអញចេញហោង
ទៅរកបក្រើ ។
ជូនចាស់មុស្សា ឥតមានករុណា ឲ្យមាននៅដ៏
លុះល្ងាចព្រលប់ ជួបចូលរាត្រី ងងឹតឥតបី
រទះក្បៀនផង ។
គតិនាងជរប៊ួណ៍ ជាអម្ពុំយូរ ដប់ខែកន្លែងហោង
នាងនឹងប្រសូត យប់នោះជាមួង ស្រដីទន្ទង
គង្វរជូនចាស់ ។

| | | |
|---|---|---|
| អម្ចាស់ខ្ញុំអើយ | លោកអ្នកអើយ | ឈឺផ្ទៃខ្ញុំណាស់ |
| ទីងសម្រាលកូន | គាប់ស្ទួនរាពាស់ | ឥតគេទីងគាស់ |
| | ទន់ទល់ឲ្យទាន | ។ |
| ដូនចាស់ស្តាប់ហើយ | ពុំអាសូរឡើយ | បណ្តេញដេរថា |
| ហងទៅសម្រាល | ឯខាងផ្វរជ្ញា | អញដែលមានឯណា |
| | កូនចៅផៅផង | ។ |
| នាងឆ្លើយវិញថា | សូមទានករុណា | ស៊ើជើងបង |
| ទៅឆ្ងាយពុំបាន | រន្ទះភ្លៀងផង | ទទឹកក្តាត់ហោង |
| | ពុំយល់ទិសា | ។ |
| ដូនចាស់ទោះឆ្លើយ | ដេរថាពោរអើយ | ទៅឯផ្វាជ្ញា |
| ទៅនេះអញត្ថិម | រអើមក្តាត់ណា | កុំមឹងបរោ |
| | សរសោះអន្ទង | ។ |
| នាងស្តាប់ជាក់ហើយ | ពុំផ្សរផ្សង់ឡើយ | នាងបើករបង |
| សំដៅគ្រោះនា | ផ្វាជ្ញាទោះហោង | ងងឹតក្តាត់ហោង |
| | ពុំយល់មាគ៌ា | ។ |
| នាងចំដើរស្ទាប | រិមរាមអាចឡាប | ដល់ផ្វាជ្ញាណា |
| នាងឈរសញ្ជប់ | ស្ទុតស្ទប់គគ្រា | នាងសោយសោកា |
| | ពិលាភក្តាត់ហោង | ។ |

ឱព្រះអង្គថ្លៃ ព្រះអង្គក្សិណក្ស័យ ឬស្តេចរស់នៅ
ខ្ញុំដឹងតិចក៏ ទឹងយាត្រាទៅ ឱព្រះចមពៅ
លំបាកកពជា ៗ

បើស្តេចសុគត នៅក្នុងសមុទ្រ ឯកអង្គអនិច្ចា
ប្រសិនស្តេចនៅ ខ្ញុំទៅរក្សា លុះស្លាប់ផងគ្នា
មូលមិត្រដូច ង ៗ

បើស្តេចសុគត មែនពិតប្រាកដ សូមខ្ញុំស្លាប់ផង
កុំឲ្យខ្ញុំរស់ ជីវិតនៅហោង សមទឹងរស់រង
ពិបាកឥតស្បើយ ៗ

បើស្តេចរស់ហោង សូមខ្ញុំរស់ផង កុំឲ្យស្លាប់ឡើយ
ហើយបានជួបចូល មិត្រមូលជាត្រើយ ដូចដើមអ្នកអើយ
កុំឃ្លាតឡើយហោង ៗ

ឱព្រះពជា រែងទ្រង់ករុណា រក្សាស្ងួនត្រង
បើខ្ញុំអផ្សុក ជាទុក្ខគ្មានហ្ន ស្តេចថ្នមត្រកង
លួងលោមបរបា ៗ

ឥឡូវម្តេចឡើយ ឈឺផ្ទៃខ្ញុំហើយ ស៊ើរទឹងជាប់ខ្យល់
ឥតមានអ្នកមួយ មកជួយគាំពារ ឱហេតុវេរា
បុរាណព្រេងនាយ ៗ

ទុកមុខវេក បង់ឃ្លាតបង់ឃ្លា អញទឹកកល់ថ្ងៃ
ឲ្យព្រាត់នឹងប្រាស ខ្វាត់ខ្វាយទីទៃ ទោះរស់ទោះក្ស័យ
ពុំយល់គ្នាឡើយ ៗ

ទុជាតិនេះណា ព្រះអង្គក្សត្រា ប្រាសពីខ្ញុំហើយ
កើតសព្វជាតិ ពុំមានឃ្លាតឡើយ រៀនរួបផល់ត្រើយ
ទិញ្ញានទាយនៃ ៗ

ទោះព្រះបក្រ៏ កើតជាបក្សី ហើរហួសវេហាស៍
សូមខ្ញុំបានកើត ជួបចូលស្នេហា កុំមានឃ្លាតឃ្លា
សព្វជាតិនោះហោង ៗ

ទោះបីក្សត្រា យកជាតិកើតជា អម្រឹតទ្រឹស្ដឃ្លង
សូមខ្ញុំបានកើត កំណើតជួបប៉ឹង ជួបជាគូវផង
ទឹងមហាក្សត្រា ~

ទោះស្ដេចវង្វេង ដោយវិបាកឯង កើតជាមិច្ឆា
សូមខ្ញុំបានកើត កំណើតមួលជា ជួបចូលស្នេហា
ទឹងព្រះអង្គថ្ងៃ ៗ

បពិត្រទេព្ដា ចូលស្ដាប់ប្រស្នា អញខ្ញុំនេះ៎
សូមបានធុតៗ ចំហុតពោកក្រៃ ដូចអាហាបុទ័យ
ខ្ញុំនឹងប្រាថ្នា ៗ

| | | |
|---|---|---|
| នាងនាថទូលថា | សម្ដេចចក្រី | តម្លៃក្រឡា |
| នាងខ្ញុំអង្វរ | ទូលអស់ទេព្ដា | ទាំងទសទិសា |
| | ឲ្យជ្រែងជ្រោមជួយ | ៗ |
| ហើយទើបនាងនាថ | ខ្ញុំពជកុមារ | បណ្ដូលត្រួលត្រួយ |
| ឱកអួលអន់ | ទៀងទន់ល្ហួយ | ហាក់ដូចគេជ្រួយ |
| | ទៀងខ្ញុំថប់ថា | ៗ |
| ទុក្ខខត្រពាល | បុត្ររ័ត្នសង្ការ | មាសមត្រស្នេហា |
| កើតនៅនគរ | បវរនាយណា | ម្ដាយទិន្នសុខា |
| | ចាក់ចមមេតី | ៗ |
| មេទំគីលៀង | បំពេរជ្រះជ្រៀង | ជិតជុំប្រក្រតី |
| អស់ក្រស្ដប្រជា | សេនាមន្ត្រី | ព្រះជនកព្រះជននី |
| | ព្រះអយ្យកា-កោ | ៗ |
| ទាំងពីរព្រះអង្គ | ស្ដេចសឹងសួនត្រង | ស្រឡាញ់ពោឡា |
| ឥឡូវមាសកើត | កំណើតឯកោ | ឯកអង្គអត្តនោ |
| | ពិបាកក្ដាត់ណា | ៗ |
| ឯម្ដាយឥឡូវ | ជាខ្ញុំគេនៅ | ម្ចាស់ការចមហិមា |
| ដេរឥតសម្រាន្ត | ពុំបានទេក្បា | ទុក្ខនស្នេហា |
| | ពន្ទុកម្ដាយអើយ | ៗ |

ម្តាយឈឺក្រលួច ដឹងរួចពុំរួច ម្តាយស្លាប់ដឹងអើយ
ទុកតអ្នកម្តាយ មកជួយកូនអើយ សមមិនរស់ឡើយ
ស្លាប់ឥង់ហោងណា ។
នាងខ្ទួញពិលាក សព្វគ្រប់ដកប ពីព្រះពជា
ឯណាជម្ងឺ ទឹងឈឺខ្លោចផ្សា ញ័រអស់អង្គា
ចំប្រប់ស្មើរក្ស័យ ។
ឈឺចៀបអស់អង្គ ភ្លាំងក្អួចលឿនឡង់ ញ័រជើងញ័រដៃ
ដួលដេកនៅដី ក្សត្រីរ័តន៍ថៃ លំបាកពេកក្រៃ
មុខគួរប្រណី ។

បនតាំពោល

ហេតុតែតេជះឫះម៉ ម:ង់សោយសោកក័- ណាបលុះពន្ទឹកពេកណា ។
ក្តៅដល់មណ្ឌលអាសនា នៃព្រះឥន្ទ្រា- ធិកជរមិលវឹងថ្ងាត់ ។
យង់យល់តាងនាថស្រីរ័តន៍ ជាក់ជាទៀងទាត់ កនៃព្រពន្ធកពុទ្ធា ។
យល់នាងប្រសូតបុត្រា ម្នាក់ឯងកំព្រា ពុំរួចហើយនាងប្រែកយំ ។
ទៅព្រះមហាក្សត្រឧត្តម ប្រាថ្នាសូមសុំ លុះដល់ទិព្វានថ្ងៃថ្ងា ។
ទើបព្រះឥន្ទ្រប្រែប្រាណជា ជូនចាស់មួយណា កំដើរទៅត្រង់ក្សត្រី ។
ចរចាស្នេហាស្រដី ជាហៃនាងស្រី ក្រមុំនាងមកពីឯណា ។
នាងទាចសង្ក្រារឆ្លើយថា ជូនអើយខ្ញុំជា ប្តើរទេសរង្វង់ព្រាត់ប្តី ។

រ.ឆ្លើយមកថាខ្ញុំគេ  គេវាយគេជេរ  រំលើកបណ្ដាញមហិមា ។
ប្រើមកសម្រាលទៅនា  ឯខាងផ្លូវថ្លា  ខ្ញុំមកឥឡូវជួបផ្គង ។
សម្រាលពុំរួចឡើយហោង  ជូនជួយនេះម្ដង  សូមតានអ្នកជូនករុណា ។
មកជួយទុំងជុលតិពក  យកបុណ្យហោងណា  ស្មើអ្នកបង្កើតខ្ញុំហោង ។
ជូនចាស់ថ្លាស់ឆ្លើយវិងស្នង  ថាជូននេះហោង  កុំនាងចុះរម្ភាឡើយណា ។
ជូនចាស់ចូលទៅម្ចា  ទុំងជុលចាប់ស្មា  ក្សិណនាងប្រសូតរូបហោង ។
ហើយប្រែកាឡាជួបផ្គង  ជាក្មេងនេះហោង  ឲ្យនាងកំដៅអាត្មា ។
ស្រេចហើយជូនចាស់ឆ្លើយថា  កូននាងនេះណា  គឺអញសូមយកជាចៅ ។
ចូរនាងឲ្យអញយកទៅ  ផ្ទះអញនិត្យនៅ  ឯកើតមណ្ឌលស្ដេចណា ។
ថាបើនាងទីងរក្សា  សួរកូនពុំងា  ខ្វាចក្រែងពុំស្គាល់ឡើយណា ។
នាងបានទ្រព្យអ្វីរួចពក់  ឲ្យជាបន្ទាល់  ហើយនាងឃើញកូនពុំងា ។
បើនាងយកទៅហើយណា  ពុំបានរក្សា  អាសូរសមស្លាប់ឯងហោង ។
ត្បិតម្ចាស់នាងខ្វរកន្ទួង  ប្រើហើយជេរផង  សមនាងពុំបានរក្សា ។
ទើបនាងថ្លាស់ឆ្លើយវិងថា  បើជូនករុណា  អាសូររក្សាសួនគ្រង ។
ស្មើជូនបង្កើតឲ្យហោង  ខ្ញុំក្រអ្វីផង  លែងតែអ្នកជូនមេត្តា ។
សមទឹកទឹងយកទៅឯណា  ពុំបានរក្សា  ទីងជាប្រយោជន៍អ្វីឡើយ ។
បើខ្ញុំឃើញប្ដីខ្ញុំហើយ  ហៅអ្នកជូនអើយ  សូមលោះអំពីអ្នកណា ។
ខ្ញុំមានចិញ្ចៀនត្បូងជា  ភប្ដីខ្ញុំណា  ខ្ញុំឲ្យទៅជាបន្ទាល់ ។

ពោះធំប្ដីខ្ញុំបានស្គាល់ ទ្រព្យជាបន្ទាល់ ក៏ស្គាល់ជាកូនឯងណា ៗ

នាងបីបុត្រថ្ងៃពុំផា ថ្នមថើបសិរសា បបក់ព្រះលឹងថ្វាថ្ងៃន ៗ

ឱបអង្គថ្ងូញទ្រង់ព្រះកន្សែង ចំប្រាប់ស្ងប់សែង អនាថអាណិតថ្ងូញថា ៗ

ឱកូនកម្សត់ពុំផា កូនអើយម្ដេចបា កើតមកពិបាកវេទនៃ ៗ

ឱកូនមិត្តមាសថ្លើមថ្លៃ ចិត្តម្ដាយអាល័យ ពុំចង់ឲ្យបាឃ្លាតឃ្លា ៗ

ឥតលុះម្ដាយឯងករុណា ទើបម្ដាយថបថា ហាក់ដូចទុជិនវិស័យ ៗ

ម្ដាយជាខ្ញុំគេហើយនៃ អម្ចាស់ខ្ញុំក្រៃ សាហាវឥតមានករុណា ៗ

សមម្ដាយពុំបានវេក្យា ចិញ្ចឹមមើលថា ត្បិតម្ដាយនេះមានអំពល់ ៗ

សមបាយំឯងដាច់ខ្យល់ កូនអើយម្ដាយយល់ ព្រោះហោងតែម្ដាយនិងកូន ៗ

ឲ្យទៅជាទៅអ្នកដូន បង់សៀតសោះសូន្យ ដឹងយល់ពុំយល់មុខបា ៗ

ម្ដាយនៅបម្រើគេណា តែ ១០ ទិវា គម្រប់ ៧ ថ្ងៃហោង ៗ

ហើយម្ដាយតាមកូនស្ងួនគ្រង ម្ដាយទៅទៅផង ទីដូនមូលទីបាណា ៗ

ទើបនាងហុចកូនពុំផា ទេ.ដូនហើយណា នាងហុចចិញ្ចៀនទៅផង ៗ

ទើបដូនយកចិញ្ចៀនចង នៅករកូនផង ស្រេចហើយទើបនាងត្រឡប់ ៗ

ដើរដល់ផ្ទះវិញហើយណា ឯចាប់ប៉ុស្សា ដណ្ដឹងមកហើយជេរផង ៗ

ហៃហោរ ព្រោងដកទង ឯណាកូនហោង សម្រាលរួចហើយទុកឯណា ៗ

នោះទើបនាងឆ្លើយវិញថា ព្រោះគេរក្សា គេចិញ្ចឹមយកជាចៅ ៗ

ដូនចាស់ជាហោងឲ្យទៅ កុំយកមកនៅ អញនេះរើមក្ដាត់ណា ៗ

កាលនោះក្សត្រីថ្ងៃថា នៅផងជូនតា វិស័យដូចខ្ញុំម្ចាស់ ។
នាងថាវិបាកក្រៃក្រាស់ ដេរពោលច្រើនណាស់ កុំឲ្យសម្រាន្តឡើយណា ។
នាងគិតអាណិតអាត្មា ទឹងព្រះរាជា ខ្វល់បុត្រពុំងាថ្មើមថ្ងៃ ។
នេះនូវស្រដីកាលថ្ងៃ នាងនាថឈឺផ្ទៃ ប្រសូតព្រះរាជបុត្រា ។
ព្រះឥន្ទ្រប្រែប្រាណកាឡា ជាតាស់មួយណា សូមកូនយកទៅជាចៅ ។
កាលក្រោយនាងនាថឈឺទៀត ព្រះឥន្ទ្រនោះនៅ រក្សានៃព្រះរាជបុត្រ ។
ហើយប្រែកាឡាជាសំពត់ ទេសទិព្វទាំងផ្ទត់ មកទ្រាប់នៃកូនពុំងា ។
ហើយព្រះឥន្ទ្រឯងប្រែជា ត្មាតមួយសោះសា ក៏គ្រងព្រះរាជបុត្រថ្ងៃ ។
ការក្តៀងសទៀមសោតនៃ ការខ្យល់ការថ្ងៃ កុំអាចឲ្យត្រូវឡើយណា ។
កាលនោះចៅសូរវង្សា សោយរាជ្យនៅនា គន្ធពបុរីស្ត្រគ្រង ។
កាលរាត្រីនោះសោតហោង ស្តេចគិតប៉ុនប៉ង ទឹងទៅព្រះពានព្រឹក្សា ។
លុះព្រឹកព្រហាមហើយណា ព្រះបាទក្សត្រា ស្តេចទ្រង់នូវគ្រឿងទិព្វថ្ងៃ ។
ទ្រង់ព្រះមកុដកែវប្រពៃ រតនកសក្រាស់ក្រៃ ចញ្ចែងចញ្ចាចយល់យង់ ។
ថ្កើងកេរ្តិ៍ថ្កើងយសថ្កើងអគ្គ ថ្កើងពូជថ្កើងពង្ស ត្រកូលអម្បូរក្សត្រថ្ងៃ ។
ស្រេចស្តេចគង់ដំរីជ័យ បរិវារក្រាស់ក្រៃ ក៏ហែសម្តេចរាជា ។
ស្តេចដើរទៅដោយផ្លូវថ្លា ឆ្ពោះព្រះនេត្រា ក៏ទតមើលមៀងសព្វទិស ។
លុះទៅដល់ក្រៅបង្អស់ ទីមផ្ទះដូនចាស់ ស្តេចយល់នៃត្មាតនោះហើយ ។
យល់កាន់បំពៀងព្រងើយ កុំអើលហើយឡើយ ក៏ស្តេចបន្ទូលត្រាស់ថា ។

ហៃម្នាបេអស់ពួកអមច្ចា គ្នាយើងម្នីម្នា ទៅមើលសត្វនោះធំអ្វី ។
ទើបអស់អមាត្យផងវិញ ធុនអគ្គិសិរសី ក៏ថ្វាយបង្គំក្រាបលា ។
រួសរត់ប្រៀវប្រុងម្នីម្នា ទៅទៀបហើយណា ទើបត្មាតនោះលោតទៅក្រៅ ។
អមាត្យរមិលមើលទៅ យល់កូននោះនៅ នាក្នុងសំពត់ទិពថ្មី ។
អមាត្យវិលវិញមកវិញ ទូលព្រះបត្រី ព្រះបាទសម្ដេចពកជា ។
បពិត្រសម្ដេចក្សត្រា កូនអ្នកឯណា ទៅបោះបង្វៀតច្នេះនៃ ។
សំពត់មួយមានតម្លៃ ទាំងផ្ទត់ចីប្រពៃ ក៏ទ្រាប់នៃកូននោះណា ។
កូននោះយល់មានរូបា ហាក់ដូចទេវតា ច្យុតមកពីសួគ៌វិញ ។
អាហារសមត្ថតចកង យល់រស់ជីវី ក៏ចាំទាំតែស្លាប់ ។
តេជៈយើងខ្ញុំទៅចាប់ អគ្គិសម្លាប់ ហើយត្មាតនឹងធំហោងណា ។
ស្ដេចស្ដាប់អស់អមាត្យផង ទូលដូច្នោះហោង ស្ដេចតរិះតឯឧបមា ។
ទើបស្ដេចបន្ទូលត្រាស់ថា ថាម្នាលអស់គ្នា ទៅយកមកឲ្យអញផាប់ ។
កាលនោះអមាត្យផងស្ដាប់ ក្រាបលាត្រឡប់ ទៅយកនៃកូននោះណា ។
បីមកថ្នាក់ថ្នមលេលា ថ្វាត់ថ្វាយក្សត្រា ធីកជកសូរជៀសជ័យ ។
ទើបមហាក្សត្រាថ្វាថ្ងៃ ព្រះហស្តប្រពៃ ទទួលព្រះរាជបុត្រា ។
ហើយស្ដេចបន្ទូលត្រាស់ថា វ៉ែកូននេះណា អញយកជាកូនអញហោង ។
ទើបស្ដេចទតព្រះស្ងួន យល់ចិញ្ចៀនចង ស្ដេចគន់មើលមើលជាក់ ។
ស្ដេចផ្ទឹមព្រះទម្រង់ស្ដេចពាក់ ក្បាច់ក្បូរចម្លាក់ ដូចព្រះទម្រង់ស្ដេចហោង ។

ស្តេចថាចិញ្ចៀននេះហោង  នូវកូននេះផង  មិនអ្នកដទៃទៀតឡើយ ។
គឺកូនប្អូនឥញឯងហើយ  ឱកូនមាសហើយ  ឪពុកតើនៅឯណា ។
ឱក្មួយបុកណាទឹងមា  បានយល់មុខបា  ហេតុបុណ្យបុកណាមាក្តាត់ ។
ឪពុកបាម្តេចមកព្រាត់  ឃើញតែកូនរ័តន៍  ត្រមោចកំព្រាម្នាក់ឯង ។
ឱហេតុវិបាកពីព្រេង  ឯងអាចថ្លែង  បំព្រាត់បំប្រាសហោងណា ។
ស្តេចទ្រង់ព្រះកន្សែងសោកា អាណិតអាណា  អនាថទឹងកូននោះហោង ។
ទើបស្តេចត្រាស់ប្រើអ្នកផងឲ្យសួរដណ្តឹង  មេបាឪពុកនូវម្តាយ ។
អមាត្យបរបេញប្រញាយ  រកសួរសព្វសាយ  ពុំដឹងពុំឮសូរសោះ ។
រកសព្វគ្រប់ឥតចន្លោះ  តែផ្ទះដូននោះ  ឲ្យជាវង្វេងវិលវល់ ។
អមាត្យរកសួរពុំយល់  ស្រេចវិលមកដល់  ព្រះបាទសម្តេចកជា ។
ថាពិត្រយើងពុំអស់គ្នា  រកសព្វទិសា  ពុំយល់ឪពុកនូវម្តាយ ។
ស្តេចស្តាប់អ្នកផងទូលថ្វាយ  រកគ្រប់សព្វសាយ  ពុំយល់ដូចព្រះបង្គាប់ ។
ស្រេចស្តេចលីលាត្រឡប់  វិលវិញមកឆាប់  ដល់រាជមន្ទីរកេងរម្យ ។
ស្តេចឲ្យរករើសមេទំ  ស្រាលសឹងដោះធំ  ហៅក្បំព្រនាក់ខ្សែត្បាញ ។
ក្បំស្តៀតព្រួយចិត្តទឹងទាញ  ព្រនាក់ខ្សែត្បាញ  កឹសមទឹងដៃបីឡើង ។
ស្រាលរូបមិនក្រាសមិនស្តើង  មិនពើតមិនពើង  មិនជាត់មិនធំពេកសម ។
សឹងមានវង្សាឧត្តម  ឲ្យជាមេទំ  បំបៅព្រះរាជបុត្រា ។
ស្រេចស្តេចឲ្យសង់សាលា  ប្រាំល្វែងនោះណា  កណ្តាលព្រះលានក្បែរថ្លៃ ។

ឲ្យគូរគំនូរបីប្រពៃ　និយាយនេះថៃ　ពីកាលដំណើរស្តេចហោង ។
កាលដើរតែប្អូននឹងបង　ត្រាច់ដោយជ្រលង ដូចដល់ខគរគាយណា ។
ហើយស្តេចទ្រង់ព្រះសទ្ធា　យកទ្រព្យជា ១　ឲ្យមានជាប្រក្រតីហោង ។
ស្តេចផ្តាំអស់នរអ្នកផង　អម្បាលគ្រប់គ្រង　រក្សាព្រះបរមសីលា ។
ថាពោះស្រមណ៍ព្រាហ្មណ៍ព្រឹទ្ធា　បុរសផងណា　មកចូលសំណាក់ទាហ៊ាន ។
គ្នាយើងទទួលឲ្យមាន　ស្រេចស្រាប់គ្រប់បាន　ហើយនាំឲ្យមើលគំនូរ ។
បើអ្នកឯណាផ្សងផ្សូរ　ចូលស្តាប់គិតគូរ　ម្តេចវមកប្រាប់អញហោង ។
ផ្តាំស្រេចស្តេចឲ្យប៉ាវគង　ប្រាប់អស់អ្នកផង　ឲ្យចូលទៅយកមានណា ។
ព្រះបាទសូរវង្សជេដ្ឋា　ឲ្យសង់សាលា　ដំណើរដំណាលស្តេចហោង ។

## បទ កាកគតិ

វរពទវទ្វីយ៍　លះនូវស្រដី　ដំណាលទំនង
ដំណើរពោធី　ស្តេចព្រាត់ហែលឆ្លង　សមុទ្រនោះហោង
ពិបាកមហិមា ។
ស្តេចហែលសមុទ្រ　ហែលហៀបផុត ១　ស្ទើរដាច់ខ្យល់ណា
លង់លុះដួចដល់　ត្រើយថ្នល់គង្គា　ស្តេចឡើងម្ហូម្មា
ទៅរកៈទពី ។

ស្តេចដើរដោយឆ្ងរ សាគរគម្ភីរ ត្រាច់រកប្អូនស្រី
ភិតភ័យឡិនឡង់ ឯកអង្គចក្រី ស្តេចសោយសោកពី-
លាបលន់ពេកក្តាក់ ។

ស្តេចស្តែងទូញថា ឱប្អូនស្នេហា ពន្ធកខ្ញុំមចិត្ត
វិបាកពីព្រេង នោះឯងឲ្យព្រាត់ ហេតុនោះបងឃាត
ពុំឲ្យប្អូនមក ។

ឱប្អូនស្នេហា សាច់សង្សារ ខ្ញុំខ្លួនពន្លក
បងគិតតិចក៏ មាតាឈូងឆក បងនឹងទៅរក
ព្រះប្អូនស្នេហា ។

បងគិតមួយគ្រែ ខ្លាចតែប្អូនក្សយ កណ្តាលជលសា
ក្រែងសត្វទឹកផង ទ្រីស្តួយងហឹង្សា ឆក់ធីគោក្តា
អន្តពយបាត់បង់ ។

ឬមួយប្អូនឃ្លាត ខ្ញុំហែលសង្វាត ដូចដល់កំពង់
សឹងលើខ្នងខ្យាប់ ដើរត្រាច់ឯកអង្គ ភិតភ័យឡិនឡង់
រកបងពុំយល់ ។

ឬមួយប្អូនថ្ងៃ ត្រេចចរចូលព្រៃ វង្វេងវិលវល់
ក្រែងសត្វអម្រឹត ពន្ទឹកសោតសល់ យល់ប្អូនដើរដល់
ជាលដេញគោក្តា ។

ឬមួយអ្នកព្រៃ ដើរត្រេចសព្វថ្ងៃ ស្វែងរកអម្រឹតា
ប្រទះប្អូនស្ងួន ខ្ទឹមខ្លួនពុំឃា សោរ៉ះយាត្រា
ចរបូលនគរ ៗ

ឬអ្នកឯណា អាចចរយាត្រា ទីងត្រេចចេញចរ
យង់យល់ប្អូនក្យា ស្នេហាសាទរ ស្ងួនស្ងួតសមបវរ
ប្រាយប្រាប់អញក៏ ៗ

អញទឹងទៅរក ប្អូនស្ងួនពន្ទុក សង្ក្រះស្នេហា
ឲ្យបានរួមប៉ាន ពុំមានឃ្លាតឃ្លា ដូចដើមនោះណា
ប្រក្រតីសព្វផង ៗ

បពិត្រទេព្តា ទិត្យនៅរក្យ សមុទ្រនេះហោង
ត្បិតព្រះប្អូនរ័ត្ន ប្រាសព្រាត់ហៃបង្ខង ក្រែងយល់ផងហោង
បង្ហាញខ្ញុំក៏ ៗ

បពិត្រព្រះឥន្ទ ទ្រ័សទ្រង់អាចិទ ទេពទិព្វចក្ខា
ក្រែងយល់នាងនាថ សង្ក្រះស្នេហា បិតនៅឋានណា
អ្នកប្រាប់ខ្ញុំផង ៗ

បពិត្រព្រះអាទិត្យ ទើបទេវបុត្រ រុងរឿងកន្ទង់
ក្រែងយល់ប្អូនថ្លៃ ប្រពៃឥតហ្មង ប្រាយប្រាប់ខ្ញុំផង
កុំលាក់ឡើយណា ៗ

| | | |
|---|---|---|
| បពិត្រព្រះបាទ | ប្រសើរសល់ខ្នាត | ស្មើថ្ងៃថ្លា |
| ក្រែងយល់ស្រីតែទំ | មាសមិត្រស្នេហា | កុំលាក់ឡើយណា |
| | អ្នកប្រាប់ខ្ញុំផង | ៗ |
| ព្រះយមរាជា | ស្តេចប្រើអាជ្ញា | ត្រួតត្រាសត្វផង |
| ក្រែងយល់នាងនាថ | សង្សារស្នេហ៍ស្នង | អ្នកប្រាប់ខ្ញុំផង |
| | ឲ្យខ្ញុំបានដឹង | ៗ |
| បពិត្រព្រះមាតុ | ឥសីនរនាថ | ជាតិជាជំណឹង |
| អ្នកបុណ្យអ្នកបាប | ដរាបផ្សេងៗ | ញុំាងអ្នកបានដឹង |
| | វេរាខ្ញុំហោង | ៗ |
| សូមអ្នកប្រាប់ក៏ | បានខ្ញុំនឹងលា | វេរានោះផង |
| ឲ្យបានលំដោះ | រំដោះម៉ត់ហ្មង | សោះរាំចាំចង |
| | តែឲ្យព្រាត់ប្រាស | ៗ |
| ឱប្អូនស្នេហ៍ស្និទ្ធ | ឥឡូវមេព្រាត់ | ចាកចេញទិកស |
| បងធុញថប់សល់ | ត្បិតពុំយល់អាស | ហាក់ដូចគេពាស |
| | កងទ្រូងធ្លុលផ្សា | ៗ |
| ឱមាសស្នេហ៍ស្នង | កំសត់នឹងបារ៍ | ច្រើនផងច្រើនគ្រា |
| ហេតុតែបុរាណ | ឲ្យបានស្នេហោ | ម្តេចមកឃ្លាតឃ្លា |
| | និរាសសោះសល់ | ៗ |

| | | |
|---|---|---|
| ខ្លួនឯណា | ប្រាយប្រាប់អញក៏ | ឲ្យអញបានយល់ |
| ប្អូនមាសថ្លើមថ្លៃ | ប្រពៃមង្គល | សោះតែអញទល់ |
| | ទុក្ខឯងកំព្រា | ៗ |
| ព្រះពោធិសត្វ | ទៀងទួញប្អូនរ័តន៍ | សែនសោយសោកា |
| លុះបន្ទោរស្រេច | ស្ដែងស្ដេចលីលា | ដើរដោយឆ្ពោះសា- |
| | គរតែឯកអង្គ | ៗ |
| ដើរដោយត្បូងខ្សាច់ | ព្រះនេត្រាត្រេច | ស្ដេចមៀងមើលទង់ |
| ស្ដេចដើរសង្វាត | ខ្ចីឃ្លាតតម្រង់ | ស្មានជាយល់អង្គ |
| | ព្រះប្អូនស្នេហា | ៗ |
| ស្ដេចយល់តែស្បៃ | ដោតជាទង់ជ័យ | ពុំយល់ប្អូនភ្ងា |
| ហើយយល់ស្នាមជើង | ជាន់ថ្មីនោះណា | ស្ដេចសោយសោកា |
| | កិល បសោកសល់ | ៗ |
| ឱប្អូនមាសអើយ | បានដល់ត្រើយហើយ | រកបងពុំយល់ |
| សមប្អូនកិតឯង | វង្វេងវិលវល់ | គិតស្មានបងដល់ |
| | ជួបនៅនេះនៃ | ៗ |
| ទទឹងយល់បាត់ | ត្រមោចស្ងប់ស្ងាត់ | ប្អូនចរចូលព្រៃ |
| ហើយប្អូនពន្ទក | យកតែជាយស្បៃ | ដោតជាទង់ជ័យ |
| | នៅខ្សាច់នោះណា | ៗ |

ឧកែវរត្នពិសេស    កន្ត្រាទិព្វទេស    ហៅរ័តន៍កាសា
ប្រសើរកន្ទង    ម៉ត់ហ្មងថ្លៃថ្លា    ដែលព្រះប្អូនភ្ញា
ដណ្តប់យានយាស    ។

ប្អូនមហាប្រសើរ    តោះនៅមៀងមើល    ដូចកែវកែមមាស
ស្រស់ស្រេចប្រិមប្រិយ    រស្មីផ្ទុះធ្លាស់    ប្រពាត់ពេញពាស
ទាំងបរមមណ្ឌល    ។

ម្តេចឡើយមកព្រាត់    និរាសបង់បាត់    រកមាសពុំយល់
ត្រមោចឯកឯង    វង្វេងវិលវល់    លំបាកទូរពល
ទៀយណាស់ល្ហិតល្ហៃ    ។

ប្រណីប្អូនមាស    ម៉្លេះសមយានយាស    ហត់ហើយហាលថ្ងៃ
បាទាទាំងពីរ    កបល័ក្ខណ៍ប្រពៃ    សមរុកនព្រៃ
ព្រៀងព្រេចបន្ទា    ។

ធ្លាប់នៅពិមាន    ប្រាសាទលើបាន    ទិព្វខែនសុវណ្ណ
ក្រោមស្វេតច្ឆ័ត្រ    រូបរ័តន៍មាលា    ហាក់បានសួគ៌ា
ទិព្វទេពបន្ទំ    ។

បរិពារក្រាស់ក្រៃ    ស្រីស្រស់សារដ័យ    ស្រីឆ្គារព្រះស្នំ
សម្រាប់ឆ្វេងស្តាំ    ចោមចាំដិតដុំ    របបក្រិត្យក្រំ
សម្រាប់ក្សត្រី    ។

ម្ដេចឡើយឥឡូវ កំព្រាឯងក្លូវ ត្រមោចឥតបី
លំបាកគស់អង្គ ស្រយន់ឥន្ទ្រីយ៍ ហេតុតែពៀរពី
ព្រេងនាយមកដល់ ៗ

ព្រះពោធិសត្វ ទៀនទួញប្អូនរតន៍ សោកសល់អន្ទូល់
បម្រះនទៀល មះមៀលសោតសល់ នៅខ្ទប់ថ្នាក់ថ្នល់
ដែលព្រះប្អូនភ្ងា ៗ

ហើយទើបស្ដេចតាម ទៅដោយដែលស្នាម ដើរជាន់នោះណា
ដែលដើរពីព្រឹក ទទឹកយល់ជា ថ្មីៗហើយណា
ស្ដេចតាមទៅហោង ៗ

ស្ដេចដល់មាត់ព្រៃ ស្មៅប្រេះក្រាស់ក្រៃ ពុំយល់គន្លង
ស្ដេចមើលក្រោយក្នុក ស្រែកហៅរំពង ស្ដេចស្កាត់ដោយដង
ព្រះព្រៃព្រឹក្សា ៗ

ព្រះអង្គខ្ញុំឃាត រងចំសង្វាត ត្រាច់រកប្អូនភ្ងា
សព្វព្រោះព្រេលង ដោយដងមាគ៌ា លំបាកក្ដាត់ណា
ថ្ងើនថ្ងីនពុំបាន ៗ

មើលឯព្រឹក្សា ត្រសាយសាខា ត្រសុំយោនយាន
ដុះដូចគេបារ រៀនកល់សព្វបាន តូចធំផងមាន
ប្រូងប្រាងស្មើស្មោះ ៗ

| | | |
|---|---|---|
| លាយលេចប្រឡំ | ត្រញូនសុក្រម | ផ្ដឹកកាំងក្រកោះ |
| ប្រេជ្រួយទ្រៀលទ្រាំង | លំពង់លំពោះ | ព្រូសព្រុំផ្កាត់ប៉ោះ |
| | រលៀកឃ្លាឃ្លៃ | ៗ |
| សម្រោងសម្រង់ | ស្កុកស្កុលឆ្នាឆ្នង់ | ស្វាច់ស្វៃជ្រៃជ្រ |
| រៃកាំងដើងដោត | លៀបលោតលាំងជ័យ | អំបែងថ្ងៃថ្ងៃ |
| | សានសោមផ្ដោកផ្ដៅ | ៗ |
| ឈើតាលឆ្នាឆ្នង់ | រវៀងខ្វែងគង់ | ក្របាសក្របៅ |
| ដង្កៀបក្ដាមក្ដុល | ស្កុកស្កុរស្ដើស្ដៅ | គ្រៀកគ្រាចតាគ្រៅ |
| | បបាតទន្ទា | ៗ |
| កណ្ដោកកណ្ដោល | កែវតោកអង្គោល | ក្អាំពាក់ក្រឹស្នា |
| ស្រមឺស្រមូល | ស្រល់ស្រូលធាំធា | សត្វារកា |
| | ដក់ពូស្ដឹស្ដន់ | ៗ |
| ស្រឡៅស្រឡី | ក្រិត្នារណ្ហាដី | ប្រទៀងខ្វែងគង់ |
| ត្រឡាចត្រឡក | សម្រកផ្អាផ្អុង | ពពូលឆ្នាឆ្នង់ |
| | ក្រូសក្ងុងក្ងាំក្ងែង | ៗ |
| ផលោកញរព្រៃ | ចង្រិតាតក្រ័យ | សង្កែពុំសែន |
| ត្រសេកត្របែក | កន្ទ្រកទ្រុំវែទ | ត្រមូចត្រមែង |
| | ពពលផ្ដៀកផ្ដៅ | ៗ |

| | | |
|---|---|---|
| ស្រគុមថ្ពួរថ្ពាន | វល្លិយារវល្លិយាន | ក្រពាន់ក្រៀលស្វា |
| មានវល្លិផ្លាល់មាន់ | ពាក់ព័ន្ធលើគ្នា | ធ្លាក់សព្វសាខា |
| | ពាក់ពឹងលើធំ | ៗ |
| ឈើផងរុងធ្លារ | សង្ស័រសង្សា | សង្សាយទ្រទំ |
| បង្គួយដើងតាប | ក្នុកព្រាបព្រាលព្រំ | ដង្កោឧជុំ |
| | ធ្មេញត្រីឃ្មួតឃ្មៃ | ៗ |
| ក្រៀលគ្រស់ឧជ្រឹង | វល្លិរាសន្ធឹង | វល្លិរើកវល្លិរាយ |
| ដើងអណ្ដើកស្វា | មានវល្លិដក់ពាយ | វល្លិវែងធ្លាក់ធ្លាយ |
| | ពាក់ពឹងឈើឈរ | ៗ |
| ព្នួរជ្រែសន្ធឹង | វល្លិបាស់ទ្រហឹង | វល្លិប្រាសកំទរ |
| មានវល្លិលំបឹង | ទទំទងរាគរ | ត្រួយតាំងឈើឈរ |
| | ព័ន្ធពាក់ធ្លាក់ធ្លាយ | ៗ |
| មានឈើផលា | ទន្ទាប់ទន្ទា | រលួសរលាយ |
| ទ្រមូងទ្រមួច | ពោនពោចស្វាតស្វាយ | ស្រគុំក្រួចក្រាយ |
| | តាទឹមផលា | ៗ |
| បង្គើរគួលែន | សេមាន់មាក់ប៉ែន | មានលុតសែជា |
| ព្រួសព្រេងដើមដូង | អង្កោលសោតណា | ប្រដាក់ផលា |
| | ដើងក្រានវល្លិមាស | ៗ |

(ទៅមានត)

ផ្នែកកំណត់-ប្រវត្តិការណ៍

## កំណត់ការិយាល័យនិពន្ធ :

ថ្ងៃ ៦ មិថុនា ១៩៧០ ពួកចក្រពត្តិឈ្លានពាន វៀតកុង-យួនខាងជើង បានរុករានទន្ទ្រានចូលទៅក្នុងប្រាសាទអង្គរវត្ត និងប្រាសាទនានាទៀត នៅខេត្តសៀមរាប ដែលជាសម្បត្តិដ៏មានតម្លៃនៃប្រទេសកម្ពុជា ។

រដ្ឋាភិបាលយើង បានធ្វើសេចក្តីប្រកាសពេញសកលលោកឲ្យគេដឹងរឿងដ៏ឃោរឃៅនេះ ។ ឯលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ក៏ធ្វើការអំពាវនាវភ្លាមទាន់ពេលវេលាដែរ ។ ចំណែកអង្គការផ្សេងៗ ខាងវប្បធម៌ក្នុងប្រទេស មានសមាគមអ្នកនិពន្ធខ្មែរជាដើម ក៏ផ្ញើមាចេញសេចក្តីអំពាវនាវ ទាញសតិសម្បជញ្ញៈមតិសកលលោក ពីរឿងនេះដែរ ។

យើងសូមចុះផ្សាយ សេចក្តីអំពាវនាវទាំងនោះខ្លះ ដូចតទៅ :

---

## សាររបស់រដ្ឋាភិបាលប្រទេសកម្ពុជា

## ជូនចំពោះមតិពិភពលោក

*ក្នុងប៉ុន្មានថ្ងៃកន្លងទៅនេះ ពួកចក្រពត្តិ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និង រណសិរ្ស សេរីការជាតិ រំដោះវៀតណាមខាងត្បូង (វៀតកុង) បានជ្រៀតជ្រែកចូលមកក្នុងទឹកដីប្រទេសកម្ពុជាកាន់តែជ្រៅឡើង ៗ ហើយបានកាន់កាប់សម្លាប់បំផ្លិចបំផ្លាញ និងធ្វើឲ្យវិនាសហិនហោចគ្រប់ទីកន្លែងដែលវាឆ្លងកាត់ ។ កាលពីថ្ងៃ ទី ២៨ ឧសភា ១៩៧០ ពួកនេះបានចូលដល់ខេត្តកំពត ហើយពីរបីថ្ងៃក្រោយមក ពួក*

ក៏បានទៅដល់ខេត្តសៀមរាប ដែលមានព្រំប្រទល់ជាប់នឹងថៃឡង់ដ៍ ។ នៅខេត្តសៀមរាប ក៏បានកាយប្រហារចំណតអាកាសយាន ដែលស្ថិតនៅជិតផ្ទាល់នឹងប្រាសាទអង្គរ ។ ប្រាសាទអង្គរជាប្រាសាទមួយ ក្នុងចំណោមអច្ឆរិយវត្ថុទាំងឡាយ ដែលប្រជាមនុស្សអាចបង្កបង្កើតឡើងបាន ហើយដែលបានក្លាយទៅជាភាគមួយនៃបេតិកភ័ណ្ឌខាងសិល្បៈ និងវប្បធម៌របស់មនុស្សជាតិ ។ គួរកត់សម្គាល់ទៀតថា ក្រៅពីពួកប្រាសាទអង្គរ ខេត្តកំពង់ធំ និងសៀមរាប សឹងពោរពេញទៅដោយពួកប្រាសាទដទៃទៀត ដ៏សំខាន់ និងដ៏ល្អផងដែរ ។

ដោយកាលពីមុន កងទ័ពកក្បាលយៀកកុង និងយៀកណាមខាងជើងមិនបានរួញរា នឹងប្រព្រឹត្តអំពើប្រមាថបំផ្លិចបំផ្លាញ បូជនីយដ្ឋានសិល្បៈនិងសក្ការវត្ថុ នៅក្នុងខេត្តតាកែវ កំពត និងកំពង់ចាម ដែលពួកក៏បានធ្វើឲ្យអន្តរាយដល់វត្តអារាមនិងប្រាសាទបុរាណ ។ រដ្ឋាភិបាលនៃប្រទេសកម្ពុជាសូមសម្តែងនូវការព្រួយបារម្ភ ខ្លាចក្រែងកងទ័ពយៀក-កុង-យៀកណាមខាងជើងនឹងប្រព្រឹត្តអំពើព្រៃផ្សៃ ជាថ្មីទៀត ហើយសូមប្រកាសពញ្ញាក់មតិពិភពលោក ចំពោះគ្រោះថ្នាក់យ៉ាងអាសន្ន ដែលនឹងអាចកំហែងគំរាមដល់ប្រាសាទឯទៀតៗ ។

ដោយប្រទេសកម្ពុជាជាសហជីកជាប់កិច្ចសន្យានិងអនុសញ្ញានៃក្រុងឡាអេ ឆ្នាំ ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងករណីដែលមាន

ចម្បាំង អនុសញ្ញាដែលប្រទេសកម្ពុជាបានអនុម័ត កាលពីថ្ងៃទី ២៥ មេ ឆ្នាំ ១៩៦២, រដ្ឋាភិបាលប្រទេសកម្ពុជា សូមអំពាវនាវជាបន្ទាន់ ដល់ប្រទេសទាំងអស់ជាពិសេស ដល់ប្រទេសទាំងឡាយដែលបានចុះហត្ថលេខា និងបានចូលជាសមាជិកនៃអនុសញ្ញានេះ ដើម្បីឲ្យប្រទេសទាំងនោះ ជួយគិតគូរធ្វើសេចក្ដីស្នើការចាំបាច់ទាំងឡាយនិងចាត់វិធានការណ៍គ្រប់បែបយ៉ាង ដើម្បីជួយប្រទេសកម្ពុជាក្នុងការធ្វើឲ្យមានការគោរព និងការស្រោចស្រង់បេតិកភ័ណ្ឌសិល្បៈនិងវប្បធម៌ របស់ខ្លួន ។

ម្យ៉ាងទៀត ដោយយល់ច្បាស់ថា " ការប៉ះពាល់ដល់សម្បត្តិវប្បធម៌ ទោះជាប្រទេសណាក៏ដោយ ជាការប៉ះពាល់ដល់បេតិកភ័ណ្ឌវប្បធម៌របស់មនុស្សជាតិទាំងមូល ហើយដោយយល់ថា ការការពារបេតិកភ័ណ្ឌនោះ មានប្រយោជន៍ដ៏ធំ ដល់ប្រជាជាតិទាំងអស់ក្នុងលោក រដ្ឋាភិបាលប្រទេសកម្ពុជា មានករណីយកិច្ចយ៉ាងខ្ពង់ខ្ពស់ និងទាក់ទាញអារម្មណ៍ប្រជាជាតិនោះ ចំពោះការកំហែងគំរាម និងបំផ្លិចបំផ្លាញពពួកប្រាសាទអង្គរ និងពពួកប្រាសាទឯទៀតដែលជានិមិត្តរូបនិងជាសក្ខីភាពនៃវប្បធម៌ដ៏សម្បូណ៌ និងអារ្យធម៌ដ៏ឧត្តុង្គឧត្តមរបស់ខ្មែរ ដែលមិនមែនជាសម្បត្តិ នៃប្រទេសកម្ពុជាតែម្នាក់ឯងទេ ប៉ុន្តែជាសម្បត្តិនៃមនុស្សជាតិទាំងមូល ។

នៅទីបញ្ចប់ រដ្ឋាភិបាល នៃប្រទេសកម្ពុជា ព្រមានដល់រដ្ឋាភិបាលវៀតណាមខាងជើង និងវៀតកុង អំពីសេចក្ដីព្រហើន ចង់ប្រមាថបំផ្លេចបំផ្លាញចោលនូវអ្វីៗទាំងអស់ ហើយសូមប្រកាស ជូនដំណឹងដល់មតិអន្តរជាតិថា ខាងយើង ។ ចាត់វិធានការណ៍គ្រប់បែបយ៉ាង ដើម្បីរក្សាឲ្យគង់វង្សនូវរតនវត្ថុកេរ្តិ៍ដំណែល នៃវប្បធម៌ របស់ទាំងអស់នោះហើយ ហើយនឹងសូមប្រកាសថា ការបំផ្លេចបំផ្លាញ និងអំពើនិយមកំទេចចោល នូវប្រាសាទបុរាណនិងទីសក្ការបូជា គឺសុទ្ធតែជាអំពើព្រៃផ្សៃ អស់ពួកពាលត្បាតវៀតកុង និងវៀតណាមខាងជើងប៉ុណ្ណោះ ។ ពួកនេះជាអ្នកទទួលខុសត្រូវតែម្នាក់ឯង ហើយដែលត្រូវឆ្លើយចំពោះប្រវត្តិសាស្ត្រ និងមតិពិភពលោក អំពីអំពើបំផ្លេចបំផ្លាញ ដោយគិតទុកជាមុន នូវសម្បត្តិវប្បធម៌ទាំងអស់នោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ មិថុនា ១៩៧០

# សេចក្ដីអំពាវនាវរបស់ ឯ.ឧ. អ៊ូ-ថាន់

# ដើម្បីរក្សាការពារប្រាសាទអង្គរវត្ត

តាមទូរលេខនៃទីភ្នាក់ងារបារាំងដែលទើបនឹងបានផ្សាយចេញពីអង្គការសហប្រជាជាតិ នៅក្រុងញូវយ៉កមកថា: ឯ.ឧ. អ៊ូ-ថាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានធ្វើសេចក្ដីអំពាវនាវមួយកាលពីថ្ងៃ ចន្ទ (៨-៦-៧០) កន្លងទៅនេះ " ចំពោះសាមីប្រទេសទាំងអស់ ដើម្បីសាមីប្រទេសទាំងនោះធ្វើការប្រុងប្រយ័ត្នជាចាំបាច់ ដើម្បីរក្សាអង្គរវត្តនិងប្រាសាទដែលជាប់ក្នុងប្រវត្តិសាស្ត្រ ខាងសាសនា និងខាងវប្បធម៌ ៗ ដែលឋិតនៅក្នុងភូមិភាគប្រយុទ្ធ នៅក្នុងប្រទេសកម្ពុជា និង នៅតំបន់នានាទៀត នៃឥណ្ឌូចិន . . . "

តទៅនេះ គឺជាសេចក្ដីនៃឃ្លបទដែល ឯ ឧ. អ៊ូ-ថាន់បានធ្វើឡើងក្នុងរឿងខាងលើនេះ :

" ការរីកដាលនៃសង្គ្រាមវៀតណាម នៅប្រទេសកម្ពុជា បានធ្វើឲ្យមានមនុស្សស្លាប់ជាច្រើន , ការហិនហោចខូចខាតក៏ច្រើនណាស់ដែរ ៗ សង្គ្រាមនៅប្រទេសវៀតណាម ក្លាយទៅជាសង្គ្រាមឥណ្ឌូចិនហើយ ៗ ដំណឹងចុងក្រោយ ដែលបានចុះផ្សាយតាមសារពត៌មានពុំបញ្ជាក់ថា

“ប្រាសាទខាងផ្នែកសាសនានិងខាងផ្នែកវប្បធម៌ ដែលជាទីសក្ការៈនិងលេចឮឈ្មោះល្បីល្បាញជាងគេ នៃមនុស្សជាតិ នៅប្រទេសកម្ពុជា គឺ “ប្រាសាទអង្គរវត្ត” បានត្រូវទទួលការគំរាមកំហែងដូចប្រាសាទនៅក្រុងវើដែរ ។

ត្រូវតែជួយរំដោះអង្គរវត្តឲ្យរួច ( Angkor Wat doit être sauvé )

ខ្ញុំសូមអំពាវនាវការនេះ ប្រកបដោយជំនឿដ៏ស៊ប់ ដល់សាមីប្រទេសទាំងអស់ ដើម្បីឲ្យសាមីជនទាំងអស់ គោរពដល់ប្រាសាទបុរាណនានាដែលជាប់ក្នុងប្រវត្តិសាស្ត្រ ក្នុងផ្លូវសាសនា និងវប្បធម៌ ដែលឋិតនៅក្នុងភូមិភាគប្រយុទ្ធនានា នៅប្រទេសកម្ពុជា និងនៅក្នុងទឹកដីទៃទៀតនៃឥណ្ឌូចិន ហើយសូមប្រទេសសាមីជនទាំងអស់ ប្រកាន់នូវការប្រុងប្រយ័ត្នជាចាំបាច់ ក្នុងការថែរក្សាប្រាសាទទាំងនោះ ។ ”

សេចក្ដីថ្លែងការណ៍របស់ ឯ.ឧ អ៊ុ-ជាង នេះត្រូវបានអ្នកនាំពាក្យនៃ អ-ស-ប យកទៅតាងជូនអ្នកកាសែត ហើយអ្នកនាំពាក្យនេះ បានប្រកែកពុំព្រមបញ្ជាក់ថា គេផ្ញើសេចក្ដីអំពាវនាវនេះ ចំពោះទៅលើសាមីប្រទេសណាទេ ។ សេចក្ដីអំពាវនាវនេះ នឹងត្រូវផ្សាយឡើងតែតាមសារព័ត៌មានប៉ុណ្ណោះ ។

# សេចក្ដីអំពាវនាវរបស់អ្នកនិពន្ធខ្មែរ

## ករណីនៃការរាតត្បាតនៃកុម្មុយនិស្ដចូលប្រាសាទអង្គរ

---

ក្នុងពេលដែលចូលមករាតត្បាតទីក្រុងសៀមរាប ដែលជាខេត្តមួយយ៉ាងសំខាន់ សឹងមានពាសពេញទៅដោយប្រាសាទបុរាណ កាលពីថ្ងៃទី ៦ មិថុនា និងថ្ងៃតទៅមក, ពួកយៀកកុងយួនខាងជើងបានចូលទៅរុករានបំផ្លាញប្រាសាទអង្គរ ដែលជាបេតិកភ័ណ្ឌវប្បធម៌ដ៏ឆើតឆាយរបស់យើង ពួកសត្រូវអាចធ្វើឲ្យខូចខាតនូវក្បាច់ចម្លាក់, រូបបដិមា និងសោភណភាពខាងក្រៅនៃប្រាសាទ ដ៏ល្បីល្បាញនេះ ជាហេតុគួរឲ្យស្ដាយរកអ្វីប្រៀបគ្មាន ព្រោះថា សិល្បកម្មទំនេបថ្ម ពុំអាចជួសជុល ឬធ្វើឡើងវិញឲ្យដូចបានឡើយ ។

ប្រាសាទអង្គរ មិនត្រឹមតែជាបេតិកភណ្ឌវប្បធម៌របស់ជាតិខ្មែរទេ ថែមទាំងជាអច្ឆរិយវត្ថុ នៃសាកលលោកផងទៀត បានសេចក្ដីថា: អង្គរពិតមែនតែជាស្ថាបនកម្មរបស់ខ្មែរ តែសាកលលោកទទួលទុកជានិម្មិតកម្ម ដែលកើតពីមនុស្សជាតិពិតប្រាកដ ។ កាលបើគេវិនិច្ឆ័យប្រមាណអំពីសន្ទុះ នៃការបោះជំងរបស់មនុស្សជាតិ គឺត្រូវយកស្ថាបត្យកម្មអង្គរនេះឯង ធ្វើជាសាក្សីយ៉ាងពិតឥតក្លែងបន្ទំបាន ។

អាស្រ័យហេតុនេះរៀងរាល់ឆ្នាំមានទេសចរគ្រប់សញ្ជាតិរាប់ម៉ឺននាក់មកទស្សនាប្រាង្គប្រាសាទនេះ ដើម្បីក្រេបជញ្ជក់យករសជាតិវប្បធម៌-

អារ្យធម៌មនុស្សជាតិសម័យសតវត្សទី១០-១២ មានទាំងសិល្បៈ អក្សរសាស្ត្រ សាសនា ទស្សនវិជ្ជា ប្រវត្តិសាស្ត្រជាដើម ។

អាស្រ័យហេតុនេះ ដោយផ្អែកទៅតាមសេចក្តីអំពាវនាវនៃឯកឧត្តម លន់-នល់ នាយករដ្ឋមន្ត្រីប្រទេសកម្ពុជាដែលបានផ្ញើទៅកាន់សាកលលោក កាលពីថ្ងៃទី ១១មិថុនា១៩៧០ និងសេចក្តីថ្លែងការណ៍របស់ ឯ ឧ. អ៊ូ-ថាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ, អ្នកនិពន្ធខ្មែរទាំងអស់ សូមអំពាវនាវចំពោះសតិសម្បជញ្ញៈ អ្នកនិពន្ធ អ្នកអក្សរសាស្ត្រ អ្នកវប្បធម៌ទូទៅក្នុងសាកលលោក ជាពិសេសអ្នកវប្បធម៌ក្នុងប្រទេសទាំង-ឡាយ ដែលជាភាគីបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ ស្តីពីកិច្ចការការពារបេតិកភណ្ឌវប្បធម៌ ក្នុងករណីមានសង្គ្រាម (ដែលបានប្រជុំនៅក្រុងឡាអេឆ្នាំ១៩៥៤) សូមចាប់អារម្មណ៍ជួយធ្វើអន្តរាគមន៍ ដល់រដ្ឋាភិបាលរៀងខ្លួន ដើម្បីរិះរកមធ្យោបាយការពារប្រឆាំងនឹងមារសត្រូវរបស់កម្ពុជា គឺពួកយៀកកុង-យៀកណាមខាងជើង ដែលជាអ្នកបំផ្លាញទ្រព្យដ៏មានតម្លៃ នៃមនុស្សជាតិនេះ ដើម្បីឲ្យបានស្របតាមប្រការ២៣ នៃអនុសញ្ញា ខាងលើនេះ " ។

អ្នកនិពន្ធខ្មែរ សូមទាញអារម្មណ៍អង្គការអន្តរជាតិទាំងអស់ជាពិ-សេសអង្គការខាងការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ

(យូណេស្កូ) សូមជួយចាត់វិធានការពេញសមត្ថភាព តាមអំណាចប្រការ ១៩-២២-២៣ នៃអនុសញ្ញាដែលពោលខាងលើ ដើម្បីបញ្ឈប់យ៉ាងរួសរាន់ ឬ ជួយទប់ទល់ការពារប្រាសាទបុរាណទាំងនេះ ឲ្យជៀសផុតពីមហន្តរាយដែលនឹងកើតមានតទៅទៀត ។

អ្នកនិពន្ធខ្មែរទាំងអស់ សូមប្រកាសដាក់ទោសយ៉ាងធ្ងន់លើកងទ័ពវៀតកុង-វៀតណាមខាងជើង ព្រមទាំងអ្នកបង្គាប់បញ្ជាទាំងអស់ ដែលបានចូលមកបំផ្លាញ ទ្រព្យពិសិដ្ឋគ្មានគូផ្ទឹមរបស់ជាតិខ្មែរ និងរបស់មនុស្សជាតិទាំងមូលនេះ

ភ្នំពេញ ថ្ងៃទី ២០ មិថុនា ១៩៧០

ប្រធានសមាគមអ្នកនិពន្ធខ្មែរ

ហត្ថលេខា: លាង - ហាប់ អាន